00932767



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jun-2013, 11:58
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅជំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី១៩៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ ដារាវស្មី

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឃីត រេយ៍ន័រ *(Mr.Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ (*Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ហុង គីមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះ គឺជាថ្ងៃចាប់ផ្តើមនៃសប្តាហ៍ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការដាក់បង្ហាញនូវឯកសារគន្លឹះដោយភាគីចំពោះមុខអង្គជំនុំជម្រះ ឬការដាក់ឯកសារគន្លឹះរបស់អង្គជំនុំជម្រះចំពោះមុខភាគី ដូចអង្គជំនុំជម្រះបានជម្រាបជូនកន្លងមក។

កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ កន្លងទៅនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយដើម្បីជម្រាបជូនទៅភាគីពាក់ព័ន្ធនៃរឿងក្តីថា អង្គជំនុំជម្រះនឹងធ្វើសវនាការនៃការបង្ហាញឯកសារគន្លឹះសំខាន់ៗជាលើកចុងក្រោយ ដែលភាគី ឬអង្គជំនុំជម្រះយល់ថា ជាប់ពាក់ព័ន្ធបំផុតទៅនឹងសំណុំរឿង០០២/០១ ដែលឯកសារទាំងនោះធ្លាប់បានពិភាក្សាដេញដោលរួចមកហើយនៅចំពោះមុខអង្គជំនុំជម្រះ ផ្អែកលើកឯកសារ E288។

ក្រឡាបញ្ជីសវនាការលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរសវនាការថ្ងៃនេះ!

[០៩:០៤:១០]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៃការបង្ហាញឯកសារគន្លឹះនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ វាមានវត្តមាន។ សូមកត់សម្គាល់ថា ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយមូលហេតុបញ្ហាសុខភាព។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណលោក ផារី ហើយ -- នាពេលកន្លងទៅនេះសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំពេលវេលាចំនួន៣ថ្ងៃ សម្រាប់ភាគីនីមួយៗក្នុងការបង្ហាញឯកសារគន្លឹះ ដែលសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមរដ្ឋប្បវេណីយល់

ថាមានសារប្រយោជន៍ដើម្បីជាជំនួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃភស្តុតាង។ ប៉ុន្តែនៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានធ្វើឡើងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ កន្លងទៅនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលវេលាដែលខ្លួនស្នើសុំនោះនឹងបន្ថយមកនៅ ត្រឹមតែ១ថ្ងៃកន្លះវិញ។ មេធាវីការពារក្តីជនជាប់ចោទ នួន ជា មិនមានបំណងបង្ហាញឯកសារគន្លឹះនោះទេ ក៏ប៉ុន្តែបានស្នើសុំពេលវេលាចំនួន១ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងបណ្តាឯកសារដែលភាគីផ្សេងទៀតបានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:០៥:៣៧]

ហើយចំណែកឯមេធាវីការពារក្តីលោក ខៀវ សំផន បានតវ៉ាដោយលើកឡើងថាសវនាការបែបនេះគឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ ខៀវ សំផន ដោយហេតុថាមេធាវីការពារក្តីពុំត្រូវបានអនុញ្ញាតឲ្យជំទាស់តវ៉ា ឬពិភាក្សាទៅលើឯកសារដែលបានលើកដោយភាគីនានានោះឡើយ។

ហេតុដូច្នេះហើយអង្គជំនុំជម្រះគួរធ្វើសវនាការបន្ថែមទៀត ស្តីពីភាពអាចទទួលយកបាននៃឯកសារ ព្រមទាំងទម្ងន់នៃភស្តុតាងចំពោះឯកសារដែលបានបង្ហាញរួចហើយនៅក្នុងសវនាការនាពេលកន្លងមក ឯកសារ E263។

ដូចដែលបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈស្តីពីការកំណត់កាលវិភាគសវនាការបង្ហាញឯកសារគន្លឹះនៅក្នុងសវនាការនេះ ឯកសារ E288/1/1 ដែលបានផ្ញើជូនភាគីនៃសំណុំរឿងក្តីជាលក្ខណៈក្រៅផ្លូវការកាលពីថ្ងៃចន្ទ ដើមសប្តាហ៍មុន និងបានដាក់ចូលទៅក្នុងសំណុំរឿងកាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣។

អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា សវនាការនៃការបង្ហាញឯកសារគន្លឹះមិនមែនជាសវនាការនៃការពិភាក្សាដេញដោលលើភាពអាចទទួលយកបាននៃឯកសារដែលត្រូវបានលើកមកបង្ហាញនៅក្នុងសវនាការពិភាក្សាដេញដោលលើភស្តុតាងកន្លងមកនោះទេ។ ប៉ុន្តែវាជាសវនាការមួយដែលអនុញ្ញាតឲ្យភាគីលើកយកឯកសារសំខាន់ៗ ទាំងឯកសារដាក់បន្ទុក ទាំងឯកសារដោះបន្ទុក ដើម្បីជាជំនួសដល់អង្គជំនុំជម្រះលើការវាយតម្លៃលើតម្លៃនៃភស្តុតាង នៅពេលដែលអង្គអង្គជំនុំជម្រះធ្វើការថ្លឹងថ្លែងទៅលើទម្ងន់នៃភស្តុតាងទាំងនោះ បន្ទាប់ពីសវនាការពិភាក្សាដេញដោលលើភស្តុតាងត្រូវបានបញ្ចប់។

[០៩:០៧:៣៣]

ម្យ៉ាងទៀត សវនាការនេះក៏ដើម្បីជួយដល់សាធារណជនយល់បានកាន់តែច្បាស់នូវឯកសារទាំង

ឡាយដែលបានពិភាក្សាដេញដោលនាពេលកន្លងមក ដោយសារតែសំណុំរឿងក្តីនៅចំពោះមុខមានទំហំធំ ហើយស្មុគស្មាញ។ ទោះជាយ៉ាងនេះក្តីមេធាវី ខៀវ សំផន ក៏ដូចជាជនជាប់ចោទមិនបានប្រើប្រាស់នូវឱកាសដែលអង្គជំនុំជម្រះបានផ្តល់ដើម្បីកត់សម្គាល់ ឬអត្ថាធិប្បាយលើឯកសារទាំងឡាយដែលបានលើកបង្ហាញដោយភាគីផ្សេងទៀត ជាពិសេសពីសំណាក់សហព្រះរាជអាជ្ញានាពេលកន្លងមកនោះឡើយ។

ប៉ុន្តែដើម្បីជាប្រយោជន៍យុត្តិធម៌ អង្គជំនុំជម្រះនៅតែផ្តល់ពេលវេលាដល់ជនជាប់ចោទ ខៀវ សំផន និងក្រុមមេធាវីការពារក្តីរបស់គាត់ធ្វើការកត់សម្គាល់ ឬក៏ធ្វើអត្ថាធិប្បាយលើបណ្តាឯកសារទាំងឡាយដែលត្រូវបានដាក់បង្ហាញដោយភាគីដទៃទៀតនៅក្នុងសវនាការ។ ការដាក់បង្ហាញនូវឯកសារគន្លឹះដែលបានធ្វើកន្លងមក ប្រសិនបើជនជាប់ចោទ ខៀវ សំផន និងមេធាវីការពារក្តីរបស់គាត់មានបំណងធ្វើដូច្នេះ។ អាស្រ័យហេតុនេះអង្គជំនុំជម្រះធ្វើការបែងចែកពេលវេលានៃការបង្ហាញឯកសារគន្លឹះ និងពេលវេលាសម្រាប់កត់សម្គាល់ ឬអត្ថាធិប្បាយទៅនឹងការបង្ហាញឯកសារគន្លឹះដូចខាងក្រោមនេះ៖

[០៩:០៨:៥៥]

សហព្រះរាជអាជ្ញា អង្គហេតុសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវ២ថ្ងៃ។ តួនាទីរបស់ជនជាប់ចោទ១ថ្ងៃ។ រយៈពេលសរុបសម្រាប់សហព្រះរាជអាជ្ញាមានរយៈពេល៣ថ្ងៃ។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គហេតុសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវ១ថ្ងៃ។ តួនាទីរបស់ជនជាប់ចោទកន្លះថ្ងៃ។ ពេលវេលាសរុបសម្រាប់សហមេធាវីនាំមុខមានរយៈ១ថ្ងៃកន្លះ។

មេធាវីការពារក្តីលោក នួន ជា អង្គហេតុសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវកន្លះថ្ងៃ។ តួនាទីរបស់ជនជាប់ចោទកន្លះថ្ងៃ។ រយៈពេលសរុបសម្រាប់មេធាវីការពារក្តី នួន ជា មានរយៈពេល១ថ្ងៃ។

មេធាវីការពារក្តីលោក ខៀវ សំផន ឯកសារគ្រប់ប្រភេទទាំងអស់ដែលពួកគាត់ស្នើសុំធ្វើការកត់សម្គាល់ ឬក៏ធ្វើអត្ថាធិប្បាយ កន្លះថ្ងៃ។

ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ឡើងបង្ហាញឯកសារគន្លឹះដែលខ្លួនយល់ឃើញថាមានសារប្រយោជន៍ ដើម្បីជាជំនួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃភស្តុតាងពាក់ព័ន្ធទៅនឹងអង្គហេតុសហឧក្រិដ្ឋកម្មរួម ទម្រង់នៃការទទួលខុសត្រូវ ហើយនិងបន្តគឺ ហ្នឹងតួនាទីរបស់ជនជាប់ចោទ។ សូមអញ្ជើញ!

[០៩:១០:៣៦]

**លោក ឃីត រេយ៍ន័រ៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម អរុណសួស្តីសហការី។ នៅក្នុងការបង្ហាញឯកសារស្តីអំពីសហឧក្រិដ្ឋកម្មរួមទាក់ទងទៅនឹងការជម្លៀសប្រជាជន ជនស៊ីវិលដោយបង្ខំនៅដំណាក់កាលទី១ និងទី២ សហព្រះរាជអាជ្ញានឹងបង្ហាញជូននូវឯកសារដែលខ្លួនពិចារណាថាមានការពាក់ព័ន្ធយ៉ាងខ្លាំងដើម្បីជួយវាយ -- អង្គជំនុំជម្រះដើម្បីវាយ ស្វែងរកការពិត។

ឯកសារពាក់ព័ន្ធទៅនឹងបញ្ហា និងព្រឹត្តិការណ៍ដូចតទៅនេះ៖

ទី១) គោលនយោបាយស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជាមុនការជម្លៀសប្រជាជន។ គោលនយោបាយបក្សនេះគឺជាឯកសារផ្លូវការបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា ដូចជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា និងបញ្ហានៅក្នុងទង់បដិវត្ត ដែលជាចំណុចស្នូលទៅដល់មនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីចម្រាញ់ពួកខ្មាំង និងជម្លៀសប្រជាជនស៊ីវិល។ ឧទាហរណ៍នៃការចម្រាញ់ប្រជាជន និងការជម្លៀសប្រជាជនដោយបង្ខំនេះ គឺយើងយោងទៅលើព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងខេត្តក្រចេះ កំពង់ចាម សៀមរាប ភូមិភាគបូព៌ា ភូមិភាគនិរតី។ ជាពិសេសព្រឹត្តិការណ៍នៅឧដុង្គ ក្នុងខែមីនា ឆ្នាំ១៩៧៤។

ទី៣) មតិដែលលើកឡើងដោយខៀវ សំផន ក្នុងសុន្ទរកថាដែលថ្លែងនៅកូរ៉េខាងជើង នៅថ្ងៃទី៥ មេសា ៧៤ នៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍បន្ទាប់ពីការវាយប្រហារនៅក្រុងឧដុង្គ ក៏ដូចជាឯកសារផ្លូវការណ៍ដែលចេញនៅពេលដដែលនោះដែរ ដែលក៏និយាយអំពីការវាយប្រហារទីក្រុងឧដុង្គនោះផងដែរ។

[០៩:១៣:១០]

ទី៤) ការបំលាស់ទីរបស់ ខៀវ សំផន និង អៀង សារី ការធ្វើដំណើររបស់ ខៀវ សំផន និង អៀង សារី ដែលជាតំណាងដ៏សំខាន់របស់រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិក្នុងអំឡុងផ្លូវទស្សនកិច្ចផ្លូវការទៅកាន់វៀតណាម ចិន និងបណ្តាប្រទេសនៅអឺរ៉ុប និងអាហ្វ្រិក នៅក្នុងអំឡុងពីថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៤ ហើយត្រឡប់មកកាន់ទីក្រុងប៉េកាំងនៅចុងខែឧសភា ឆ្នាំ១៩៧៤។

ទី៥) សេចក្តីសម្រេចជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ក្នុងនោះរួមមានភស្តុតាងនៃជំនួបរវាង ប៉ុល ពត និង អៀង សារី ក្នុងខែមិថុនា ឆ្នាំ១៩៧៤ និងមតិយោបល់ដែលលើកឡើងដោយ នួន ជា ទាក់ទងទៅនឹងដំណើរធ្វើសេចក្តីសម្រេច និងការប្រើមធ្យោបាយប្រជាធិបតេយ្យ។

[០៩:១៤:១៨]

ទី៦) ឧទាហរណ៍តាមរយៈការទទួលបានតេឡេក្រាមនៃការជម្លៀស និងការសម្លាប់ជនស៊ីវិល នៅចុងឆ្នាំ៧៥។

៧) រដ្ឋាភិបាលសហរដ្ឋអាមេរិករាយការណ៍ -- របាយការណ៍សហរដ្ឋអាមេរិកចុះថ្ងៃ១៧ មីនា ៧៥ ដែលបានរៀបចំឡើងដើម្បីការប្រើប្រាស់ដ៏សំខាន់មួយជាមួយនឹងសមាជរបស់ -- ជាមួយនឹងមហាសន្និបាតសហរដ្ឋអាមេរិក និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានលើកឡើងអំពីឧបទ្ទវហេតុនៃអំពើឃោរឃៅ និងជាជនស៊ីវិលដោយពួកខ្មែរក្រហមដែលឈានទៅដល់ការជម្លៀសនេះឯង។

ទី៨) ខ្លឹមសារនៃសុន្ទរកថាដែលថ្លែងដោយ ខៀវ សំផន នៅពេលដែលឈានទៅដល់ការជម្លៀសដោយប្រជាជនដោយបង្ខំដំណាក់កាលទី១ និងឯកសារដែលបង្ហាញថា គាត់ក៏នៅជាមួយនោះផងដែរ។

និងទី៩) យោបល់ដែលលើកឡើងដោយ អៀង សារី ទៅកាន់អ្នកកាសែតអន្តរជាតិបង្ហាញអំពីយុត្តិកម្មគាំទ្រទៅដល់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

[០៩:១៥:៤០]

លោកប្រធាន ខ្ញុំសូមយោងទៅលើឯកសារ E3/214។ នេះគឺជាលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។ បើខ្ញុំយោង *អ៊ីងគ្លីស* ERN 00184033, ខ្មែរ 00053018 លើ 9, បារាំង 00292923។

នេះគឺមាត្រា៤ នៃលក្ខន្តិកៈនិយាយអំពីវិន័យរបស់បក្ស។ ខ្ញុំសូមធ្វើការបង្ហាញនៅក្នុងអេក្រង់មុននឹងខ្ញុំចាប់ផ្តើមនិយាយនេះ។

មាត្រា៤(១) ដើម្បីរក្សា និងពង្រឹងសាមគ្គីឯកភាពផ្ទៃក្នុងបក្សឲ្យបានល្អរហូតនោះ គឺថាបក្សបានលើកឡើងនូវគោលការណ៍ពាក់ព័ន្ធទៅនឹងវិន័យនៅក្នុងជួរបក្ស។ វិន័យរបស់បក្ស គឺជាការរឹងមាំ ប៉ុន្តែអ្វីក៏ដោយត្រូវតែគោរព និងប្រតិបត្តិតាមវិន័យរបស់បក្សដាច់ខាត។ គឺថាគ្រប់ចំណុចទាំងអស់ត្រូវតែគោរព និងដើរតាមវិន័យរបស់បក្ស។ គោរពវិន័យ និងគោរពអង្គការរបស់បក្សនេះ គឺគោរពមាគ៌ានយោបាយរបស់បក្ស គោលជំហរសតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំងរបស់បក្ស និងលក្ខន្តិកៈរបស់បក្ស។

លេខ២ សមាជិកបក្សទាំងអស់ ដែលជំទាស់ជាមួយនឹងគោលនយោបាយរបស់បក្ស អង្គការបក្ស និងលក្ខន្តិកៈរបស់បក្ស។ ធ្វើឲ្យប្រេះឆាសាមគ្គីឯកភាពផ្ទៃក្នុង បង្កជាបក្សពួកធ្វើសកម្មភាព បំផ្លិច

បំផ្លាញបក្សបដិវត្តន៍។

[០៩:១៨:០៦]

ឯកសារបន្ទាប់គឺ E3/16។ នេះគឺជាសម្រង់ឯកសារពីសៀវភៅដែលសរសេរដោយ -- ការពិចារណាទៅលើប្រវត្តិសាស្ត្រកម្ពុជាពីដំណាក់កាលដំបូង រហូតមកដល់ដំណាក់កាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សម្រង់នេះគឺមាន ERN អង់គ្លេស 00498231, ខ្មែរ 00380267, បារាំង 00643834។ ចំណងជើង ឃ "គោលនយោបាយបក្ស និងរបស់បក្សថ្មី"។ គោលនយោបាយនេះនិយាយថា "វណ្ណៈជិះជាន់ គឺជាខ្មាំងរបស់បដិវត្តន៍ និងជាឧបករណ៍របស់ពួកចក្រពត្តិអាមេរិក។ តើប្រជាជនត្រូវកម្ចាត់របបមូលធននិយម ដោយប្រើមធ្យោបាយសមស្រប ឬក៏មធ្យោបាយណាដទៃទៀតនោះ ដែរឬយ៉ាងណា?"

ឯកសារបន្ទាប់គឺ E3/18។ នេះគឺសៀវភៅដែលសរសេរឡើងដោយ ខៀវ សំផន ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រថ្មីៗនៃប្រទេសកម្ពុជា និងមូលហេតុនៅពីខាងក្រោយសេចក្ដីសម្រេចដែលខ្ញុំបានធ្វើឡើង"។ ERN អង់គ្លេស 00103778 ខ្ញុំជឿជាក់ថា ឯកសារនេះនឹងបង្ហាញជូននៅលើអេក្រង់ហើយៗ, ERN ជាភាសាខ្មែរ 00103873, បារាំង 00595484 ដល់ 85។

ចំណងជើងនេះគឺនិយាយអំពី "ការបង្កើនល្បឿនរបបកុម្មុយនីស្តនៅក្នុងប្រទេស"។ សូមដកស្រង់ដូចតទៅ៖ "ជ័យជម្នះខ្មែរក្រហមនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ បានពង្រឹងជំនឿ ប៉ុល ពត ថាផ្លូវតែមួយគត់ដើម្បីចលនាខ្មែរក្រហម ហើយតាមរយៈនេះដើម្បីកម្ពុជារស់នៅចំពោះមុខអ្វីដែលគាត់ហៅថា គ្រោះអាសន្នវៀតណាម។ គ្រោះអាសន្ននៅពេលដែលគាត់យល់ថា មានទំហំធ្ងន់ធ្ងរណាស់ក្រោយវៀតណាមបង្រួបបង្រួមហើយ។ ផ្លូវដើម្បីរស់គឺសមូហភាវូបនីយកម្ម"។

[០៩:២១:៣០]

នៅក្នុងឯកសារនេះដដែលតែមានលេខ ERN ខុសគ្នា។ ERN ជាភាសាអង់គ្លេស 00103776, ខ្មែរ 00103870, បារាំង 00595479 ដល់ 80។ បាទ ខ្ញុំសូមបង្ហាញសៀវភៅដែលសរសេរឡើងដោយលោក ខៀវ សំផន ដដែល។ សូមដកស្រង់៖ "ចាប់តាំងពីនោះមក ខ្ញុំបានអានឯកសារផ្ទៃក្នុង និងបានស្ដាប់អ្នកដឹកនាំភូមិភាគ ឬតំបន់និយាយរៀបរាប់ថា ក្នុងរយៈពេលនោះទំនាស់សង្គមនៅក្នុងទីក្រុងក្ដី នៅជនបទក្ដី ទោះបីតូចយ៉ាងណាក៏ដោយក៏ជាថ្នាលសម្រាប់បក្សកុម្មុយនីស្តកម្ពុជាអប់រំ លត់ដំកម្មាភិបាលសម្រាប់ឲ្យគេធ្វើជាស្នូលអង្គការមហាជនគ្រប់បែបយ៉ាង ប៉ុន្តែនៅទីក្រុងចលនាត្រូវខ្វះខាតច្រើនជាង

នៅជនបទ”។

[០៩:២៣:០៩]

យោងទៅតាមឯកសារនេះពន្យល់ថា សូមដកស្រង់៖ “នៅទីក្រុងម៉ាស៊ីនរាតត្បាតរបស់ខ្លាំងប្រណីតជាង និងណែនជាងនៅជនបទ ហើយកម្មករត្រូវរបបមូលធននិយមបំពុកបំពុល។ ចំណែកនៅជនបទទូលំទូលាយ ខ្មាំងខ្សោយ ហើយកសិករមិនសូវទទួលឥទ្ធិពលអាក្រក់ពីមូលធននិយមទេ។ នៅជនបទមិនគ្រាន់តែមានសមាគមកសិករតាមរូបភាពផ្សេងៗជាច្រើនប៉ុណ្ណោះ ដូចជាកងការពារ។ កសិករក្មេងៗគេរៀនចង -- កសិករហាត់ប្រើខ្សែគោ ក្រមា ដំបងឫស្សី វល្លិ៍ កាំបិត ពូថៅ។ល។ អាវុធនិយាយមួយម៉ាត់គឺប្រើប្រាស់អ្វីៗដែលនៅជិតនឹងដៃគេ ដើម្បីធ្វើការតស៊ូទប់ទល់មេឃុំ ជំទប់ មេព្រៃ មេនេសាទដែលឃោរឃៅ ឬប្រឆាំងទៅនឹងអ្នកណាដែលមករឹបអូសយកដីរបស់គេ ឬរបស់ឪពុកម្តាយគេ។ ពេលខ្លះគិញសម្ងាត់របស់រដ្ឋអំណាចដែលមកលបស្តាប់ ឬតាមដានការប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជាក៏ត្រូវចាប់យកទៅបាត់”។

ឯកសារបន្ទាប់នេះគឺE3/5 នេះគឺសម្រង់ពីឯកសារទង់បដិវត្តចុះថ្ងៃ០៨ សីហា ១៩៧៥។ សម្រង់ដែលមាន ERN ជាភាសាអង់គ្លេស 00401492, ខ្មែរ 00063329, បារាំង 00538966។ នេះគឺមានចំណងជើងថា “កងការពារសម្ងាត់”។ សូមដកស្រង់ “កងការពារសម្ងាត់ចាត់តាំង ឡើងនៅគ្រប់កន្លែងនៅក្នុងប្រជាជនកសិករ កម្មករ ពលករ និងសិស្សដែលបំពាក់អាវុធ គឺកាន់អាវុធដោយស្របច្បាប់ក្តី មិនស្របច្បាប់ក្តី តែកងការ -- តែជាកងការពារសម្ងាត់របស់បក្ស។ តើគេមានភារកិច្ចអ្វីខ្លះ? ភារកិច្ចរបស់កងការពារសម្ងាត់គឺការពារមូលដ្ឋានបដិវត្តន៍ ការពារប្រជាជនបដិវត្តន៍ ការពារកម្មាភិបាលដើរហើរធ្វើការ ការពារសន្និបាត និងការប្រជុំផ្សេងៗ។ ហើយទន្ទឹមនឹងនេះគឺលបកម្ទេចខ្មាំងជាគិញ និងពួកប្រតិកិរិយាផ្សេងៗដើម្បីការពារបក្ស បដិវត្តន៍ និងប្រជាជន”។ បញ្ចប់ការដកស្រង់។

[០៩:២៦:៥២]

ឯកសារបន្ទាប់គឺ E3/25។ នេះគឺជាការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានចំណងជើងថា “ទង់បដិវត្តន៍ លេខពិសេស ចុះខែធ្នូ ឆ្នាំ១៩៧៦ ដល់ មករា ១៩៧៧”។ សម្រង់ជាភាសាអង់គ្លេសគឺ 00491424, ខ្មែរ 00063039 ដល់ 40, និងបារាំង 00504049 ដល់ 50។ ចំណងជើងនៃសម្រង់នេះ សូមដកស្រង់ “ការវាយខ្មាំងតាមរូបភាពនយោបាយ។ សូមលើកជាឧទាហរណ៍មួយបង្ហាញជូន ការវាយប្រហារដើម្បីរឹបចាប់ ដើម្បីកែនប្រជាជនមាគ៌ារបស់យើងគឺដើម្បីវាយប្រយុទ្ធរឹបអូសយក

ប្រជាជននៅពេលយើងទទួលបានប្រជាជន។ ថ្ងៃនេះយើងយកបានគាត់ម្នាក់ ថ្ងៃនេះយើងយកបានអ្នកដទៃ យើងយកបានរាប់រយ។ យើងអាចប្រមូលពីប្រជាជនមកបានរាប់ពាន់រហូតទល់យើងវាយប្រយុទ្ធនឹងរឹបអូសបានប្រជាជនទាំងអស់នៅក្នុងទីក្រុងភ្នំពេញ។

មាគ៌ាចម្រាញ់ប្រជាជនពីខ្មាំងនេះគឺជាការត្រឹមត្រូវបំផុត។ ការណ៍នេះគឺមិនដែលមានកើតឡើងនៅក្នុងពិភពលោកនោះទេ។ នៅពេលណាខ្មាំងមានប្រជាជននៅក្នុងដៃ គឺខ្មាំងមានយោធា ខ្មាំងមានសេដ្ឋកិច្ច។ បើខ្មាំងគ្មានប្រជាជន វាគ្មានកម្លាំងយោធា គ្មានកម្លាំងសេដ្ឋកិច្ចទេ។ ហេតុផលយើងត្រឹមត្រូវ។ ដូច្នេះមាគ៌ាយើងត្រឹមត្រូវណាស់។ កន្លែងណាក៏ដោយ គឺយើងវាយដើម្បីដណ្ដើមប្រជាជន។ ឧទាហរណ៍ វាយខាងបាណាមនៅក្នុងឆ្នាំ៧៣ យកទាំងអស់នៅក្នុងក្រុងបាណាម បញ្ចេញទាំងអាណិកជនវៀតណាម អាណិកជនចិន ទាំងទាហាន ទាំងប៉ូលិស យើងយកអ្វីៗទាំងអស់ ពង្រឹង ពង្រីងប្រជាជនពីខ្មាំង។ ឧទាហរណ៍ យើងរំដោះឧដុង្គនៅឆ្នាំ១៩៧៤ យើងបានដណ្ដើមយកប្រជាជនទាំងអស់។ នេះជាមាគ៌ាយុទ្ធសាស្ត្រមួយដែលមានសារៈសំខាន់ណាស់ក្ដាប់ប្រជាជន ដណ្ដើមប្រជាជន”។

[០៩:៣០:៣៤]

លោកប្រធានខ្ញុំសូមការអនុញ្ញាតបន្តិច ដើម្បីចង់មានការបង្ហាញនូវទំព័រមួយទៀត។

ឯកសារបន្ទាប់គឺ E3/118។ នេះជារបាយការណ៍ផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាដែលមានហត្ថលេខានៅចុងបញ្ចប់នៃឯកសារនេះ។ ជារបាយការណ៍ទាក់ទងទៅនឹងកិច្ចប្រជុំមួយដើម្បីអបអរសាទរការចាប់ផ្ដើមតស៊ូនៅអមលាំង។ បាទ នេះគឺជាកិច្ចប្រជុំមួយដែលធ្វើឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៤។ ទំព័រខាងមុខនៃឯកសារនេះ ERN ជាភាសាអង់គ្លេស 00583819, ហើយខ្មែរ 00383754 លើ 5, បារាំង 00788350។ របាយការណ៍នេះមានចំណងជើងថា “កម្មវត្ថុ: ការប្រជុំធ្វើបុណ្យខួបលើកទី២៣ របស់ខ្មាំង និងសុន្ទរកថារបស់លោក ហ៊ូ យន់។ នៅថ្ងៃទី៣០ ខែកញ្ញា ១៩៧៤ គណៈកម្មាធិការនៃគណៈកម្មធិការបក្សកុម្មុយនីស្តកម្ពុជា បានប្រជុំធ្វើបុណ្យរំឭកខួបស្ដីពីប្រវត្តិនៃការតស៊ូ២៣ឆ្នាំនៅស្រុកអមលាំង។ ព្រឹត្តិការណ៍នេះបានប្រារព្ធធ្វើឡើងដោយមានការចូលរួមនៅក្នុងក្របខ័ណ្ឌខ្មែរក្រហមយ៉ាងច្រើន បក្ខជន និងកងកម្លាំងប្រដាប់អាវុធ ប្រជាជនរំដោះកម្ពុជា ដែលទាំងអស់គ្នាស្លៀកខ្មៅពាក់ខ្មៅមកពីគ្រប់តំបន់ទាំងអស់”។ និងជាភាសាខ្មែរគឺរំលងមួយទំព័រគឺ 00383755, បាទបារាំងនៅទំព័រដដែលនេះទេ។ យើងឃើញអំពីអ្នកចូលរួមនៅក្នុងកិច្ចប្រជុំមាន ជូ ជេត។ ពេលនោះគឺថាជាប្រធានភូមិភាគនិរតី ហើយលេខ៣ តាម៉ុក ជាមេបញ្ជាការកងទ័ពភូមិភាគនិរតីទិស។ ហើយ

បន្ទាប់ -- ទំព័របន្ទាប់គឺ 00383756, អង់គ្លេស 00583821 ហើយបារាំង 00788352។

[០៩:៣៤:០១]

យើងឃើញមានអ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះដទៃទៀតដែរ គឺនៅក្នុងត្រង់លេខ៤៧ គឺ សាឡុត ស លេខាបក្ស ហើយលេខរៀងទី៤៨ ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុករៀបចំទីជនបទ និងសហករណ៍។ លេខ៥០ ឈ្មោះ ទីវ អុល អនុរដ្ឋលេខាធិការក្រសួងឃោសនាការ។ ឯលេខ៥៣ គឺ កុយ ធួន អនុរដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ ហើយលេខ៥៤ មិត្ត កែន ឬក៏ថា ភូរិស្សរ៉ា ដែលជាសមាជិកផងដែរ។

បាទចូលទៅទំព័រខ្មែរបន្ទាប់ 00383757, បារាំង 00788353, បារាំង *(ស៊ីក)* 00583822 សូមដកស្រង់ដូចតទៅ៖ "ដំបូង ជូ ជេត បានបើកប្រកាសពីកម្មវិធីសំឡេងឧគ្ឃោសនសព្ទបានបំពងបញ្ជាខ្លាំងៗឲ្យមិត្តទាំងអស់ទម្លាក់ដៃអាវចុះ ហើយនិងប្រុងប្រៀបគោរពទង់បក្ស។ ទស្សនិកជនកម្មាភិបាល កងទ័ពគោរពដោយស្ងៀមស្ងាត់ បទភ្លេងគោរពទង់បក្សបានបន្លឺឡើង។ ហើយបន្តិចៗម្តងលេចផ្ទាំងក្រហម កំណាត់ក្រហម ប្រហែលបួនម៉ែត្រ មានសញ្ញាកណ្តៀវ និងញញួរ ប្រទាក់គ្នានៅចំកណ្តាលផ្ទាំងក្រហម ដូចទង់សញ្ញារបស់សូវៀតដែរ។ ពួកគេនាំគ្នាក្តាប់ដៃគោរពដោយស្ងៀមស្ងាត់។ លុះចប់ពិធីនេះហើយ ហ៊ូ យន់ ឡើងទៅកាន់វេទិកា ថ្លែងសុន្ទរកថាមួយយ៉ាងវែងអស់រយៈពេល៣ម៉ោង រំឭកអំពីប្រវត្តិតស៊ូ២៣ឆ្នាំនៃបក្សកុម្មុយនីស្តកម្ពុជា និងឲ្យយោបល់ទៅកម្មាភិបាលកងទ័ពដែលមានតួនាទីសំខាន់ៗ"។

[០៩:៣៦:៤៣]

បន្តទៅដល់ចំណុចដកស្រង់នៅក្នុងសុន្ទរកថារបស់ ហ៊ូ យន់ ខ្មែរគឺ 00383759, បារាំងមានលេខ 00788354, អង់គ្លេស ERN គឺមានលេខ 00583823។ ហ៊ូ យន់ បានលើកឡើងអំពីប្រវត្តិនៃអង្គការបក្ស។ ខ្ញុំសូមដកស្រង់ "ដោយអាស្រ័យហេតុនេះហើយ ទើបអង្គការបក្សពុំព្រមចូលរួមក្រោមនឹមសក្តិភូមិ និងរាជសម្បត្តិទេ។ គឺអង្គការទុកចាត់តាំងកម្មាភិបាលជាបីផ្នែក, មួយផ្នែកឲ្យទៅសិក្សានៅប្រទេសវៀតណាមខាងជើង, មួយផ្នែកឲ្យទៅតាមចលនានយោបាយនៅតាមទីក្រុង និងមួយផ្នែកទៀតឲ្យនៅចលនានយោបាយតាមជនបទ"។

ចំណុចដកស្រង់មួយទៀតគឺខ្មែរ 00383763, បារាំងមានលេខ 00788356, អង់គ្លេសមានលេខ 00583824។ ខ្ញុំសូមដកស្រង់សម្តី "ក្រោយមកទើបអង្គការអនុវត្តផែនការតាមពាក្យស្លោក តាម

ដំណាក់កាលទី១ វាយជនបទ។ ហ៊ុមព័ទ្ធទីក្រុង ដំណាក់កាលទី២។ ការអនុវត្តតាមពាក្យស្លោកក៏សម្រេចបានជោគជ័យច្រើន។ ដូច្នេះហើយមុនឆ្នាំមកដល់ឆ្នាំ១៩៧១ ទើបអង្គការសម្រេចឲ្យកម្មាភិបាលកងទ័ពទាំងអស់រំដោះខ្លួនចេញពីកងឯកភាពវៀតណាមឲ្យអស់ ដោយពឹងលើឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន"។

[០៩:៣៩:២០]

និងចំណុចដកស្រង់ចុងក្រោយនៃសុន្ទរកថារបស់ ហ៊ូ យន់។ នេះគឺត្រង់លេខខ្មែរ ERN 00383766, បារាំងមានលេខ 00788357, អង់គ្លេសមានលេខ 00583826។ ជាសេចក្តីណែនាំពី ហ៊ូ យន់ ទៅដល់កម្មាភិបាលកងទ័ព។ ខ្ញុំសូមដកស្រង់ "ចាប់ពីពេលនេះទៅ កងទ័ពត្រូវរំដោះប្រទេសទាំងអស់ ក៏ប៉ុន្តែត្រូវចងចាំថា មុនពេលដែលយើងវាយខ្មាំងខាងក្រៅ យើងត្រូវវាយកម្ចាត់ខ្មាំងខាងក្នុងយើងជាមុនសិន។ កម្មាភិបាលទាំងអស់ត្រូវធ្វើការបែងចែកឲ្យបានច្បាស់លាស់រវាងមិត្ត និងខ្មាំង។ ហើយត្រូវតែយកជំហរដូចខាងក្រោម៖ ១) គោលជំហរពលកម្ម ២) គោលជំហរនយោបាយ ៣) គោលជំហរសាមគ្គី ៤) គោលជំហរសតិអារម្មណ៍ ៥) គោលជំហរចាត់តាំង"។

ឯកសារមួយទៀត គឺឯកសារ E3/118 គឺឯកសារដកស្រង់ចេញពីហ្វីប៊ីស ចុះខែមេសា ឆ្នាំ១៩៧៥។ ចំណងជើងឯកសារនេះគឺសរសេរថា "ថ្ងៃទី២១ ខែមេសា -- សាររបស់ ខៀវ សំផន នៅតាមវិទ្យុទីក្រុងភ្នំពេញ ថ្ងៃទី២១ ខែមេសា អំពីជ័យជម្នះ។ សារនេះធ្វើឡើងដោយ ខៀវ សំផន នៅថ្ងៃទី២១ ខែមេសា ដោយ ខៀវ សំផន"។

[០៩:៤១:៣៤]

ការចាក់ផ្សាយនេះមានចំណងជើងដូចតទៅ៖ "សារអបអរសាទរជ័យជម្នះ អបអរសាទររបស់ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា រដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាទៅកាន់អង្គភាពនានានៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងប្រជាជនកម្ពុជាផ្សាយបន្តផ្ទាល់ ឬថតទុក"។ អង់គ្លេសមានលេខ 00166999 *(ស៊ីក)*, ខ្មែរ 0088 -- , បារាំងមានលេខ 00845854 ទៅដល់ 55។

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបញ្ជាក់លេខ ERN ជាភាសាខ្មែរឡើងវិញ។

[០៩:៤២:៣៥]

**លោក ឃីត រេយ៍ន័រ៖**

ខ្មែរ 00846160 លើ 61 ខ្ញុំសូមដកស្រង់សម្ដីដូចតទៅ៖ “នេះជាជ័យជម្នះប្រវត្តិសាស្ត្រ ដ៏អស្ចារ្យបំផុតរបស់ប្រជាជន និងប្រជាជាតិយើង។ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ប្រជាជននិងប្រជាជាតិយើងទាំងមូល ក៏ដូចជាប្រជាជនទូទាំងពិភពលោក និងក្នុងប្រទេសជាមិត្តទាំងអស់ ទាំងជិតទាំងឆ្ងាយ ស្វាគមន៍យ៉ាងកក់ក្ដៅចំពោះមហាជ័យជម្នះនេះ។ ជ័យជម្នះបានបើកផ្លូវដ៏ភ្លឺស្វាង ដ៏ត្រឹមត្រូវបំផុតក្នុងការដឹកនាំប្រជាជនកម្ពុជា និងកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាក្នុងការធ្វើសង្គ្រាមប្រជាជន ដើម្បីវាយខ្មាំងនៅគ្រប់សមរភូមិទាំងផ្នែកយោធា នយោបាយ និងសេដ្ឋកិច្ច និងក្នុងគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអូសទាញប្រជាជនចេញពីតំបន់ដែលខ្មាំងគ្រប់គ្រង ពោលគឺកម្ទេចប្រកបដោយជោគជ័យនូវរាល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្មាំង ការវាយប្រយុទ្ធមិនបង្អង់ដៃ និងធ្វើឱ្យខ្មាំងខ្សោយផ្នែកសេដ្ឋកិច្ច ផ្នែកហិរញ្ញវត្ថុ ផ្នែកនយោបាយ និងផ្នែកយោធា និងម្ហូបអាហារ និងស្រូវ អង្កររហូតដល់ចំណុចមួយដែលវាមិនអាចស្ដារឡើងវិញបាន។ ជាចុងក្រោយខ្មាំងបានងាប់ដោយការឈឺចាប់”។ សូមបញ្ចប់ការដកស្រង់។

[០៩:៥៥:៣០]

ឯកសារមួយទៀតគឺ ឯកសារ E3/22 គឺជាឯកសារដកស្រង់ចេញមកពីឯកសារស្ដីអំពីកុម្មុយនីស្តកម្ពុជា -- របបកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា សរសេរដោយ ស្ទីវ ហេដឌ័រ។ ERN ជាភាសាអង់គ្លេស 00393831, ខ្មែរគឺ 00846160។ ខ្ញុំសូមបញ្ជាក់អ្នកដែលបញ្ចាំងឯកសារនៅខាងក្រោយខ្ញុំនេះគឺថាខ្ញុំមិនប្រាកដទេ លេខខ្មែរ ERN ប្រាកដ -- ទំនងជាខ្មែរ ឯកសារខ្មែរមិនទាន់បានបកប្រែនោះទេ។ ឯកសារនេះមានចំណងជើងថា “របបកម្ពុជាកុម្មុយនីស្តកម្ពុជា” សរសេរដោយ ស្ទីវ ហេដឌ័រ ដែលឯកសារនេះរៀបរាប់អំពីឆ្នាំ៧២ ដល់ឆ្នាំ៧៣។

គាត់លើកឡើងដូចតទៅ “ចុងឆ្នាំ៧២ ដើមឆ្នាំ -- ចុងឆ្នាំ៧០ និងដើមឆ្នាំ៧១ ខ្មាំងគឺមានសភាពគ្រប់គ្រង ហើយបក្សកុម្មុយនីស្តកម្ពុជាចាប់ផ្ដើមក្ដោបក្ដាប់។ នៅពេលនោះ គឺចាប់ផ្ដើមបង្ក្រាបកងកម្លាំងប្រដាប់អាវុធដើម្បីធ្វើការពង្រីកការគ្រប់គ្រង ហើយកងទ័ពវៀតណាមកំពុងតែគ្រប់គ្រងយ៉ាងច្រើន ហើយបានធ្វើការបិតតំបន់ភូមិភាគនានាចេញពីប្រទេស ហើយធ្វើការហាមឃាត់ប្រជាជនមិនឱ្យធ្វើការបំផ្លាស់ទី។ គោលនយោបាយកុម្មុយនីស្តកម្ពុជាត្រូវបានអនុវត្តឡើង។ ប្រជាជននៅតាមជនបទ គឺបានធ្លាក់ចូលនៅក្នុងចលនាកុម្មុយនីស្តនេះ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកកុម្មុយនីស្ត មិន

ថាកម្ពុជា ឬវៀតណាម។ ពួកគេធ្វើការរត់គេចចេញពីបដិវត្តន៍ ហើយពួកគេមិនទទួលបានការគ្រប់គ្រងពីមហាជនដូចនៅវៀតណាមខាងត្បូងនោះឡើយ”។

[០៩:៤៦:៤៧]

ទំព័រមួយទៀតគឺអង់គ្លេស ERN 00393832 គឺមានសរសេរដូចតទៅ “ចំពោះបក្សកុម្មុយនីស្តកម្ពុជា វាកាន់តែមានស្វយ័តខាងនយោបាយ ដាច់ចេញពីបក្សពលកររបស់វៀតណាមនៅក្នុងឆ្នាំ៧១ និង ៧២។ ប្រជាជនភាគច្រើន គឺមិនមាន -- មានការភ័យខ្លាចអំពីបដិវត្តន៍ដែលរក្សាជំហររបស់ខ្លួនតាមការគំរាមកំហែង និងការកាប់សម្លាប់។ នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបណ្តេញកងកម្លាំងវៀតណាមនៅក្នុងឆ្នាំ១៩៧២ និង៧៣ បក្សកុម្មុយនីស្តកម្ពុជាបានជំនួសសមាជិករបស់ខ្លួន ហើយកាន់តែមានការបង្ខិតបង្ខំឡើង ដើម្បីឱ្យសមាជិករបស់ខ្លួនគោរពតាមមាគ៌ារបស់ខ្លួន។ បក្សកុម្មុយនីស្តកម្ពុជាកាន់តែមានភាពហិង្សា និងមានការបង្ក្រាបកាន់តែខ្លាំងឡើង ក្រោយពីឆ្នាំ១៩៧៣។ នៅពេលដែលខ្លួនបានពង្រឹងគោលនយោបាយរបស់ខ្លួន ដោយបង្កើតសហករណ៍កសិកម្មនៅតាមភូមិភាគដែលខ្លួនក្តោបក្តាប់ ហើយកាត់បន្ថយការគោរពសាសនា ដាក់កាន់តែតឹងភាព ដាក់លើការហាមឃាត់កាន់តែតឹងរឹងទៅលើការដើរហើររបស់ប្រជាជន និងធ្វើការប្រមូលប្រជាជនដើម្បីវាយទីក្រុងភ្នំពេញ”។ ខ្ញុំសូមដកស្រង់បន្តទៀត៖ “បក្សកុម្មុយនីស្តកម្ពុជាមិនដែលទទួលបានចំនួនប្រជាជនភាគច្រើននោះទេ ជាពិសេសដោយសារពួកគេមិនចាប់អារម្មណ៍។ ការបង្ខំ ការគំរាមកំហែង គឺជាការទាក់ទាញ និងការគាំទ្រកាន់តែច្រើនឡើង ហើយធ្វើយ៉ាងណា ដើម្បីឱ្យប្រជាជនចូលជាមួយនឹងបដិវត្តន៍របស់ពួកគេ”។

[០៩:៤៨:៥១]

ឯកសារមួយទៀតគឺ E3/597។ ឯកសារដកស្រង់ចេញពីកាសែតឡឺម៉ុងដ៍ ចំណងជើងថា “ការសម្ភាសជាមួយនឹងជនបដិវត្តកម្ពុជា”។ បារាំងលេខ ERN គឺ 00722245 រហូតទៅដល់ 46, ខ្មែរគឺ 00744036, អង់គ្លេស 00003963 ទៅដល់ 64។ ការដកស្រង់មានសរសេរដូចតទៅ អត្ថបទនេះចាប់ផ្តើមដោយរៀបរាប់ថា “នៅក្នុងទីក្រុងប៉េកាំង អ្នកឆ្លើយតបរបស់យើងបានជួបជាមួយនឹង អៀង សារី ដែលជាមេដឹកនាំប្រវត្តិសាស្ត្រមួយរូបរបស់បដិវត្តន៍កម្ពុជា។ គាត់គឺបានចូលលាក់ខ្លួន ហើយគាត់មកទីក្រុងប៉េកាំងលើកដំបូងជាមួយនឹងអ្នកកាសែតបរទេស ដើម្បីរៀបរាប់អំពីការវិវត្តន៍នៅក្នុងប្រទេសរបស់គាត់”។

ឯកសារនេះចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦។ អៀង សារី ត្រូវបានគេសួរថា តើលោករៀបចំ

អំណាចប្រជាជនដោយរបៀបណា? អៀង សារី បានឆ្លើយដូចតទៅ "នៅក្នុងតំបន់រំដោះដ៏ធំធេង យើងបានអនុវត្តនូវកម្មវិធីរបស់រណសិរ្សរួបរួមជាតិកម្ពុជា។ កម្មវិធីនេះផ្អែកលើគោលការណ៍ដែលថាប្រជាជនគឺជាប្រភពរាល់អំណាចទាំងឡាយ។ អាជ្ញាធររដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ចាប់តាំងពីថ្នាក់ភូមិ ឃុំ ស្រុក រហូតដល់ថ្នាក់ខេត្ត គណៈកម្មាធិការនានាអនុវត្តមុខងាររដូចជាក្បាលម៉ាស៊ីនរដ្ឋដូច្នេះដែរ។ គណៈកម្មាធិការនីមួយៗមានសមាជិក៣, ៥ ឬ ៧រូប អាស្រ័យទៅលើទំហំនៃតួនាទីរបស់អង្គភាពរដ្ឋបាលនោះ។ សមាជិកនីមួយៗបំពេញនូវមុខងារមួយ ឬច្រើនជាកំណត់ មុខងារនយោបាយ យោធា សន្តិសុខ កិច្ចការសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច។ល។"

[០៩:៥១:០៩]

ហើយនៅខាងក្រោមនេះបន្តិចត្រង់ខ្មែរលេខ 00744039, អង់គ្លេសមានលេខ 00003964, បារាំងមានលេខ 00722246, សរសេរដូចតទៅ "ដូច្នេះកងកម្លាំងប្រជាជនរបស់យើងបានប្រមូលផ្តុំគ្នាយ៉ាងឆាប់រហ័ស ហើយរីកចម្រើនលើគ្រប់វិស័យ ព្រមទាំងបែងចែកជាកម្លាំងបីសំខាន់ៗ។ អង្គភាពកងទាហានជំនួស កម្លាំងតំបន់ និងកម្លាំងប្រចាំការ កងកម្លាំងទាំងអស់នោះស្ថិតនៅក្រោមបញ្ជារបស់គណៈកម្មាធិការយោធាជាតិក្រោមការជួយអន្តរាគមន៍ពីអគ្គសេនាធិការមួយ។ នៅថ្នាក់តំបន់នីមួយៗមានគណៈយោធាមួយ និងអគ្គសេនាធិការថ្នាក់តំបន់មួយ"។

ឯកសារមួយទៀតគឺ E3/37 គឺកំណត់ហេតុនៃសំណួរចម្លើយដែលបានស្តាប់ដោយចៅក្រមស៊ើបអង្កេតជាមួយនឹងលោក ខៀវ សំផន ចុះថ្ងៃ១៤ ខែធ្នូ ឆ្នាំ២០០៧។ ចំណុចដកស្រង់ដែលខ្ញុំយោងនៅក្នុងពេលនេះគឺត្រង់លេខសម្គាល់អង់គ្លេស ERN គឺ 00156756, ខ្មែរគឺ 00156677 រហូតដល់លេខ 78, បារាំងគឺ 00156684។ ចៅក្រមបានសួរ ខៀវ សំផន, ចៅក្រម ម៉ាកសែល ឡឺម៉ុងដ៍, ចៅក្រមស៊ើបអង្កេតបានសួរលោក ខៀវ សំផន ដូចតទៅ ខ្ញុំសូមដកស្រង់សម្តី "តើលោកយល់ស្របទៅលើខ្លឹមសារនៃសុន្ទរកថាដែលលោកបានថ្លែងនោះដែរឬទេ? ហើយប្រសិនបើលោកមិនយល់ស្របទៅលើខ្លឹមសារសុន្ទរកថានោះ តើលោកអាចលើកជាឧទាហរណ៍អំពីការខ្វែង -- ការមិនយល់ស្របរបស់លោកត្រង់ចំណុចណា?" ចម្លើយឆ្លើយនាពេលនោះគឺដូចតទៅ៖ "ជារួមមកគឺថាខ្ញុំឯកភាពលើខ្លឹមសារនៃសុន្ទរកថានោះ"។

[០៩:៥៣:៤៩]

ឯកសារបន្ទាប់មួយទៀតគឺ E3/637 គឺសុន្ទរកថាថ្លែងដោយ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម

នៅក្នុងខែមករា ឆ្នាំ១៩៧៣។ ឯកសារនេះលើកឡើងអំពីព្រឹត្តិការណ៍ខែកញ្ញា ឆ្នាំ៧២។ ឯកសារនេះមានលេខ ERN 007409 -- សូមអធ្យាស្រ័យ គឺខ្ញុំលើកឡើង ERN សាជាថ្មី 00740931, លេខ ERN ជាភាសាខ្មែរ 00442333 ជាភាសាខ្មែរ, បារាំងមានលេខ 00752174។ ឯកសារនេះគឺឯកសារ E3/637 ឯកសារមានចំណងជើងថា "សេចក្តីថ្លែងការណ៍ដោយ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម"។

នៅក្នុងសុន្ទរកថានេះត្រង់អង់គ្លេស 00740938, ខ្មែរ 00442332 រហូតទៅដល់ 33, បារាំងមានលេខ 00752174 គឺមានការដកស្រង់សម្តីដូចតទៅ "ជារួមមកនៅពាក់កណ្តាលឆ្នាំ៧៣ ប្រជាជនកងកម្លាំងរំដោះប្រជាជនកម្ពុជា និងប្រជាជនយើងបានទទួលជ័យជំនះដ៏មហាអស្ចារ្យ។ យើងបានកម្ទេចខ្មាំង១០,២៤៥នាក់ ហើយបានរំដោះប្រជាជនយើងជាច្រើន"។ ភ្ជាប់ជាមួយនឹងរបាយការណ៍ខែមករា គឺមានរបាយការណ៍ពិសេសមួយទៀត គឺយើងឃើញនៅមានទំព័រ ក្របដំបូងនៃរបាយការណ៍នេះ។ អង់គ្លេស ERN គឺ 00740939, បារាំងមានលេខ 00752175, ខ្មែរមានលេខ 00442333។ របាយការណ៍ពិសេសមានចំណងជើងដូច្នេះថា ខ្ញុំសូមដកស្រង់ "របាយការណ៍ពិសេស។ ខ្ញុំអមដំណើរឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ធ្វើទស្សនកិច្ចខេត្តព្រះវិហារ កំពង់ធំ និងខេត្តសៀមរាប"។ បញ្ចប់ការដកស្រង់។

[០៩:៥៦:៥៨]

ឯកសារនេះគឺចាប់ផ្តើមដោយពាក្យសរសេរពាក្យដូចតទៅ៖ "ចាប់ពីថ្ងៃ២៥ ខែវិច្ឆិកា ឆ្នាំ៧២ រហូតដល់ថ្ងៃ១៥ ខែធ្នូ ឆ្នាំ៧២ ខ្ញុំបានអមដំណើរលោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ទៅទស្សនកិច្ចខេត្តព្រះវិហារ ខេត្តកំពង់ធំ និងខេត្តសៀមរាប"។

ហើយនៅក្នុងខ្លឹមសារនៃរបាយការណ៍ពិសេសដដែល អង់គ្លេស 00740943, ខ្មែរមានលេខ 00422336 រហូតទៅដល់ 37, បារាំង 00752178។ ការសរសេរដូចខាងក្រោម ដែលក្នុងនោះនិយាយអំពីទស្សនកិច្ចរបស់លោក ខៀវ សំផន នៅតំបន់ទាំងនោះ។ ខ្ញុំសូមដកស្រង់ "ប្រជាជនរបស់យើងដឹងច្បាស់ណាស់ អ្នកណាជាខ្មាំង អ្នកណាជាមិត្ត ហើយពួកគេចងកំហឹងជាមួយនឹងខ្មាំងយ៉ាងខ្លាំង។ គ្រប់កន្លែងដែលយើងទៅ ប្រជាជនរួមទាំងនារី បុរស ក្មេង និងមនុស្សចាស់ស្វាគមន៍យើង ស្វាគមន៍ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន យ៉ាងកក់ក្តៅ និងសប្បាយរីករាយ។ មុនពេលចាកចេញទៅកន្លែងផ្សេងប្រជាជនបានមកចាប់ដៃឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ដោយក្តីនឹករឭក ហើយសូមឲ្យឧបនាយករដ្ឋមន្ត្រីមកទស្សនកិច្ចម្តងទៀត។ ឧបនាយករដ្ឋមន្ត្រីគឺបាន -- គឺប្រជាជនបានជូនពរឲ្យ

ឧបនាយករដ្ឋមន្ត្រី និងកងទ័ពបដិវត្តន៍ទទួលបានកម្លាំងនិងជោគជ័យ"។

[០៩:៥៩:១០]

លោកប្រធាននៅពេលនេះ ខ្ញុំសូមចូលទៅដល់ឯកសារមួយទៀតគឺសៀវភៅដែលសរសេរដោយ ប៉ែន យៀរនិន "ថាតើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា?" ឯកសារនេះគឺមានលេខសម្គាល់ E3/1815។ ហើយប្រាំមួយចំណុចទៀតដែលខ្ញុំដកស្រង់ចេញមកពីសៀវភៅតែមួយនេះទេ។ ខ្ញុំសូមចាប់ផ្ដើម ដោយលើកឡើងឯកសារ E3/1815, អង់គ្លេស ERN គឺ 00487488, ខ្មែរគឺ 00104868។ ខ្ញុំសូមពន្យល់លោកចៅក្រម ឡាវែន៍ ហើយនិងភាគីដែលស្ដាប់ជាភាសាបារាំង។ គឺមានការបកប្រែត្រង់ផ្នែកខ្លះតែប៉ុណ្ណោះជាភាសាបារាំងចេញពីសៀវភៅនេះ។ ក៏ប៉ុន្តែមិនបានបកប្រែទៅលើកការដកស្រង់ដែលខ្ញុំនឹងអានក្នុងពេលបន្តិចទៀតនោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យអ្នកបកប្រែនោះ បកប្រែផ្ទាល់តែម្ដងជាភាសាបារាំង ហើយឯកសារដែលបង្ហាញលើអេក្រង់ជាភាសាខ្មែរ ហើយខ្ញុំនឹងអានជាភាសាអង់គ្លេស។

ឯកសារដកស្រង់ដំបូងនេះមានចំណងជើងថា "បដិវត្តន៍ប្រជាធិបតេយ្យ ១៩៧៣ ដល់១៩៧៥" ហើយនៅខាងក្រោមនេះដាក់ចំណងជើងថា "សត្រូវវណ្ណៈ" ការសរសេរដូចខាងក្រោម៖

[១០:០០:៥៧]

ខ្ញុំសូមដកស្រង់៖ "នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ នៅពេលដែលការទម្លាក់គ្រាប់បែករបស់អាមេរិកបានឈានដល់កម្រិតកំពូលនោះ ក្រុមអ្នកដឹកនាំមជ្ឈិមរបស់បក្សកុម្មុយនីស្ដកម្ពុជាបានដាក់ចេញនូវកម្មវិធីសហករណ៍ភាវូបនីយកម្ម ដែលដំបូងឡើយគេចាត់តាំងជាក្រុមមាន ១០, ២០ ឬក៏៣០ គ្រួសារ។ ការចាត់តាំងបែបនេះបានកើតរួចជាស្រេចទៅហើយនៅក្នុងតំបន់ជាច្រើន តែឥឡូវនេះដីក៏ត្រូវគេដាក់ជាសម្ហូភាព ហើយផលិតផលដែលជាពលកម្មរបស់កសិករ ក៏ត្រូវអាជ្ញាធររឹបអូសយកដែរ។ នៅក្នុងករណីខ្លះទៀត គេក៏បានអនុវត្តផងដែរនូវវិន័យដែលទាក់ទងទៅនឹងការបំផ្លាញសាសនា និងជីវភាពគ្រួសារ និងការបង្ខំឲ្យហូបរួម។ ប្រការទាំងនេះត្រូវគេហៅថា ជាបដិវត្តន៍ប្រជាធិបតេយ្យ"។

ចំណុចយោងនេះ គឺក៏មានសរសេរនៅក្នុងទង់បដិវត្តលើកឯកសារ E3/5 ចុះថ្ងៃ០៨ ខែសីហា ឆ្នាំ៧៥។ បន្ទាប់មកលោក ប៉ែន យៀរនិន បានយោងទៅលើកិច្ចសម្ភាសន៍ធ្វើឡើងដោយលោក ស្ទីវ ហេដឌ័រ ជាមួយនឹងសមាជិកបក្សកុម្មុយនីស្ដកម្ពុជានៅថ្ងៃទី១១-១២ ខែមីនា ១៩៨០។ សូម -- នៅសម្រង់នៃឯកសារលើ E3/1815 ដដែល។ ឯកសារនិយាយៗទៅទង់បដិវត្ត ឯកសារទង់បដិវត្ត។ ពាក្យពេចន៍នៅក្នុងឯកសារកុម្មុយនីស្ដកម្ពុជា គឺថាយើងត្រូវកសាងសង្គមមួយដែលស្អាតស្អំ។ ចំណុចនេះត្រូវ

បានពន្យល់នៅក្នុងទង់បដិវត្តដែលនិយាយអំពីទង់បដិវត្តផ្ទៃក្នុង ហើយឯកសារនេះក៏និយាយអំពីស្ថានភាពមុនឆ្នាំ១៩៧៣។ សូមដកស្រង់៖ “ឲ្យមានការរីកចម្រើននៅត្រង់មួយ ហើយនិងចំណុចមួយទៀតក៏រីកចម្រើនជារួមផងដែរ”។

[១០:០៣:៣៥]

ពីឯកសារ E3/1815 ដដែលនេះនិយាយពីខេត្តក្រចេះនៅឆ្នាំ៧៣។ ERN ជាភាសាអង់គ្លេស 00487489, ខ្មែរ 00104869។ អ្នកនិពន្ធនេះយោងទៅលើឯកសារថ្ងៃទី០៣ ខែឧសភា ៧៣ ពាក់ព័ន្ធទៅនឹងខេត្តក្រចេះដែលលើកឡើងដូចតទៅ សូមដកស្រង់៖ “រហូមកដល់ឆ្នាំ១៩៧៣ (គឺយោងឯកសារ E3/1815) ទីក្រុងក្រចេះអាចបង្ហាញនូវបញ្ហាដូចពីសង្គមចាស់អ៊ីចឹង។ ម៉ូតូហុងដារត់ចុះឡើងៗដូចពីមុនអ៊ីចឹង។ ចំណែកឯរបស់យើងដើរនឹងដី។ ពួកគេចែកជូនរបស់នានាជូនប្រជាជនភាគច្រើន គឺសម្ភារៈជំនួញ។ ប្រសិនបើយើងដើរតាមផ្លូវហ្នឹងទៀត យើងនឹងគ្មានផ្លូវដើរទេ។ ដូច្នេះក្រុមអ្នកដឹកនាំមជ្ឈិមបក្សត្រូវតែធានាថារដ្ឋគ្រប់គ្រងអ្វីៗទាំងអស់។ ក្រចេះត្រូវបានគេជម្លៀស ពុំមានការជួញដូរ ជួលព័ទ្ធ ដូរកម្លាំងពលកម្ម ឬក៏ទិញលក់ជាលុយអ្វីទៀតទេ។ រដ្ឋបានលក់ផ្តាច់មុខនូវអង្ករ អំបិល ប្រេងឥន្ធនៈកំណាត់ និងប្រេងសាំង។ បើគ្មានសាំង ម្ចាស់រថយន្ត កាណូត និងត្រាក់ទ័រឯកជន គឺថាមុខជាលែងមានទៀតហើយ។ រដ្ឋរបស់បក្សកុម្មុយនីស្តបានកាន់កាប់សម្ភារៈរបស់គេ”។

[១០:០៥:៥៦]

សម្រង់បន្ទាប់មកនៅលើឯកសារដដែល ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅខេត្តកំពង់ចាមនៅក្នុងឆ្នាំ១៩៧៣។ ក្រោមចំណងជើងថា “ភូមិភាគឧត្តរ”។ ERN ជាភាសាអង់គ្លេស 00487491, ខ្មែរ 00104870។ អ្នកនិពន្ធបានលើកឡើងថា “ក្រោយពីការបញ្ចប់ការទម្លាក់គ្រាប់បែកនៅខែសីហា ៧៣ កងទ័ពមកពីតំបន់៣១ -- ខ្ញុំសូមបញ្ជាក់ថាទាហានម្នាក់ថា ម៉ុំ ឡុន គាត់ជាអនុប្រធានឃុំនៅស្រុក បាទ តំបន់៣១ ខេ.អាយ.អាយ.អិន.ដី។ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ៧៣ ទាហានមកពីតំបន់៣១ បានត្រឡប់មកកាន់អង្គភាពរបស់គាត់នៅខេត្តកំពង់ធំ ដើម្បីចង់ដឹងថានៅពេលដែលពួកគេនៅសៀមរាប គឺថាការធ្វើចលនាប្រជាជនឲ្យទៅជនបទបែរជាបានលទ្ធផលផ្ទុយទៅវិញ។ នៅពេលនោះកសិករ៥០.០០០នាក់បានរត់ទៅកាន់ទីក្រុងកំពង់ធំ។ (បាទនេះគឺជាសម្រង់សម្តីចេញពីកងទ័ពនោះផ្ទាល់តែម្តង) ពេលនោះបានដំណាលថា ជនបទស្ងាត់ជ្រងំគ្មានមនុស្សរស់នៅទេ”។ បញ្ចប់ការដកស្រង់។ ទាហានគាត់រំឭកឡើងថាគាត់ចងចាំ។

[១០:០៧:៥៧]

ដូច្នេះរឿងនេះមិនមែនបណ្តាលមកពីការទម្លាក់គ្រាប់របស់អាមេរិក ដែលបានបញ្ចប់ទៅហើយនោះទេ ឬក៏មកពីការដើរឃាមល្បាតដ៏ខ្លាំងរបស់កងទ័ព លន់ នល់ ដែលនៅបន្តឡើងនោះទេ។ គឺបណ្តាលផលដែលមកពីមេបញ្ជាយុទ្ធភូមិភាគរបស់បក្សឈ្មោះ កែ ពក។ ប្រហែលជាមកពីអំពើប្រពន្ធរបស់ ប៉ុល ពត, ខៀវ ប៉ុណ្ណារី។ ទាហាននេះឈ្មោះ ម៉ុំ ឡុន ដដែលដែលគាត់បាននិយាយ សូមបន្ត "នៅក្នុងតំបន់កំពង់ធំ អង្គការត្រូវបានដឹកនាំដោយមនុស្សតឹងរ៉ឹង វិន័យអាក្រក់ មានការសម្លាប់ជាច្រើន រូបពុទ្ធបដិមាត្រូវគេបំផ្លាញ វត្តអារាមលែងឲ្យមាន... យុទ្ធជនត្រូវគេបង្ខំឲ្យធ្វើការជាទម្ងន់ ជាពិសេសនៅគឺពេលដែលគេរៀបចំ និងកសាងភូមិឡើងវិញ។ អង្គការមិនអនុញ្ញាតឲ្យមានការសាងសង់ផ្ទះ ដូចជាបុគ្គល ជាផ្ទះឯកជននោះទេ។ មានជំរំសម្រាប់នារី កុមារ យុវនារី និងយុទ្ធជន។ ពួកគេហូបរួម របបមានតែរបបគ្មានសាច់។ កុមារត្រូវគេហាមមិនឲ្យគោរពឪពុកម្តាយ។ ព្រះសង្ឃមិនឲ្យសូត្រធម៌ ហើយប្តីមិនឲ្យរស់នៅជាមួយប្រពន្ធទេ"។ បាទ សម្រង់នេះគឺដកស្រង់ចេញពីអំពីសៀវភៅ -- ខ្ញុំសូមអធ្យាស្រ័យពីអ្នកនិពន្ធមួយ ដេប្រុក។ សូមអត់ទោសព្រោះខ្ញុំអានបារាំងមិនច្បាស់ ពីឆ្នាំ១៩៧៦។

[១០:០៩:៥៧]

ខ្ញុំបន្តទៅលើឯកសារ E3/1815 និយាយអំពីព្រឹត្តិការណ៍ឆ្នាំ១៩៧៣ នៅភូមិភាគឧត្តរដដែល "នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៣ កងទ័ពតំបន់៣១ របស់បក្សកុម្មុនីស្តកម្ពុជាបានដណ្តើកាន់កាប់ក្រុងកំពង់ចាម ហើយជ្រៀតចូលចម្ងាយ១០០ម៉ែត្រពីបរិវេណលំនៅដ្ឋានរបស់ចៅហ្វាយខេត្ត។ នៅពេលដែលគេដកថយទៅវិញ គេនាំយកប្រជាជន១៥.០០០នាក់ឲ្យទៅរស់នៅជនបទជាមួយនឹងពួកគេ"។

បាទសេចក្តីថ្លែងនេះគឺយោងទៅ គឺយោងលេខយោងជើងទំព័រ៣១៨ និយាយអំពី យីស៊ីងហ្គ័រ និចសុន ហើយនិងការបំផ្លិចបំផ្លាញប្រទេសកម្ពុជាសរសេរនៅក្នុងឆ្នាំ១៩៧៩។

ទាក់ទងទៅហ្នឹងព្រឹត្តិការណ៍នៅភូមិភាគឧត្តរដដែល ហើយស្ថិតនៅក្នុងអំឡុងពេលឆ្នាំ១៩៧៣ដដែល, ទៅអង់គ្លេស 00487493, ខ្មែរ 00104871។ បាទមានសម្រង់ពីជាសំណេររបស់លោក ប៉ែន យៀវនិន ដូចតទៅ ខ្ញុំសូមដកស្រង់៖ "ការកែប្រែ ក៏មានការការកែប្រែច្រើនដែរនៅសៀមរាប។ លាវកែវមុនី ឥស្សរៈជើងចាស់មកពីហាណូយ ដែលអប់រំនៅហាណូយ ហើយដែលទទួលខុសត្រូវស្រុកស្រីស្នំនៅឆ្នាំ១៩៧០នោះ បានស្លាប់។ តាមស្មានប្រហែលទៅ គឺដោយសារមូលហេតុធម្មជាតិនៅក្នុងឆ្នាំ៧២។ ជនវ័យក្មេងម្នាក់ជាងគាត់...។ មុនពេលមរណភាពរបស់ មុនី ពួកកុម្មុយនីស្តទាំងនោះបាន

អនុវត្តការសម្លាប់ជាលើកដំបូងទៅលើទាហាន លន់ នល់ ដែលគេធ្លាប់ចាប់បានម្តងមកហើយ ហើយដែលទៅចូលកងទ័ព លន់ នល់ វិញ។ ពួកកុម្មុយនីស្តបានផ្តើមដុតផ្ទះ ហើយប្រមូលប្រជាជនទាំងបង្ខំឲ្យទៅនៅឆ្ងាយពីខ្សែត្រៀមជួរមុខ។ ប៉ុន្តែបើតាមអតីតចៅហ្វាយស្រុករបស់ លន់ នល់ គឺយោងសម្តីរបស់មនុស្សម្នាក់ឈ្មោះ ឈៀង ណាំយាង -- ឈៀង ណាំយាម គឺថា ប៉ែន យៀវនិន បានសម្លាសមនុស្សម្នាក់នៅថ្ងៃទី១១ តុលា ៧៩។ យោងទៅតាមចៅហ្វាយស្រុក លន់ នល់ នៅតំបន់នោះដែលបាននិយាយនៅក្នុងឆ្នាំ១៩៧៩ ថា គេកម្រសម្លាប់ប្រជាជនស៊ីវិលណាស់កាលនោះ។ ការស្លាប់របស់លោកមុនី គឺថាគឺនៅក្នុងឆ្នាំ៧៣ មានការកាប់សម្លាប់ទ្រង់ទ្រាយធំទៅលើគ្រប់ទ័ព លន់ នល់ ដែលគេចាប់បាននិងទៅលើពួកសេនាជន ព្រមទាំងពួកឈ្មួញផងដែរ”។ ចៅហ្វាយស្រុកនេះបានរាយការណ៍ដូចតទៅនេះ “នេះគឺឈ្មោះ ឈៀង ណាំយាង ត្រូវបានគេពួកកុម្មុយនីស្ត ពេលនោះបានផ្តើមជម្លៀសប្រជាជនចេញពីភូមិ ព្រមទាំងជាមួយនឹងសត្វចិញ្ចឹមផង និងធ្វើឯកសារតាមដានរាល់ម្នាក់ៗ។ ពួកគេត្រូវបង្ខំឲ្យធ្វើការ”។

[១០:១៤:១៥]

បាទឥឡូវខ្ញុំសុំចូលទៅភូមិភាគនិរតីម្តង គឺនៅត្រង់ឯកសារ E3/1815 ដដែល។ *អ៊ីងគ្លីស* ERN 00487495, ខ្មែរ 00104873 ដល់ 74។ បាទត្រង់នេះលោក ប៉ែន យៀវនិន សរសេរអំពីភូមិភាគនិរតី។ សូមដកស្រង់ “តែនៅក្នុងភូមិនិរតីឯនោះទេ ដែលមានការពង្រឹងខាងផ្នែកបដិវត្តន៍។ នៅក្នុងឆ្នាំ១៩៧៣ គឺជាឆ្នាំដែល ម៉ុក, ធុច រិន ដែលមានសម្ព័ន្ធភាពយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមអ្នកដឹកនាំមជ្ឈិម ហើយកសាងអត្តិភាពរបស់ខ្លួនលើ ប្រសិទ្ធិ, ជូ ជេត និងសហាសេវិកនិយមកណ្តាលដទៃទៀត។ រួចកម្ចាត់ទាំងស្រុងនូវខ្មែរអប់រំនៅហាណូយឲ្យអស់ពីភូមិភាគ។ អ្នករងគ្រោះថ្នាក់មានតួនាទីខ្ពស់ម្នាក់គឺឈ្មោះ សង្ហា ហឿន ដែលជាឥស្សរៈជើងចាស់ និងជាសមាជិកម្នាក់របស់គណៈកម្មាធិការភូមិភាគ”។ ក្នុងនាមជាអតីតលោកសង្ឃម្នាក់នៅក្នុងខេត្តកំពង់ស្ពឺ ឈ្មោះ ឈួន សម្បត្តិ ដែលសម្ភាសដោយ ប៉ែន យៀវនិន នៅស្រុកគងពិសី នៅក្នុងឆ្នាំ១៩៨០។ ក្នុងនាមគាត់ជាអតីតមកពីកំពង់ស្ពឺតំបន់៣២ ដែលបានចូលជាមួយកុម្មុយនីស្តនៅក្នុងឆ្នាំ១៩៧០។

[១០:១៦:២៨]

បាទ នេះសម្រង់មកពីសម្តីរបស់គាត់ “នៅក្នុងឆ្នាំ៧១, ៧២ បដិវត្តន៍ល្អ ប្រជាជនគ្មានការព្រួយបារម្ភអ្វីទាំងអស់។ សង្ហា ហឿន ស្និទ្ធស្នាលជាមួយវៀតណាម ហើយមិនដែលមានរឿងរ៉ាវអ្វីជាមួយ

គេទេ។ ហើយប្រជាជនចូលចិត្ត សង្ហា ហឿន ច្រើនណាស់ ពីព្រោះគាត់រៀបចំឲ្យមានការសម្ដែងល្ខោន ដែលមានភ្លេងប្រពៃណីជាតិ។ រួចក៏ទាហាន លន់ នល់ និងបញ្ញាជនជាច្រើនដែលចេញពីភ្នំពេញមកកាន់តំបន់រំដោះ និងមកទីរួមខេត្តដើម្បីចូលរួមបដិវត្តន៍។ សង្ហា ហឿន និង ជូ ជេត បានអប់រំ និងបង្រៀនអ្នកទាំងនោះ។ ខ្ញុំបានឃើញផ្ទាល់ភ្នែក គេពុំសម្លាប់អ្នកទាំងនោះទេ ប៉ុន្តែ ម៉ុក ពិតជាបានសម្លាប់អ្នកទាំងនោះ ហើយគាត់ខឹងនឹងអំពើដែលអ្នកទាំងពីរនាក់នោះបានធ្វើ។ មានទំនាស់អំណាចនឹងគ្នា។

[១០:១៧:៤១]

នៅក្នុងឆ្នាំ១៩៧៣ មានការសម្លាប់ចាប់ផ្ដើមឡើង។ ដំបូងមានការផ្លាស់ប្ដូរកម្មាភិបាលស្រុក និងតំបន់។ ក្រោយមក ជូ ជេត និងកូនចៅរបស់គាត់បានប្រយុទ្ធជាមួយនឹងកូនចៅរបស់ ម៉ុក នៅក្នុងការប្រមូលផ្ដុំភូមិភាគ និងតំបន់ នៅក្នុងឃុំរបស់ខ្ញុំ ដែលខ្ញុំជាអ្នករៀបចំការប្រជុំនោះ។ ការប្រយុទ្ធគ្នានោះផ្ទុះឡើងដោយសាររឿងនយោបាយ និងទ្រឹស្ដីនៅកណ្ដាលពេលប្រជុំ។ ក្រោយមក ជូ ជេត បានចេញទៅទិសខាងលិច ដើម្បីពិភាក្សាអំពីបញ្ហានៃការសម្លាប់ទាហាន លន់ នល់។

អោគ ឆាយ ក៏ទៅជាមួយគាត់។ គេប្រាប់ខ្ញុំថា គាត់ត្រូវគេផ្លាស់ទៅកោះកុង។ ២សប្ដាហ៍ក្រោយមក សង្ហា ហឿន ត្រូវទ័ពរបស់ ម៉ុក ចាប់ខ្លួន។ ដំបូង គេយកគាត់ទៅក្នុងភូមិរបស់ខ្ញុំ១យប់ និង១ថ្ងៃ ដោយមានការឃាមកាមយ៉ាងហ្មត់ចត់ ក្រោយមកទៅមន្ទីររបស់ភូមិភាគ។ រថយន្តក្រុង៥គ្រឿងបានមកដឹកកូនចៅរបស់គាត់ទៅកំពង់ឆ្នាំង"។

[១០:១៩:១២]

បាទ ចំណុចនេះទាក់ទងទៅនឹងសំណេររបស់ ប៉ែន យៀរនិន ដែលសម្ភាសទៅលើបុគ្គលនេះ បន្ទាប់មកគាត់សរសេរបន្តទៅទៀត និយាយអំពី កេណ្ណេត ឃ្វីន។ កេណ្ណេត ឃ្វីន ជាជនជាតិអាមេរិកាំង។ នេះយោងទៅលើការបោះពុម្ពផ្សេងរបស់គាត់នៅត្រង់ហ្វូតណូតលេខ 335 យោងទៅលើការសម្ភាសជាមួយ ឃ្វីន និយាយអំពីការកែប្រែផ្នែកនយោបាយយ៉ាងច្រើន។ បដិវត្តន៍ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាដែលបានត្រូវបានបោះពុម្ពផ្សេងនៅក្នុងសង្គ្រាមជើងទឹក នៅក្នុងឆ្នាំ១៩៨៦។

លោក យៀរនិន បានបន្តទៅទៀតដូចតទៅ សូមសកស្រង់៖ "កេណ្ណេត ឃ្វីន រាយការណ៍នៅក្នុងឆ្នាំ១៩៧៣ ថា ជូ ជេត អំណាច ជូ ជេត ត្រូវបានថយចុះ ព្រោះតែគាត់ស្និទ្ធនឹងវៀតណាមខាងជើង និងមានគោលជំហរគាំទ្រ សីហនុ ហើយត្រូវទទួលរងរបួសដោយកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជានៅចុងខែវិច្ឆិកា នៅពេលដែលគាត់ធ្វើដំណើរជាមួយនឹងកងទ័ពវៀតណាមខាងជើងខ្លះនៅតាមផ្លូវជាតិ តាម

ផ្លូវលេខ១៦"។

[១០:២០:៥៥]

បាទ ឃ្លាបន្ទាប់លោក ប៉ែន យៀវនិន ដែលបានយកមកយោងនោះគឺកិច្ចសម្ភាសជាមួយឈ្មោះ នូ មោក ដែលបានផ្តល់សក្ខីកម្មកាលពីសប្តាហ៍មុន។ បាទ ជាកិច្ចសម្ភាសដែលយើងបានឮហើយ។ សូម ដកស្រង់សម្រង់របស់លោក ប៉ែន យៀវនិន៖ "ក្រោយពីគាត់ទៅដល់ខេត្តកំពង់ឆ្នាំង ជូ ជេត គឺបន្ត និយាយអំពីការសាមគ្គីជាមួយនឹងវៀតណាមនៅក្នុងកិច្ចប្រជុំនយោបាយមួយ"។

លោក យៀវនិន ក្រោយមកបាននិយាយថា "សមាជិកយុវកកម្នាក់នៅស្រុកកំពង់ត្រឡាចបាន និយាយថា-- បាទជាកិច្ចសម្ភាសន៍របស់បុគ្គលហ្នឹងជាមួយនឹងឈ្មោះ ចុង កាល-- នៅ ចុង កាល នៅ ក្នុងស្រុកកំពង់ត្រឡាចលើ ដែលថាដោយសារតែ ជូ ជេត ជាបញ្ញវន្ត គាត់តែងតែមានទំនាស់ជាប្រចាំ ជាមួយពួកព្រៃដូចជា តាម៉ុក ជាដើម។ លើសពីនេះទៅទៀត ថ្វីបើគាត់មានបទពិសោធន៍ផ្ទាល់ខ្លួននៅ ក្នុងកណ្តាប់ដៃ សីហនុ ក្នុងទសវត្សរ៍ទី៦០ក៏ដោយ ជេត និងជនដទៃទៀតដូចជា ភោគ ឆាយ និង កុយ ធួន ជាដើម បានសរសើរចំពោះការអំពាវនាវរបស់ សីហនុ ទោះបីជាគាត់យល់ថា សីហនុ ជាអ្នកដឹកនាំ មានតែឈ្មោះក៏ដោយចុះ។ សមាជិកយុវកកនោះក៏និយាយថា ប្រជាជនជឿ សីហនុ ជាងបដិវត្តន៍ មាន បញ្ហាកើនឡើងនៅពេលដែលបក្សបានផ្តើមទិតៀនសម្តេចជាចំហ ហើយការឆ្លើយតបរបស់ ម៉ុក គឺត្រូវ ប្រើកម្លាំងបង្កើនអំណាចរបស់គាត់"។

[១០:២៣:០៩]

ហើយសូមដកស្រង់បន្តទៅទៀត "ម៉ុក ជាមនុស្សឃោរឃៅណាស់តាំងតែពីឆ្នាំ១៩៧១ ដល់ ៧២ មកម្ល៉េះមិនដូច ជូ ជេត និង ភោគ ឆាយ ទេ។ ម៉ុក គឺជាមនុស្សសាហាវ ជាឃាតករ។ ការសម្លាប់ បានចាប់ផ្តើមនៅឆ្នាំ១៩៧៣ នៅពេលដែលមានការទម្លាក់គ្រាប់បែក ហើយឈ្លើយសឹកខ្លះត្រូវគេសម្លាប់ ហើយខ្លះទៀតត្រូវគេយកទៅដាក់ក្នុងគុក ក្នុងមណ្ឌលអប់រំ។ ឆ្នាំ១៩៧៣ ជាឆ្នាំដែលអាមេរិកផ្តើម ទម្លាក់គ្រាប់បែកក្នុងតំបន់នោះ ដោយប្រើយន្តហោះបេ៥២។ ដូច្នេះគេត្រូវតែប្រយុទ្ធតបវិញយ៉ាងខ្លាំង ក្លា។ ការកាប់សម្លាប់មនុស្សនោះៗគឺស្របទៅនឹងការបន្តឹងវិន័យ នេះគេហៅថាការពង្រឹងបដិវត្តន៍ប្រជា ធិបតេយ្យ។ គ្មានអ្នកណាមួយហ៊ានប្រឆាំងនឹងការផ្លាស់ប្តូរនោះទេ។ ខ្ញុំដឹងច្បាស់ណាស់ពីមិត្តភក្តិដែល ធ្វើការជាមួយ ម៉ុក គឺគាត់ហ្នឹងហើយជាអ្នកបញ្ជាឲ្យសម្លាប់។ ការសម្លាប់នេះគឺប្រព្រឹត្តទៅនៅក្នុងព្រៃ។ ម៉ុក មានអំណាច តែគាត់មិនយល់ពីនយោបាយច្រើនឡើយ។ ភោគ ឆាយ បង្រៀនគាត់ តែ ម៉ុក មាន

ទំនាស់រវាងការតស៊ូក្នុងព្រៃ ដូចជាអ្នកតស៊ូក្នុងព្រៃដូច តាម៉ុក ជាដើម និងអ្នកតស៊ូក្នុងទីក្រុង ដូចជា ភោគ ឆាយ ជាដើមដែលទើបតែបានមកដល់ក្នុងឆ្នាំ១៩៧០"។ បាទឯកសារទាំងអស់នេះយោងទៅលើការកិច្ចសម្ភាសន៍នៅជើងកាល។

[១០:២៥:០៨]

បាទ នៅក្នុងភូមិភាគនិរតីដដែលគឺអង់គ្លេស 00487497។ បាទ នេះគឺជាសំណេររបស់លោក ប៉ែន យៀរនិន និយាយអំពី កេណ្ណេត ឃ្វីន នេះដដែល។ ខ្ញុំនិយាយអំពីឈ្មោះ កេណ្ណេត ឃ្វីន នេះម្តងរួចមកហើយ។ ខ្ញុំយោងទៅលើឯកសារមួយទៀតដែល កេណ្ណេត ឃ្វីន បានលើកឡើងគឺឯកសារនេះមានចំណងជើងថា "កម្មវិធីរបស់ខ្មែរក្រហម ដើម្បីបង្កើតសង្គមកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា"។

នេះគឺជាសារទូរលេខមកពីសហរដ្ឋអាមេរិក មកពី។ខាងទូតទៅក្រសួងការបរទេសនៅក្នុងឆ្នាំ១៩៧៤។ កេណ្ណេត ឃ្វីន ដែលតាមដានភូមិភាគនិរតីនោះដែលនិយាយថា ការបោះឆ្នោតនៅថ្នាក់តំបន់លែងមានតទៅទៀតហើយ។ នៅក្នុងតំបន់ដែលគេរឹបអូសបានថ្មីៗពីពួក លន់ នល់ នៅឆ្នាំ៧៣។ គាត់និយាយថា មេភូមិ និងមេឃុំត្រូវបានចាត់តាំងដោយគណៈកម្មាធិការស្រុករបស់បក្សកុម្មុយនីស្តកម្ពុជា។ ពីធីបុណ្យព្រះពុទ្ធសាសនាត្រូវគេបន្ថយឲ្យនៅមានត្រឹមតែពីរដងក្នុងមួយឆ្នាំ។

នៅក្នុងខេត្តកំពតក្នុងខែកក្កដា គេបញ្ជាការឲ្យវត្តនីមួយៗឲ្យប្រគល់ព្រះសង្ឃ១០អង្គ ដើម្បីឲ្យសឹកមកធ្វើជាទ័ពថ្មើរជើងដើម្បីបំពេញសាច់ទ័ព។ ក្រោយមកនៅក្នុងខេត្តតាកែវ និង ខេត្តកំពតតំបន់ ១៣ និង ៣៥ ព្រះសង្ឃទាំងអស់ត្រូវបានគេកែនបញ្ចូលទ័ព ទុកតែមួយអង្គ -- ទុកតែមួយវត្ត ៤អង្គទេ។ ហើយនៅពេលជាមួយនេះដែលដូចជានៅតាមមូលដ្ឋាន ដូចជាអង្គតាសោម និងកំពង់ត្រាចជាដើម ត្រូវបានគេជម្លៀសប្រជាជនចេញ។ ហើយនៅតាមទីជនបទការតាំងលំនៅទ្រង់ទ្រាយធំមួយត្រូវបានគេអនុវត្តឡើង។ ប្រជាជន២០.០០០នាក់ត្រូវបានគេជម្លៀសចេញពីភូមិរបស់ខ្លួន ចេញពីភូមិចំនួនពីរ បាទ ស្រុកតែពីរទេ មកពីខេត្តកំពត"។

[១០:២៨:២៤]

លោក កេណ្ណេត ឃ្វីន បន្តថា "នៅកន្លែងខ្លះនៃខេត្តតាកែវ និងខេត្តកំពតពួកកុម្មុយនីស្តខ្មែរបានយកកម្មាភិបាលថ្មីមួយចំនួនធំដាក់ឲ្យអនុវត្តកម្មវិធីនោះ ដោយពួកគេបាត់បង់ជំនឿលើកម្មាភិបាលចាស់មួយចំនួនច្រើនដែលគេចាត់ទុកថាស្និទ្ធនឹងវៀតណាមខាងជើង ឬក៏មិនម៉ឺងម៉ាត់ក្នុងការអនុវត្ត"។ បញ្ចប់ការដកស្រង់។

ការបះបោរតែងកើតមានឡើងដល់កំពូល ឃ្វីន គាត់បានលើកឡើងថា "មានព្រឹត្តិការណ៍បីកើតឡើងនៅក្នុងខេត្តកំពត នៅតំបន់៣៥ ដោយមានប្រតិកម្មពី កងទ័ពដែលជាចេតនារបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដើម្បីបង្ខំប្រជាជនឱ្យតាំងទីលំនៅ នៅកន្លែងផ្សេងហើយនិងរឹបអូសយកស្រូវអង្ករបស់ពួកគេ"។

យោងសម្ដីរបស់ ឃ្វីន ដដែល ERN ជាភាសាអង់គ្លេស 00487499។ អស់គ្លេសសូមអានឡើងវិញ 00487499 "នៅដើមឆ្នាំ៧៤ នៅពេលដែលកងទ័ពខ្មែរក្រហមចូលទៅដល់ដំណាក់កាលឃោរឃៅនៅក្នុងការឃោសនារបស់គេ គឺថាវិន័យទាំងអស់ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង ដោយមានការសម្លាប់ទៅលើអ្នកណាដែលមិនអនុវត្តតាមមាគ៌ានយោបាយ ដោយមិនមានចិត្តអាឡោះអាល័យ ឬក៏មេត្តាអ្វីនោះឡើយ"។

[១០:៣០:៥៥]

លោក ប៉ែន យៀវនិន ក្រោយមកបន្តមកទៀតដោយគាត់សម្ភាសជាមួយនឹងឈ្មោះ តាន់ ហាវ គាត់សម្ភាសនៅក្នុង -- គាត់សម្ភាសនៅខែកញ្ញា ឆ្នាំ៧៩។ ឥឡូវនេះនិយាយអំពីខេត្តកោះកុងវិញម្ដងកិច្ចសម្ភាសន៍ជាមួយនឹង តាន់ ហាវ។ នៅក្នុងខេត្តកោះកុងជនជាតិចិន ស្ត្រីម្នាក់ឈ្មោះ តាន់ ហាវ ដែលរស់នៅទីនោះ រំឭកឡើងរ៉ាវដែលបានកើតឡើង ដែលគាត់ហៅថាខ្មែរក្រហមសេរី "នៅចុងឆ្នាំ១៩៧៣ គេបានប្រាប់ឱ្យប្រជាជនវៀតណាមត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ហើយយើងលែងឃើញមានវៀត-ណាមរស់នៅទីនោះទៀតហើយ។ នៅក្នុងខែតុលា ឬវិច្ឆិកា កម្មាភិបាលដែលជាបដិវត្តន៍ ដែលជាជនជាតិចិនក៏បានបាត់ខ្លួនដែរ ហើយកងទ័ពដែលមានសញ្ជាតិជាចិនហ្នឹងត្រូវបានរំលាយចោល មានតែកងទ័ពដែលជាជនជាតិខ្មែរទេ។

[១០:៣២:១២]

នៅក្នុងឆ្នាំ៧៤ គឺពេលវេលាដ៏តឹងតែងចាប់ផ្ដើមហើយ ថ្នាក់តំបន់ និងថ្នាក់ភូមិភាគ កងទ័ពទាំងនោះមកពីតំបន់កំពង់សិលាបានមកដល់កោះកុង។ ក្នុងនោះមានកងទ័ពយុទ្ធនារីជាច្រើន ប្រាថា ក៏ត្រូវបានចាប់ខ្លួនយកទៅបាត់ទៅ។ គេនិយាយថាគាត់ គេយកគាត់ទៅអប់រំរៀនសូត្រ ប៉ុន្តែផ្ទុយទៅវិញគេយកទៅសម្លាប់ទេ។ ម្នាក់ៗនៅក្នុងខេត្តកោះកុងមានការភ័យខ្លាចយ៉ាងខ្លាំង ដោយសារគេយកមេរបស់ខ្លួនទៅបាត់ទៅហើយ។ ប្រសិទ្ធិ បានបាត់ខ្លួនក្នុងពេលដំណាលគ្នានេះដែរ។ បញ្ហាកាន់តែលំបាកឡើងៗហើយ ខ្មែរក្រហមចាប់ផ្ដើមសម្លាប់ប្រជាជន។ ប្រជាជនដែលមិនបានធ្វើអ្វីខុសសោះ ក៏ត្រូវគេចាប់ខ្លួន

យកទៅបាញ់សម្លាប់ចោល។ នៅឆ្នាំ៧៤ គេជ្រើសរើសយុវជនដែលមានអាយុពី១៦ឆ្នាំឡើងទៅ។ អ្នកណាបដិសេធមិនចូលធ្វើកងទ័ពត្រូវបានគេសម្លាប់ចោល"។

[១០:៣៣:២៣]

ចំណុចដកស្រង់មួយទៀតគឺ នៅពេលនោះនេះយើងនិយាយអំពីលោក យៀវនិន ដែលសរសេរអំពីភូមិភាគបូព៌ា។ ERN ជាភាសាអង់គ្លេសគឺ 00487506, ខ្មែរ 00104880 ដល់ 81។ "មកដល់ពាក់កណ្តាលឆ្នាំ៧៤ ភូមិភាគបូព៌ាបានចាប់ផ្តើមបង្ហាញនូវគំរូមួយចំនួន ដែលយើងឃើញមាននៅទីកន្លែងផ្សេងទៀតជាច្រើនឆ្នាំមកហើយ។ នៅក្នុងខែសីហា ឆ្នាំ៧១ គឺកម្មាភិបាលបណ្តុះបណ្តាលនៅហាណូយ ៧១នាក់ ត្រូវបានគេប្រមូលផ្តុំទៅអប់រំនៅតំបន់២១ នៅកំពង់ចាម ក្នុងនោះមានម្នាក់ ហែម សាវិន -- ហែម សាមិន"។ ដែលក្នុងនេះគឺយោងទៅលើការសម្ភាសលោក យៀវនិន ដោយលោក យៀវនិន ធ្វើឡើងជាមួយ ហែម សាមិន នេះនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ៨១។ ក្នុងនោះ ហែម សាមិន បានលើកឡើងថា "ខ្លួនត្រូវបានឧទ្ទេសនាមដោយ ភួង លេខាតំបន់ ចាន់។ គាត់ឧទ្ទេសនាមពីការតស៊ូ ហើយគាត់ត្រូវប្រាប់ថា យើងត្រូវតែនៅកន្លែងណាដែលយើងត្រូវនៅ ដើម្បីឲ្យយើងខ្លួនទីពឹងខ្លួនបាន។ រហូតដល់អង្គការមានដំណោះស្រាយមួយដែលគេអាចឲ្យយើងត្រឡប់ទៅធ្វើការវិញ។

[១០:៣៥:១៧]

ក្រោយភ្លាមមក អ្នកទោស១០នាក់ត្រូវបាន តាមគេលើកឡើងនោះ គឺថាត្រូវបានគេយកទៅកន្លែងផ្សេង។ ៦១នាក់ផ្សេងទៀត រួមទាំង សាមិន ត្រូវបានគេឲ្យធ្វើការនៅក្នុងស្រែដោយការត្រួតពិនិត្យយ៉ាងហ្មត់ចត់។ ពួកគេមានសិទ្ធិដើរហើរខ្លះ ក៏ប៉ុន្តែបើតាមសម្តីរបស់ ហឿង នោះគឺថាគេមិនមានបំណងបដិសេធតួនាទីអនាគតរបស់ពួកគេទេ។ ផ្ទុយទៅវិញ មានតែសហសេវិករបស់គេប្រាំមួយនាក់ប៉ុណ្ណោះដែលនៅរស់នៅក្នុងភូមិភាគនិរតី។ អ្នកដទៃរាប់រយនាក់ទៀត ត្រូវបានគេសម្លាប់ចោលតាំងពីឆ្នាំ១៩៧១មកម្ល៉េះ"។

ឃ្លាចុងក្រោយដែលខ្ញុំអាននេះ គឺចេញមកពីប្រភពដែលលោក យៀវនិន សម្ភាសជាមួយនឹងខ្មែរហាណូយម្នាក់ក្នុងចំណោមប្រាំមួយនាក់។ គាត់ឈ្មោះ សុខ ខែម។ កិច្ចសម្ភាសន៍នេះធ្វើឡើងនៅកំពតថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៨០។ លោក យៀវនិន បានធ្វើការសន្និដ្ឋាននៅក្នុងភូមិភាគបូព៌ាដូចតទៅ។ អង់គ្លេសមានលេខ 00487510, ខ្មែរគឺទំនងត្រង់ទំព័រ 00104881។ ប៉ុន្តែខ្ញុំមិនច្បាស់ថាលេខ ERN នេះឬក៏លេខ ERN ណានោះឡើយ។ លោក យៀវនិន បានសរសេរដូចតទៅ៖ "ការជម្លៀសទីក្រុង

ដូចជាក្រចេះ កំពង់ត្រាច អង្គតាសោម និងកំពង់ក្ដីនៅក្នុងឆ្នាំ១៩៧៣ មិនមែនជាវិធានការចម្លែកនៅក្នុងពេលដែលមានការទម្លាក់គ្រប់បែកនោះទេ។ វាក៏បានផ្ដល់ជាយុទ្ធសាស្ត្រសម្រាប់បក្សកុម្មុយនីស្តកម្ពុជាដើម្បីធ្វើការទាញប្រយោជន៍ពីស្ថានភាពនេះ និងប្រមូលប្រជាជនដើម្បីសង្គ្រាមកុម្មុយនីស្ត ក្នុងគោលបំណងបញ្ចប់ឲ្យមានការទម្លាក់គ្រប់បែក។ យើងឃើញថាបដិវត្តន៍នេះកើតចេញពីការ គឺរបបមូលធននិយម និងសង្គ្រាមរបស់អាមេរិក។--

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៨នាទី ដល់ម៉ោង ១១:០១នាទី)*

[១១:០១:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបន្តឯកសារចុងក្រោយរបស់លោក ប៉ែន ឃៀវនិន ដែលសរសេរដែលមានចំណងជើងថា "ប៉ុល ពត កាន់អំណាចដោយរបៀបណា?" អង់គ្លេស ERN គឺ 00487504, ខ្មែរ 0010487។ ផ្នែកនេះគឺលោក ឃៀវនិន បានសរសេររៀបរាប់ដូចតទៅនៅក្នុងសៀវភៅរបស់គាត់។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ៧៤ ខួបលើកទី៤ កងទ័ពរួបរួមរបស់និរតី និងឧត្តរ ដឹកនាំដោយ កែ ពក និង ម៉ុក នោះបានត្រួតត្រារាជធានីចាស់ឧដុង្គ ចម្ងាយប្រមាន៣០គីឡូម៉ែត្រខាងជើងទីក្រុងភ្នំពេញ។

ហើយនិងនៅព្រំប្រទល់ភូមិភាគទាំងពីរ។ ពីរបីខែខែក្រោយមក ដូណាល់ ឃើគ ជាអ្នកកាសែត។ អ្នកកាសែតរូបនេះ បានសរសេរអំពីសង្គ្រាមកាន់តែរីកធំឡើង បោះពុម្ពនៅទីក្រុងញូវយ៉កឆ្នាំ៧១។ ហើយក៏លើកឡើងនៅក្នុងសៀវភៅស្តីអំពី ខ្មែរក្រហម និងភេរវករ ដែលកើតមានឡើងក្នុងសម័យនោះ។ ពីរបីខែក្រោយមក ដូណាល់ ឃើគ បានសង្កេតមើលអំពីផលវិបាកនៃជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជានោះ ដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លទ្ធិរាជានិយម និងសាធារណរដ្ឋខ្មែរផងដែរ។ ដកស្រង់សម្តី៖ "ខ្មែរក្រហមពិតជាធ្វើការប្រឹងប្រែងដោយចេតនា មិនត្រឹមតែដើម្បីកាន់កាប់ប៉ុស្តិ៍ជួរមុខនានារបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ គឺថែមទាំងបំផ្លាញនូវសំណង់អរិយធម៌ តែដាក់ហាក់ដូចជាចុះអន់ថយហើយគ្មានចាក់ -- គ្មានទាក់ទងអ្វីសោះ។ ដូច្នេះហើយខ្មែរក្រហម ក្រោយពីដណ្តើមយកឧដុង្គបានមកបាននាំប្រជាជនប្រហែល២០.០០០នាក់ទៅកាន់ព្រៃជិតនោះ។ ហើយបានសម្លាប់គ្រូបង្រៀន បុគ្គលិករដ្ឋការ បំផ្លាញទីប្រជុំជននោះចោលទាំងស្រុង ដោយដុតផ្ទះ ឬក៏រុះទម្លាក់។

[១១:០៤:៤២]

លេខយោង១ជើងទំព័រ៣៧៧ ក្នុងសៀវភៅរបស់លោក ដូណាល់ ឃើគ។ ក្នុងចំណុចបន្ទាប់នៅក្នុងលេខជើងទំព័រ៣២៨ -- បានសូមអធ្យាស្រ័យ លេខយោងទំព័រ៣៧៨ទេ របស់លោក ដូណាល់ ឃើគ។ ក្នុងនោះ លោក ឃៀរនិន លេខយោង៣៧៨ លោក ប៊ែន ឃៀរនិន បានសម្ភាសជាលោក ទឹម នៅឧដុង្គ ថ្ងៃ១៨ ខែកញ្ញា ឆ្នាំ១៩៨០។ "កសិករនៅភូមិវាំងចាស់ ដែលធ្លាប់ដឹងពីសកម្មភាពរបស់ពួកខ្មែរក្រហមតាំងពីឆ្នាំ១៩៦៧ និងធ្លាប់មានសមានចិត្តចំពោះទស្សនៈប្រឆាំងនឹងរាជានិយម។ ពួកគេនោះបានចូលរួមក្នុងការជម្លៀសប្រជាជនចេញនោះដែរ។ នៅក្នុងឆ្នាំ១៩៨០ កសិករ នោះបានដំណាលថាប្រជាជន៤០.០០០នាក់ត្រូវបានបញ្ជូនទៅគ្រប់ទិស ខ្មែរក្រហមដុតផ្ទះ សម្បែង នៅគ្រប់ទីកន្លែង។ យើងត្រូវធ្វើដំណើរសំដៅទិសខាងលិច ទៅកាន់តំបន់៣១ ខេត្តកំពង់ឆ្នាំង ហើយត្រូវគេបញ្ជូនបន្តទៅទៀត។ ទាហាន លន់ នល់ ដែលស្លៀកពាក់ជាឯកសណ្ឋានត្រូវគេសម្លាប់នៅតាមផ្លូវ។គេបំបែកប្រជាជនជាក្រុមៗ ក្នុងមួយក្រុមមាន៥០នាក់ ២០០នាក់ ឬក៏៣០០នាក់ ហើយត្រូវពួកខ្មែរក្រហមតាមជាប់។ អ្នកដែលត្រូវបានគេបញ្ជូនទៅតំបន់៣១ រួចបន្តទៅពោធិ៍សាត់ រួចទៅបាត់ដំបងទៀត។ ៥ឆ្នាំក្រោយមក ក្នុងចំណោមមនុស្សប្រាំនាក់ មានសល់តែម្នាក់ទេដែលនៅរស់ត្រឡប់មកស្រុកវិញ"។

[១១:០៥:៥៣]

លោក ឃៀរនិន បានសរសេរបន្តទៀតថា "កម្មាភិបាលថ្នាក់ឃុំម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា

នៅកន្លែងនោះបានបញ្ជាក់ថា (នេះសំដៅទៅលើ នួ ម៉ៅ ឬក៏ នួ មោក ដែលបានឆ្លើយកាលពីសប្តាហ៍មុន) បញ្ជាឲ្យជម្លៀសប្រជាជនពីទីប្រជុំនោះ គឺចេញដោយ ម៉ុក ផ្ទាល់"។ គាត់និយាយថា គេលើកយកហេតុផលថាឲ្យអ្នកទាំងនោះ ទៅធ្វើស្រែនៅមូលដ្ឋាន ទៅតំបន់គ្រុនចាញ់ ហើយដែលខ្វះស្បៀងអាហារ។ បន្ទាប់មក លោក យៀវនិន បានសរសេររៀបរាប់ដូចតទៅថា "ឧដុង្គគឺជាប្រផ្នូលអាក្រក់ដ៏តូចមួយសម្រាប់ប្រជាជននៅទីក្រុងភ្នំពេញ"។ បន្ទាប់មក លោក ប៊ែន យៀវនិន យោងទៅលើសំដៅរបស់លោក នួ មោក និយាយថា "ជូ ជេត នៅកំពតក្នុងពេលដែលជម្លៀសឧដុង្គ"។ ហើយលោក យៀវនិន ក៏យោងទៅលើសម្តីរបស់ នួ មោក ដែលគាត់សរសេរដូចតទៅ៖ "កម្មាភិបាលដដែលនេះក៏បានរាយការណ៍ផងដែរថា មេបញ្ជាបក្សកុម្មុយនីស្តកម្ពុជាបានប្រាប់គាត់នៅក្នុងឆ្នាំ១៩៧៤ ថា ហ៊ូ នឹម បានជំទាស់នឹងការជម្លៀសក្រុងនៅពេលនោះ។ ក៏ប៉ុន្តែ យន់ និង ជេត ប្រាប់យើងថា នៅពេលនោះ គឺគាត់មិនចង់មានការជម្លៀសនោះទេ ម៉ុក គាត់បានលើកឡើងអំពីអ្នកដែលគាំទ្រការជម្លៀសទីក្រុងភ្នំពេញ"។ ចំណុចនេះ មាននៅលេខយោង៣៨២ ដែលជាការសម្ភាសន៍ជាមួយនឹងលោក នួ មោក។

[១១:០៩:១៧]

យៀវនិន បានសរសេរបន្តទៀតថា "អនុលេខាបក្សតំបន់៣៧ នាពេលនោះ" ខ្ញុំសូមបញ្ជាក់ត្រង់នេះថា គឺជាកិច្ចសម្ភាសន៍រវាង ស្ទីវ ហេដឌ័រ ជាមួយនឹងបុរសរូបនេះ។ កិច្ចសម្ភាសន៍នេះ ធ្វើឡើងថ្ងៃ១១ - ១២ ខែមីនា ឆ្នាំ៨០។ អនុលេខាបក្សតំបន់៣៧ នាពេលនោះ បាននិយាយប្រាប់អ្នកធ្វើសម្ភាសម្នាក់នាពេលក្រោយមកថា សូមដកស្រង់៖ "បើយើងដណ្តើមបានទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៤ ក៏មុខជាមានការជម្លៀសប្រជាជនដែរ នេះជាផែនការយូរណាស់មកហើយ។ មានពាក្យស្លោកមួយឃ្លាលើកឡើងថា រំដោះប្រជាជនចេញពីខ្មាំង"។

ចំណុចបន្ទាប់ទៀតលោកប្រធាន ខ្ញុំសូមចូលទៅដល់ឯកសារលេខ E3/167។ លេខយោងឯកសារនេះនិយាយអំពីការបំលាស់ទីរបស់ ខៀវ សំផន និង អៀង សារី ដែលគាត់បានធ្វើដំណើរទៅចិន អឺរ៉ុប និងអាហ្វ្រិក។ ឯកសារ E3/167, អង់គ្លេស ERN គឺ 00280571, បារាំងមានលេខ 00000106, ខ្មែរមានលេខ 00596117 ជាការផ្សព្វផ្សាយរបស់រណសិរ្សរួបរួមកម្ពុជាចុះផ្សាយដោយអត្ថបទ-- *អធិខល នូវើល ឌុយកាំបូដស៍*។ ទំព័រដំបូងនេះគឺបានលើកឡើងអំពីចំណុចដូចដែលខ្ញុំនឹងអាន។

[១១:១២:០៣]

ឯកសារនេះសរសេររៀបរាប់អំពីទស្សនកិច្ចរបស់លោក ខៀវ សំផន និង អៀង សារី ទៅ

ប្រទេសកូរ៉េខាងជើង។ ខ្ញុំសូមចូលលេខយោងអង់គ្លេស 00280584, ខ្មែរ 00596138 ហើយខ្ញុំគិតថា បារាំងគឺ S00000120 ដល់ 21។ នៅត្រង់ផ្នែកមួយរបាយការណ៍នេះ គឺបានលើកឡើងអំពីសុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី ខៀវ សំផន។ អត្ថបទនេះគឺបានលើកឡើងថា “នៅក្នុងពិធីលៀងសាយភោជដែលរៀបចំឡើងនៅថ្ងៃទី០៥ ខែមេសា នៅសាលសភា នៅម៉ាន់ស៊ុយដេ ដោយគណៈកម្មាធិការប្រជាជនមជ្ឈិម និងទីប្រឹក្សានៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ដែលក្នុងនេះលើកឡើងអំពីលោក ខៀវ សំផន ថ្លែងនៅសុន្ទរកថាដូចតទៅ៖--” នេះគឺវាពាក់ព័ន្ធទៅនឹងហេតុការណ៍ពីអាទិត្យក្រោយពីឧដុង្គកើតឡើង។ អង់គ្លេស ERN គឺ 00280586, បារាំងគឺមានលេខ S00000122, ខ្មែរមានលេខ 00596141។ នេះគឺជាការដកស្រង់សម្ដីផ្ទាល់ចេញពីសុន្ទរកថារបស់លោក ខៀវ សំផន។ ខ្ញុំសូមដកស្រង់៖

[១១:១៣:៥៨]

“ផ្ទុយទៅវិញកងទ័ពប្រជាជនរំដោះជាតិកម្ពុជា បានធ្វើការវាយខ្មាំងយ៉ាងខ្លាំងក្លា ហើយឥឡូវថែមទាំងបានឈរជើងយ៉ាងរឹងមាំនៅទ្វារចូលទីក្រុងភ្នំពេញផង។ ភ្នំពេញខ្លួនឯងដែលជាជម្រកចុងក្រោយរបស់ពួកក្បត់បានក្លាយទៅជាសមរភូមិប្រយុទ្ធដ៏ក្ដៅគគុកមួយក្រោមសម្ពាធដែលកាន់តែខ្លាំងក្លាឡើងៗពីសំណាក់កងទ័ពប្រជាជនរំដោះជាតិកម្ពុជានៃយើង។ នៅថ្ងៃទី១៨ ខែមីនា កន្លងទៅនេះកងទ័ពប្រជាជនរំដោះប្រជាជនកម្ពុជារបស់យើងបានរំដោះទីក្រុងមួយទៀតគឺ ទីក្រុងឧដុង្គ ដោយកម្ទេចចោលឲ្យអស់នូវកងទ័ពអាយ៉ងទាំងអស់ដែលនៅទីនោះ ហើយនិងកម្លាំងជំនួយពួកវា។ ពោលគឺមានន័យថាខ្មែរចំនួនជាង ៥០០០នាក់ត្រូវបានកម្ទេច”។

[១១:១៥:០៧]

ឯកសារបន្ទាប់ គឺខ្ញុំសូមលើកឡើងចំណុចចាប់ផ្ដើមនៃទស្សនកិច្ចដំបូងប្រទេសកូរ៉េខាងជើងគឺជាប្រទេសមួយដែល ខៀវ សំផន និងអៀង សារី បានធ្វើទស្សនកិច្ចគឺនៅចុងខែមីនា ឆ្នាំ៧៤។ ខ្ញុំសូមលើកឯកសារមួយទៀតគឺ E3/1238, អង់គ្លេស ERN គឺ00278739, ខ្មែរលេខ 00702017 ហើយបារាំង មានS00000021។ ឯកសារនេះគឺជាការចេញផ្សាយរបស់ ហ្សុង ចុះផ្សាយនៅកាសែត “នូវែលឌុយ កាំបូដស៍”, សរសេរចំណងជើងថា: អំណរសាទររបស់សម្ដេចព្រះប្រមុខរដ្ឋ នរោត្ដម សីហនុ ជូនចំពោះលោក ខៀវ សំផន, ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ៧៤។ ក្នុងនេះមានសរសេរថា អបអរសាទររបស់សម្ដេចព្រះប្រមុខរដ្ឋ នរោត្ដម សីហនុ ជូនចំពោះលោក ខៀវ សំផន ដែលធ្វើទស្សនកិច្ចផ្លូវការនៅ

ប្រទេសវៀតណាម។ ហើយផ្នែកដែលពាក់ព័ន្ធ ធ្វើឡើង និងថ្លែងឡើងដោយសម្ដេច សីហនុ នៅថ្ងៃទី ២៧ ខែមីនា។ ខ្ញុំសូមដកស្រង់សម្ដីរបស់ព្រះអង្គ៖

"ខ្ញុំមានសេចក្ដីសោមនស្សរីករាយក្រៃលែងដោយបានដឹងថាលោកបានអញ្ជើញមកដល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដ៏រុងរឿង ជាបងប្អូន ប្រកបដោយសុខភាពល្អ ហើយក៏សូមប្រសិទ្ធិពរជ័យជូនឯកឧត្ដម អៀង សារី, ឯកឧត្ដម ខៀវ ធីរិទ្ធ និងឯកឧត្ដម ទីវ អុល សូមប្រកបដោយជោគជ័យក្នុងបេសកកម្មបម្រើជាតិមាតុភូមិរបស់ឯកឧត្ដម។ ដំណើរទស្សនកិច្ចដែលអស់លោក លោកស្រីបានបំពេញ ហើយនិងដែលត្រូវបំពេញនៅប្រទេសវៀតណាម ប្រទេសចិន និងនៅប្រទេសកូរ៉េ ជាមិត្តមានតម្លៃជាប្រវត្តិសាស្ត្រ និងផលប្រយោជន៍វិជ្ជមានដល់ការបន្តប្រយុទ្ធប្រឆាំងរបស់ប្រជាជនខ្មែរ"។

បន្ទាប់មក យើងមើលនៅក្នុងឯកសារដដែលត្រង់លេខ ERN00278740, ខ្មែរ 00702019, បារាំង S00000022 ក្នុងនេះគឺនិយាយអំពីការសំណេះសំណាលរវាង ទ្រង់ និង ហ្វុង ជាមួយនឹងវៀតណាម។ កិច្ចសំណេះសំណាលនេះធ្វើឡើងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ៧៤ នៅវិមានរបស់ប្រទេសវៀតណាម ជាមួយនឹងគណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិ និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជាជាមួយនឹងប្រតិភូនៃរណសិរ្សប្រជាជាតិវៀតណាមនិងរដ្ឋាភិបាលនៃសាធាណរដ្ឋប្រជាធិបតេយ្យវៀតណាម។

[១១:១៨:១២]

ឯកសារមួយទៀតគឺ ឯកសារ E3/1242, ឯកសារខាងមុខ គឺចុះថ្ងៃទី១ ខែមេសា ៧៤ គឺកិច្ចលាគ្នារបស់ហ្វុង របស់ប្រតិភូហ្វុងនៅវៀតណាម។

នៅទំព័រខាងមុខបានលើកឡើងថា មានពិធីរៀបចំសម្រាប់ពិធីលាគ្នានៅថ្ងៃទី៣១ ខែមីនា ដែលនាពេលនោះជាពិធីរៀបចំពិធីលាគ្នាក្រោយពីទស្សនកិច្ចនៅប្រទេសវៀតណាម។

ឯកសារដដែលអង់គ្លេស ERN 00322964, ខ្មែរ 00607959, បារាំងគឺ 00000049 ដល់ 50។ ឯកសារនេះបានបង្ហាញអំពីពិធីចុះហត្ថលេខាលើសេចក្ដីប្រកាសរួម កម្ពុជា-វៀតណាម។ ពិធីចុះហត្ថលេខាលើសេចក្ដីប្រកាសរួមរវាងគណៈប្រតិភូនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងគណៈប្រតិភូនៃគណៈកម្មាធិការមជ្ឈិមនៃរណសិរ្សសម្រាប់មាតុភូមិ និងរាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមធ្វើនៅថ្ងៃទី០២ ខែមេសា ៧៤ ដែលក្នុងនោះមាន ខៀវ សំផន តំណាង។

[១១:១៩:៥៥]

ឯកសារមួយទៀតគឺ E3/113 គឺជាឯកសារចុះផ្សាយហ្វុង ចុះថ្ងៃទី២ ខែមេសា ឆ្នាំ៧៤។ គឺឯកសារនេះចុះនៅក្នុង “នូវែល ឌុយ កាំបូដស៍”, អង់គ្លេស ERN គឺ 00280540, ខ្មែរ S00704558 និងបារាំង 00000066 ដល់ 67។ ត្រង់ចំណុចចុះខែភី(?) មេសា ឆ្នាំ៧៤។ “ក្រុងប៉េកាំងរៀបចំទទួលស្វាគមន៍ដ៏ឱឡារិក និងកក់ក្តៅចំពោះគណៈប្រតិភូនៃហ្វុង និងហ្គ្រុង ក្រោមការដឹកនាំរបស់ ខៀវ សំផន និងគណៈប្រតិភូនៅបានអញ្ជើញទៅដល់ទីក្រុងប៉េកាំងតាមជើងហោះហើរពិសេស ដែលចេញដំណើរមកពីទីក្រុងហាណូយ ដើម្បីបំពេញទស្សនកិច្ចជាមិត្តភាព និងផ្លូវការប្រទេសនៅប្រទេសចិន”។

ហើយយើងឃើញមានមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានទៅព្រលានយន្តហោះ ដើម្បីស្វាគមន៍គណៈប្រតិភូកម្ពុជា។ អង់គ្លេស ERN ឯកសារនេះដដែល សូមលើកឡើងត្រង់ ERN 00280542, ខ្មែរ 00704561 ដល់ 61, បារាំង 00000068, ដែលក្នុងនេះគឺចុះថ្ងៃទី០២ ខែមេសា ឆ្នាំ៧៤ ដែលមានពិធីជប់លៀងធំនៅរដ្ឋធានីទីក្រុងប៉េកាំង។ ក្នុងនោះបានលើកឡើងថា “កាលពីរាត្រីថ្ងៃម្សិលមិញ ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សាកិច្ចការរដ្ឋបានរៀបចំពិធីជប់លៀងដ៏ធំមួយដើម្បីផ្តល់កិត្តិយសដល់គណៈប្រតិភូហ្វុង និងហ្គ្រុង ដែលមានឧបនាយករដ្ឋមន្ត្រី ខៀវ សំផន និងជាប្រធាន លោកទីប្រឹក្សាពិសេស អៀង សារី ជាអនុប្រធាន--

**អ្នកបកប្រែ៖**

លោកប្រធានសូមជួយណែនាំសហព្រះរាជអាជ្ញាឲ្យឃឹតបន្តិច។

[១១:២២:១២]

**លោក ឃីត រេយ៉ន័រ៖**

-- ERN ទំព័រអង់គ្លេសមួយទៀតគឺ 00280543, ខ្មែរគឺ 00704562, បារាំង 00000069។ ឯកសារនេះបង្ហាញចុះថ្ងៃទី០១ ខែមេសា ឆ្នាំ៧៤។ លោក ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សាកិច្ចការរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន បានថ្លែងសុន្ទរកថាក្នុងពិធីជប់លៀង ដែលលោកបានរៀបចំកាលពីថ្ងៃសម្រាប់គណៈប្រតិភូហ្វុង និងហ្គ្រុង។ នេះជាសុន្ទរកថារបស់លោក ជូ អេនឡាយ ដែលធ្វើឡើងនៅក្នុងពិធីជប់លៀងថ្ងៃទី០១ ខែមេសា។ សុន្ទរកថានេះត្រង់លេខ ERN 00280544, ខ្មែរ 00704563 ដល់ 64, បារាំងមានលេខ 00000070។ ជូន អេនឡាយ បានលើកឡើងថ្លែងដូចតទៅ៖ “កងកម្លាំងប្រដាប់អាវុធ ប្រជាជនរំដោះជាតិកម្ពុជាបានទទួលជោគជ័យយ៉ាងខ្លាំងក្លាក្នុងអណ្តាតភ្លើង

សង្គ្រាមដ៏សន្ធោសន្ធៅ ដោយផ្សាភ្ជាប់ទៅនឹងកម្លាំងរបស់មហាជន កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាបានធ្វើការប្រយុទ្ធ ដោយប្រកបវីរភាព ដោយបានធ្វើកម្លាំងរបស់សត្រូវចុះខ្សោយ និងបានរំដោះទឹកដីបានជាង៩០ភាគរយ ព្រមទាំងរំដោះប្រជាជនបានជាង៨០ភាគរយនៃប្រទេសទាំងមូលផងដែរ ទោះបីជាពួកគេជាអ្នកផ្តួចផ្តើមនៅក្នុងសង្គ្រាមនេះក៏ដោយ។ ចាប់តាំងពីរដូវប្រាំងនេះមក កងកម្លាំងរំដោះជាតិប្រជាជនកម្ពុជាបានធ្វើការវាយសម្រុកលើសមរភូមិនានា បានធ្វើការវាយប្រហារទៅលើសត្រូវដែលមានមូលដ្ឋាននៅភ្នំពេញ និងក្នុងតំបន់ដទៃទៀត ហើយទទួលបានជោគជ័យដ៏ត្រចះត្រចង់"។

[១១:២៤:៣១]

នៅក្នុងឯកសារដដែលនេះ ប៉ុន្តែខ្ញុំយោងទៅលើកិច្ចប្រជុំរបស់ ម៉ៅ សេទុង ជាមួយនឹង ខៀវ សំផន និង អៀង សារី នាពេលនោះ។ ERN ជាភាសាអង់គ្លេសគឺ 00280546, ខ្មែរគឺ S00704567 ដល់ 68, បារាំងមានលេខ S00000073។ ឯកសារនេះបញ្ជាក់ប្រធានថា ប្រធានាធិបតី ម៉ៅ សេទុង បានជួបជាមួយគណៈប្រតិភូប្រុ្កុង និងហ្កុង ដឹកនាំដោយខៀវ សំផន និង អៀង សារី នាពេលនោះ។ ហើយ ជូ អេងឡាយ នៅពេលនោះក៏មានវត្តមានក្នុងឱកាសនោះផងដែរ។ ឯកសារមួយទៀត ខ្ញុំយោងលើឯកសារលេខ E3/1254, ទំព័រដំបូងនៃឯកសារនេះត្រង់លេខ ERN00280547, ខ្មែរ S00633740 និងបារាំងមានលេខ S00000080។ ឯកសារនេះបានបង្ហាញថា "នៅថ្ងៃទី០៤ ខែមេសា ៧៤ គណៈប្រតិភូ ហ្កុង និងប្រុ្កុង បានចរចាសំណេះសំណាលជាមួយនឹង ជូ អេងឡាយ ដែលជាឧបនាយករដ្ឋមន្ត្រីនៅពេលនោះ"។

[១១:២៥:៥៥]

ខ្ញុំសូមយោងឯកសារមួយទៀត ចូលដល់ឯកសារ E3/114, អង់គ្លេស ERN គឺ00280564 --

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាតពីអ្នកបកប្រែ ឲ្យលោកសហព្រះរាជអាជ្ញាបញ្ជាក់លេខ ERN ទាំងអស់សាជាថ្មី។

**ប្រធានអង្គជំនុំ៖**

លោកៗតំណាងសហព្រះរាជអាជ្ញាលឿន ហើយសូមបញ្ជាក់ឡើងវិញ។ ទី១ សុំឲ្យយឺត ហើយទី២ សូមបញ្ជាក់លេខ ERN សាឡើងវិញ។ អំមិញនេះ គឺអ្នកបកប្រែ បកប្រែមិនទាន់ទេ។

[១១:២៦:៥២]

**លោក ឃើត រេយ៉ន័រ៖**

ខ្ញុំនឹងធ្វើតាមលោកប្រធាន។ ឯកសារ ERN គឺមានលេខ 00 -- ជាភាសាខ្មែរគឺ 00593609, អង់គ្លេសគឺ 00280564។ ឯកសារលេខ E3/1255 គឺជាការចុះផ្សាយរបស់ ហ្វុង, ចុះនៅក្នុងសារព័ត៌មានចុះនៅក្នុងសារព័ត៌មាន "ទ្រូវែល ឌុយ កាំបូដស៍", នៅត្រង់ទំព័រនេះ យើងមានចំណុចដែលសរសេរបញ្ជាក់ថា មានការពិភាក្សាធ្វើឡើងរវាងគណៈប្រតិភូហ្វុង និងហ្រ្គុង ជាមួយនឹងគណៈប្រតិភូប្រទេសប្រជាធិបតេយ្យកូរ៉េ ចុះថ្ងៃទី០៧ ខែមេសា នៅព្យុងយ៉ាង ហើយនៅខាងកម្ពុជាមានវត្តមាន ខៀវ សំផន និង អៀង សារី ចូលរួមនាពេលនោះ។

ខ្ញុំចូលទៅដល់ឯកសារមួយទៀត គឺឯកសារ E3/115។ បាទសូមអធ្យាស្រ័យ ខ្ញុំសូមលើកឡើងឯកសារមួយទៀតមុននឹងចូលដល់ឯកសារនេះសិន។

ខ្ញុំសូមលើកឡើងឯកសារ E3/167 សិន។ ឯកសារនេះគឺខ្ញុំបានលើកឡើងរួចមកហើយ ពាក់ព័ន្ធនឹងពាក្យដែលថ្លែងដោយលោក ខៀវ សំផន នៅថ្ងៃទី០៥ ខែមេសា នៅក្នុងប្រទេសកូរ៉េខាងជើង។ ដើម្បីបង្ហាញចំណុចនេះឲ្យបានត្រឹមត្រូវគឺខ្ញុំសូមលើកឡើងត្រង់ ERN លេខ 00280590 ខ្មែរគឺ 00596147 ដល់ 48, បារាំងមានលេខ 00000126។

[១១:២៩:២៤]

ក្នុងនេះគឺត្រង់ចំណុចថា ការចាកចេញពីគណៈប្រតិភូរបស់ហ្រ្គុង និងហ្វុង ពីក្រុងព្យុងយ៉ាង ដឹកនាំដោយលោក អៀង សារី និងខៀវ សំផន ចាកចេញពីទីក្រុងព្យុងយ៉ាង នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៤ ដើម្បីធ្វើដំណើរទៅទីក្រុងប៉េកាំង។ អង់គ្លេសគឺមានលេខ 00280591 ឯកសារដដែលទេ ខ្មែរគឺមានលេខ 00596149, បារាំងមានលេខ 00000128 ដល់ 129។ យើងក្នុងនេះ យើងឃើញមានសរសេរបញ្ជាក់ថាមានបានកិច្ចទស្សនៈរបស់គណៈប្រតិភូហ្វុង និងហ្រ្គុង នៅប្រទេសកូរ៉េខាងជើងបានបញ្ចប់ ហើយគណៈប្រតិភូហ្វុង និង ហ្រ្គុង បានធ្វើដំណើរទៅប្រទេសចិន ទីក្រុងប៉េកាំងនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៤។

ឯកសារបន្ទាប់ E3/115, អង់គ្លេស ERN 00280594, ខ្មែរ 00597966, បារាំងមានលេខ 00000148។ យើងមានឃើញមានចំណុចដែលមានសរសេរនៅក្នុងនេះដូចតទៅ៖ "ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាទៅកាន់ទ្វីពអឺរ៉ុប

និងអាហ្វ្រិក។ គណៈប្រតិភូបានធ្វើដំណើរទៅទ្វីបអាប្រិក និងអឺរ៉ុបក្រោមការដឹកនាំរបស់ ខៀវ សំផន ហើយ អៀង សារី បានចាកចេញពីទីក្រុងប៉េកាំងនៅថ្ងៃ១៩ ខែមេសា តាមយន្តហោះពិសេសដើម្បីទៅបណ្តាប្រទេសក្នុងទ្វីពអឺរ៉ុប និងអាហ្វ្រិក។

[១១:៣១:៣៩]

លេខ ERN មួយទៀតគឺ 00280595, ខ្មែរ 00597967, បារាំងមានលេខ 0000149, បានសរសេរថា“គណៈប្រតិភូនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានមកដល់រដ្ឋធានីទីរ៉ាណា ប្រទេសអាល់បានី។ ក្នុងនេះសរសេរថា គណៈប្រតិភូបានធ្វើដំណើរមកដល់នៅថ្ងៃទី២០ ខែមេសា តាមជើងយន្តហោះពិសេសទៅដល់រដ្ឋធានីទីរ៉ាណា តាមការអញ្ជើញរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតអាល់បានី។ គណៈប្រតិភូនៃហ្រ្គុង និងហ្នុង ដឹកនាំដោយលោក ខៀវ សំផន ដែលក្នុងនោះមានលោក អៀង សារី ជាទីប្រឹក្សាពិសេស”។

ខ្ញុំសូមចូលទៅដល់ឯកសារមួយទៀត គឺ E3/3312។ នេះគឺជាឯកសាររបស់ក្រសួងការបរទេសអាមេរិក។ អង់គ្លេស ERN គឺ 00412748, ខ្មែរ 00740848 ដល់ 49, បារាំងមានលេខ 00763784 ដល់ 90។ ក្នុងនេះបានសរសេរថា “ទីឈប់សំចត បន្ទាប់គឺអាល់បានី” ដែលខ្ញុំរៀបរាប់រួចមកហើយ ហើយក៏បានលើកឡើងថាបន្ទាប់មក “ធ្វើដំណើរទៅបែលហ្រ្គេត”។ សូមបញ្ចប់ការដកស្រង់។

[១១:៣៣:៤០]

ឯកសារបន្ទាប់មកមកទៀត គឺ E/3315, អង់គ្លេស ERN គឺ 00412754, ខ្មែរ 00290011, បារាំង 00802337។ យើងឃើញនៅក្នុងនេះបញ្ជាក់ដោយឯកសាររបស់ក្រសួងការបរទេសអាមេរិក ដែលក្នុងនេះសរសេររៀបរាប់ដូចតទៅ៖ “អំឡុងពេលការសួរសុខទុក្ខមួយរបស់ឯកអគ្គរាជទូតនៅក្រសួងការបរទេសស្តីពីបញ្ហាផ្សេងៗ។ អនុរដ្ឋមន្ត្រីការបរទេស នីកូឡេ ហ្គេនៀ បានផ្តល់យោបល់មួយចំនួនស្តីពីទស្សនកិច្ចនៅប្រទេសរ៉ូម៉ានី របស់មេដឹកនាំរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងលោក គឺលោក ខៀវ សំផន”។

ឯកសារមួយទៀតគឺ E3/3318 គឺឯកសាររបស់ក្រសួងការបរទេសអាមេរិក, អង់គ្លេស ERN គឺ 00412773, ខ្មែរ 00790015, បារាំង 00812340 ដែលក្នុងនេះយោងសរសេរថា “អគ្គរាជទូតបារាំងធ្វើដំណើរទៅអាល់ហ្សេរី” ដែលក្នុងដែលក្នុងនោះបានរាយការណ៍អំពីទស្សនកិច្ចរបស់ ខៀវ សំផន។ ហើយទំព័របន្ទាប់ចំណុចទី៥ បានសរសេរថា “បន្ទាប់ពីទស្សនកិច្ចនៅ ញួកចុត នៅក្នុងទ្វីប

អាមេរិក ខៀវ សំផន បានធ្វើដំណើរទៅ យ៉ាន់ដេ ហើយរំពឹងថានឹងធ្វើដំណើរទស្សនកិច្ចទៅទីក្រុងគែរ ដែលស្ថិតនៅក្នុងប្រទេសអេហ្ស៊ីប"។

[១១:៣៥:៥៨]

ឯកសារបន្ទាប់ គឺឯកសារ E3/2939, អង់គ្លេស ERN 00377049, ខ្មែរ 00738340 ដល់ 41, បារាំងមានលេខ 00766874។ គឺសារទូរលេខចេញពីមកស្ថានបេសកកម្មនៅទីក្រុងហុងកុង ផ្ញើជូនទៅដល់ទីក្រុងវ៉ាស៊ីតោន។ លិខិតទំនាក់ទំនងនេះ បានលើកឡើងអំពីទស្សនកិច្ចរបស់លោក ខៀវ សំផន ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ហើយបានលើកឡើងថា នេះគឺជាការជូនដំណឹងអំពីការទស្សនកិច្ចរបស់លោក ខៀវ សំផន ទៅកាន់សាធារណរដ្ឋប្រជាមានិតចិននេះ បានទទួលជោគជ័យ។

ទំព័របន្ទាប់ គឺយើងឃើញមានការរៀបរាប់ពាក្យដូចតទៅ៖ "សេចក្តីថ្លែងការណ៍រួម កាលពីថ្ងៃទី២៧ ខែឧសភា ដែលបានចេញផ្សាយនៅឯចុងបញ្ចប់នៃទស្សនកិច្ចរបស់លោក ខៀវ សំផន មកកាន់សាធារណរដ្ឋប្រជាមានិតចិនលើកនេះ បានគូសបញ្ជាក់ពីការពេញចិត្តទាំងស្រុងរបស់ភាគីទាំងសងខាង"។

តាមរយៈទស្សនកិច្ចជាផ្លូវការដោយ ខៀវ សំផន និង អៀង សារី មុននឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

ខ្ញុំសូមចាប់ផ្តើមឯកសារ E3/3315, "ថាតើប៉ុល ពត ចូលកាន់អំណាចដោយរបៀបណានោះ?" ERN ជាភាសាអង់គ្លេស 00478532, ខ្មែរ 00180885 មិនមានERN ជាភាសាបារាំងទេ។ សម្រង់គឺមានដូចតទៅ៖ "នៅក្នុងខែមិថុនា ឆ្នាំ១៩៧៩ (*ស៊ីក*) បើតាមសម្តីរបស់ ប៉ុល ពត -- ៧៤ -- គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាបានជួបប្រជុំ ហើយបានសម្រេចធ្វើការវាយលុកផ្តាច់ព្រ័ត្រដើម្បីរំដោះភ្នំពេញនិងប្រទេសទាំងមូល។ យុទ្ធនាការនេះ ត្រូវចាប់ផ្តើមនៅខែមករា ឆ្នាំ១៩៧៥"។

នេះប្រហែលជាកិច្ចប្រជុំនៅក្នុងសៀវភៅរបស់ ប៉ែន ឃៀវនិន ដែលយោងទៅលើសុន្ទរកថារបស់ ប៉ុល ពត នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧ គឺលេខយោងចុងទំព័រ១។ បន្ទាប់មកទៀត ឯកសារ E3/11 គឺជាការបោះពុម្ពផ្សាយទង់បដិវត្តនៅខែកញ្ញា ឆ្នាំ១៩៧៧។ ERN ជាភាសាអង់គ្លេស 00--

[១១:៣៩:១៥]

**អ្នកបកប្រែ៖**

លោកប្រធាន សូមអធ្យាស្រ័យ គាត់អាន ERN ញាប់ពេក តាមមិនទាន់។

**លោក ឃឹត វេយ៍ន័រ៖**

--ERN អង់គ្លេស 00486247, ខ្មែរ 00063162 លើ 3, បារាំង 00492836។ គឺជាសម្រង់ចេញពីទង់បដិវត្តចុះខែកញ្ញា ឆ្នាំ១៩៧៧។ "ដំបូងយើងយកចិត្តទុកដាក់ទៅលើការវាយទីតាំងខ្សោយៗរបស់ខ្មាំងនៅតាមជនបទដោយរួមផ្សំទាំងយោធា តាមការប្រមូលផ្តុំ និងកងឈ្លប ហើយនិងតាមរូបភាពកុប្បកម្ម វាយខ្មាំងនៅតាមភូមិឃុំ។ តាមរយៈនេះយើងរំដោះជនបទរបស់យើងកាន់តែទូលំទូលាយជារៀងរាល់ថ្ងៃ ហើយឯកកោខ្មាំងឲ្យមកនៅនេះ នៅក្រវៀនតែក្នុងប្រជុំមួយចំនួនតែប៉ុណ្ណោះ។ យើងធ្វើយ៉ាងនេះគឺវាយខ្មាំងតាមទីតាំងផ្សេងៗទាក់ទងគ្នាទៅវិញទៅមក ដើម្បីផ្គត់ផ្គង់គ្នាក៏ពិបាកផង។ គឺនៅក្នុងសភាពការណ៍នេះហើយដែលយើងលើកពីវិធានការវាយផ្លូវគមនាគមន៍ ជាយុទ្ធសាស្ត្រនៅក្នុង -- គឺនៅក្នុងខែមិថុនានោះ គឺជាលទ្ធផលផ្តាច់ជាក់ស្តែងដើម្បីរំដោះភ្នំពេញ និងរំដោះប្រទេសទាំងមូល"។

[១១:៤១:២៦]

ហើយនិងពីរកថាខណ្ឌខាងក្រោមមកទៀត: ការអនុវត្តសេចក្តីសម្រេចរបស់គណៈមជ្ឈិមនៅក្នុងរដូវវស្សានៃឆ្នាំ១៩៧៤ យើងបានរៀបចំកងកម្លាំងរបស់យើងជាមនោគមន៍វិជ្ជា ជានយោបាយ និងជាតាមរូបភាពចាត់តាំង ហើយយើងបានចូលរួមប្រយុទ្ធនៅតាមសមរភូមិ កងទ័ពបដិវត្តន៍របស់យើងបានបំពេញបេសកកម្មរបស់បក្សដោយធ្វើការវាយសម្រុកផ្តាច់ព្រ័ត្រ។ បន្ទាប់សូមចូលឯកសារ E3/89 នេះជាប្រតិចារឹកនៃកិច្ចសម្ភាសរវាង អៀង សារី និង ស្ទីវិន ហេដឌ័រ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦។ ERN ជាភាសាអង់គ្លេស 00417603, ខ្មែរ 00062457 លើ 8, បារាំង 00332685។

អៀង សារី បាននិយាយដូចតទៅ៖ "បញ្ហាជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានសម្រេចពីមុននោះរួចមកហើយ នេះបើយោងតាមអ្វីដែលគេប្រាប់ខ្ញុំ"។ ហេដឌ័រ បានសួរថា៖ "នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ មែនទេនៅក្នុងមីនា, មេសា ឬក៏ចុងខែមីនា ឆ្នាំ៧៥? ពួកគេបានយកអ្វីៗទាំងអស់ ថាតើគេត្រូវយកឈ្នះភ្នំពេញដោយរបៀបណា?" "ខ្ញុំលើកបញ្ហានេះជាមួយនឹង ប៉ុល ពត នៅឆ្នាំ១៩៧៤ សួរ ប៉ុល ពត ថាតើមានការត្រៀមយ៉ាងម៉េច បើឈ្នះភ្នំពេញ? ពេលនោះឯងយើងជជែកគ្នាពីរឿងប្រជាជនហ្នឹង"។ ហេដឌ័រ គាត់បានសួរ៖ "ថាតើលោកជួបជាមួយនឹងគាត់នៅឯណា?" អៀង សារី ឆ្លើយ៖ "កាលហ្នឹងខ្ញុំជួបនៅជិតភ្នំពេញ ខ្ញុំត្រឡប់ពីប៉េកាំងវិញ ខ្ញុំមកនៅឆ្នាំ៧៣ ខ្ញុំទៅជួបជូនសម្តេចដល់ហាណូយ ហើយខ្ញុំទៅប៉េកាំងក្រោយពីត្រឡប់មក អង្កាល់ហ្នឹងឆ្នាំ៧៤"។ ហេដឌ័រ បានសួរ៖ "ថាតើលោកដឹកនាំគណៈប្រតិភូសេដ្ឋកិច្ចទៅវៀតណាម ហើយនិងទៅប៉េកាំងហ្នឹងមែនទេ?" អៀង សារី ឆ្លើយ៖

"បាទ ខ្ញុំត្រឡប់មកវិញៗ។ ដល់ពេលហ្នឹងយើងបានជជែកគ្នា ថាបើឈ្នះតើយើងធ្វើយ៉ាងដូចម្តេច? តើយើងត្រូវរៀបចំយ៉ាងម៉េច? នេះជាមតិរបស់ឯកឧត្តម ជូ អេនឡាយ គាត់សួរខ្ញុំ ថាតើពួកមិត្ត -- បើពួកមិត្តឈ្នះ តើពួកមិត្តមានផែនការដូចម្តេច? ខ្ញុំក៏ពិបាកដែរ ខ្ញុំមិនប៉ានឆ្លើយអីទាំងអស់ក្នុងពេលហ្នឹង។ ខ្ញុំថា ខ្ញុំមិនទាន់បានដឹងច្បាស់លាស់ទេ ខ្ញុំចាំមកសួរក្នុងប្រទេសៗគឺពីបញ្ហាពីកងទ័ព។ នៅពេលដែលខ្ញុំបានសួរនៅក្នុងប្រទេសហ្នឹងខ្ញុំមិនបានសួរអំពីបញ្ហាកងទ័ពទេ ប៉ុន្តែខ្ញុំសួរថាតើដំណោះស្រាយប្រជាជនយ៉ាងម៉េចដែរ? តើត្រូវមានដំណោះស្រាយអ្វីដើម្បីដោះស្រាយប្រជាជន៣លាននាក់នៅក្នុងទីក្រុងភ្នំពេញ។ ប៉ុលពត បានឆ្លើយនឹងខ្ញុំថា គេមានបទពិសោធន៍អស់ហើយ។ សូមមិត្តកុំគិត មិត្តគិតតែភារកិច្ចរបស់មិត្តទៅបានហើយ។ គឺគិតតែពីភារកិច្ចរបស់ខ្ញុំនៅក្រៅប្រទេសទៅបានហើយ។ ហើយខ្ញុំបាននិយាយថាបញ្ហានេះគឺជាថ្នាក់ដឹកនាំចិនសួរខ្ញុំ បានខ្ញុំសួរពីបញ្ហាហ្នឹង ហើយគាត់ឆ្លើយថានេះគឺជាបញ្ហាមួយដែលងាយស្រួលដោះស្រាយទេ។ ហើយសមមិត្តចិនយើងគ្មានស្អីដែលត្រូវព្រួយបារម្ភអំពីរឿងយើងនេះទេ។ ពីព្រោះយើងខ្មែរទាំងអស់នេះគឺថាមានសញ្ញាណច្បាស់លាស់ហើយពាក់ព័ន្ធទៅនឹងបញ្ហាទាំងអស់នេះ។ គឺថាបញ្ហាទាំងអស់នេះយើងបានដោះស្រាយ នៅស្ទឹងត្រែង និងនៅខេត្តក្រចេះរួចហើយ។ ដូច្នេះបញ្ហាដើម្បីដោះស្រាយបញ្ហានេះគឺត្រូវតែជម្លៀសប្រជាជន។ នេះគឺជាមធ្យោបាយតែមួយគត់ដើម្បីដោះស្រាយបញ្ហានេះ។ ខ្ញុំក៏បានសួរទៅវិញថាតើ វាជាការជម្លៀសប្រជាជនទាំងអស់ ឬមួយយ៉ាងម៉េច? ហើយគាត់ឆ្លើយថាចាំមើលស្ថានភាពជាក់ស្តែង ប៉ុន្តែពាក្យជម្លៀសមានប្រើពេលឆ្នាំ៧៤ ហ្នឹងឯង។ ទោះជាយ៉ាងណាក៏ដោយពាក្យថា ជម្លៀសត្រូវបានប្រើប្រាស់រួចទៅហើយគឺតាំងពីឆ្នាំ៧៤ មកម្ល៉េះ"។

[១១:៤៨:០៦]

បាទ គឺខ្ញុំចូលទៅឯកសារ E3/687 នេះគឺជាអត្ថបទចុះផ្សាយនៅក្នុងកាសែត ញូវយ៉កថាមស៍ នៅថ្ងៃទី០៩ កក្កដា ឆ្នាំ១៩៨២។ ឯកសារនេះមានចំណងជើងថា "សម្ព័ន្ធមិត្តបីរបស់កម្ពុជាក្នុងសង្គ្រាមនៅវៀតណាម"។ មនុស្សបីនាក់ដែលបានយោងនៅក្នុងឯកសារនេះគឺសម្តេច នរោត្តម សីហនុ, អតីតនាយករដ្ឋមន្ត្រីរបស់គាត់ឈ្មោះសឺន សាន និង ខៀវ សំផន។ អ្នកទាំងបីនេះគឺបានថាជាជនកុម្មុយនីស្តជើងចាស់យូរមកហើយ ទាក់ទងទៅនឹងរបបកុម្មុយនីស្តខ្មែរក្រហម និងជួយធ្វើឲ្យការជម្លៀសប្រជាជន៣លាននាក់ពីភ្នំពេញនោះ ត្រូវបង្ខំឲ្យជម្លៀសដោយរបៀបណា។

នៅត្រង់ទំព័រអង់គ្លេស 00122280, ខ្មែរ 00651189, បារាំង 00622450 គឺអ្នកនិពន្ធនេះឈ្មោះ ខូលីន ខាំបូល។ យោងទៅលើសម្តីរបស់ ខៀវ សំផន និយាយពីសេចក្តីសម្រេចទាំងបួន សេចក្តី

សម្រេចក្នុងចំណោមមនុស្សទាំងប្រាំបីនាក់។ គាត់និយាយថា ប្រជាជនកម្ពុជារាប់លាននាក់ត្រូវបានជម្លៀសចេញពីក្រុងភ្នំពេញទៅកាន់ជនបទ ដោយសារតែសេចក្តីសម្រេចជាសមូហភាពនេះ។ តើលោកបានចូលរួមក្នុងការសម្រេចចិត្តនោះទេ? លោក ខៀវ សំផន បានញញឹមស្ងួត ហើយជាភាសាបារាំងថា បាទ ប្រាកដណាស់។

[១១:៥០:៤៩]

ខ្ញុំបន្តទៅឯកសារE3/26 ជាកិច្ចសម្ភាសន៍រវាង នួន ជា ជាមួយនឹងអ្នកកាសែតជប៉ុននៅថ្ងៃទី០៧ តុលា ២០០៦។ ជាអង់គ្លេស 00329511, ខ្មែរ 00000899, បារាំង 00636871។ អ្នកកាសែតបានសួរសំណួរនេះទៅកាន់ នួន ជា “តើហេតុអ្វីបានជា ប៉ុល ពត មានសមត្ថភាពគ្រប់គ្រាន់គ្រប់គ្រងចលនានេះទាំងមូល? នួន ជា ឆ្លើយ៖ អានេះមិនមែនគាត់ម្នាក់ឯងទេ រួមគ្នាទាំងអស់។ គាត់ក៏រួមចំណែក យើងខ្ញុំក៏រួមចំណែក ប៉ុន្តែសំខាន់ប្រជាជនគេគាំទ្រ គេឧបត្ថម្ភ។ សំណួរ៖ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តើ ប៉ុល ពត មានអំណាចមុខតែឯង ឬក៏យ៉ាងម៉េច? នួន ជា ឆ្លើយ៖ មិនទេ សមូហភាព (គឺជាមជ្ឈការ)”។

ទំព័រអង់គ្លេស 00299512, ខ្មែរ 00000901 ហើយបារាំង 00636873, បាទមានសំណួរពីខាងអ្នកសារព័ត៌មានសួរថា “តើអ្នកណាសម្រេចជម្លៀសប្រជាជនចេញពីទីក្រុង? នួន ជា ឆ្លើយ៖ គណៈមជ្ឈិមបក្ស។ អ្នកសារព័ត៌មានសួរ៖ អ្នកណាជាអ្នកផ្តួចផ្តើមគំនិត? នួន ជា ឆ្លើយ៖ កាលនុំងផ្តើមគំនិតម្នាក់បន្តិចៗ។ សំខាន់គឺយើងរួមផ្សំគំនិតនេះបន្តិច គំនិតនោះបន្តិច”។

[១១:៥៤:០៦]

បន្ទាប់យើងចូលឯកសារ D3248/5.1.28 ចុះថ្ងៃទី១០ កក្កដា ៧៤, សារទូរលេខពីស្ថានទូតអាមេរិកពីទីក្រុងភ្នំពេញផ្ញើជូនក្រសួងការបរទេស និយាយអំពីការជម្លៀសប្រជាជន ជនភៀសខ្លួនខ្មែរនាពេលថ្មីៗទៅកាន់អ្នកលឿង។ ERN ជាភាសាអង់គ្លេស 00377045 ដល់ 46, ខ្មែរ 00658192 ដល់ 93, បារាំង 00663886 ដល់ 87។ ប្រការពីរនៅក្នុងសាទូរលេខនេះ គឺសូមដកស្រង់ដូចតទៅ៖ “កាលពីជាង១ឆ្នាំមុននេះ កងកម្លាំងបដិវត្តន៍ខ្មែរបានចូលកន្លែងលុកលុយកន្លែងមួយចំនួនតាមផ្លូវជាតិលេខ១ត្រង់ចន្លោះរវាងអ្នកលឿងនិងភ្នំពេញ។ ហើយបានចល័តប្រជាជនខ្មែរភាគច្រើនដែលរស់នៅទីនោះឲ្យឆ្ពោះទៅកាន់តំបន់វាលល្បប់ភក់ចន្លោះរវាងទន្លេមេគង្គ និងទន្លេបាសាក់ឆ្ពោះទៅចំទិសខាងត្បូង ដោយប្រមូលផ្តុំនៅជុំវិញភូមិតូចនៃ ដើម្បីឲ្យពួកគេធ្វើស្រែចម្ការ និងនេសាទត្រីដើម្បីទ្រទ្រង់ដល់កម្លាំងបដិវត្តន៍

ខ្មែរ។ ជីវិតនៅជុំវិញតំបន់ប្រាសាទតាឃោ មានស្ថានភាពលំបាកណាស់ ហើយជនភៀសខ្លួនភាគច្រើនបំផុតដែលបានវិលត្រឡប់មកវិញថ្មីៗនេះបានតវ៉ាយ៉ាងខ្លាំងអំពីការខាតបង់សេដ្ឋកិច្ច និងការគាបសង្កត់ខាងនយោបាយ។ ក្នុងរយៈពេលប៉ុន្មានខែនេះ ស្ថានភាពកាន់តែលំបាកខ្លាំងទៅ រហូតដល់ប្រជាជននៅទីនោះគ្មានអ្វីបរិភោគក្រៅពីពោតនោះទេ។ អ្នកខ្លះបានព្យាយាមគេចចេញដោយខ្លួនឯង ហើយក្នុងអំឡុងពេលប៉ុន្មានខែចុងក្រោយនេះ ប្រជាជនប្រមាណ១៥០គ្រួសារបានគេចទៅអ្នកលឿងដោយសុវត្ថិភាព។ អ្នកដទៃទៀតមិនមានសំណាងទេ ហើយត្រូវចាប់បាន ឬសម្លាប់ដោយពួកបដិវត្តន៍ខ្មែរ។

[១១:៥៦:៥៥]

បន្តទៅទៀតគឺឯកសារ E3/3329 ជាសាទូរលេខពីស្ថានទូតអាមេរិក។ ERN គឺដូចតទៅ អង់គ្លេស 00412877, ខ្មែរ 00632768, បារាំង 00599748។ បាទនេះជាសាទូរលេខពីស្ថានទូតអាមេរិកនៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ ផ្ញើទៅទីក្រុងវ៉ាស៊ីនតោន។ ទី១ កាសែតវៀងចន្ទន៍ដេលី "ឡាវណេសិន" នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៧៤ បានចេញផ្សាយនូវអត្ថបទមួយដែលមានចំណងជើងថា៖ "ទុក្ខវេទនាក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម ដំណើរប្រាប់ដោយព្រះសង្ឃខ្មែរមួយអង្គ។" ខាងក្រោមនេះគឺជាការបកប្រែអត្ថបទនេះចេញពីភាសាអង់គ្លេស៖

គឺលេខ២. នៅពេលធ្វើទស្សនកិច្ចនៅវត្តសែនមួយ ស្ថិតនៅក្នុងខេត្តស៊ីថានដូន"។ អ្នកយកព័ត៌-មានបានសម្ភាសព្រះសង្ឃខ្មែរមួយអង្គ គឺព្រះភិក្ខុ គូ អាត ជាចៅអធិការនៅវត្តតាកើយ ដែលបានមកសុំសិទ្ធិជ្រកកោននៅក្នុងស៊ីថានដូន នៅមុនពេលចូលវស្សា។ ព្រះអង្គមានសង្ឃដីកាអំពីស្ថានភាពរស់នៅដ៏ស្ថានលំបាកនៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម។

[១១:៥៨:៥៣]

នៅចំណុចលេខ៥. និយាយអំពីការគ្រប់គ្រងនៅក្នុងតំបន់ក្រហម។ ព្រះតេជគុណ គូ អាត បានមានសង្ឃដីកាថាប្រជាជនរស់នៅយ៉ាងលំបាក ពួកគេជាជនរងគ្រោះនៃរបបផ្ដាច់ការ ហើយត្រូវតែចូលរួមក្នុងការប្រជុំឃោសនាជានិច្ច និងប្រឈមមុខចំពោះគ្រប់ឧបសគ្គទាំងអស់។

ហើយចំពោះបញ្ហាយោធាមានបញ្ហាពិសេស គឺ ខៀវ សំផន ដែលបានហាមឃាត់ប្រជាជនរស់នៅក្នុងតំបន់ដែលមានព្រំប្រទល់ជាប់នឹងប្រទេសឡាវ មិនឲ្យមានការគោរពចំពោះសម្ដេច សីហនុ។

៧. អ្នកនាក់ដែលមិនគោរពបទបញ្ជាហ្នឹងនឹងត្រូវសម្លាប់ចោលយ៉ាងព្រៃផ្សៃ។ នេះជាការបង្ហាញឲ្យដឹងដោយព្រះសង្ឃអង្គដដែល ដែលបាននិយាយពីការរាយការណ៍របស់ឧត្ដមសេនីយ៍ សំ ផុន ដែល

ត្រូវបានគេសម្លាប់នៅឆ្នាំ៧៣នោះ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកសវនាការព្រឹកនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅរសៀលនេះចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី។ សូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនោះខ្លួនគាត់មកចូលរួមនៅសវនាការនេះ នៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារគន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអញ្ជើញ!

**លោក ឃីត វេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។

ខ្ញុំសង្ឃឹមថា អស់លោក លោកស្រី មិនងងុយគេងទេនៅពេលនេះ។ នៅពេលរសៀលនេះ ខ្ញុំសូមចាប់ផ្តើមដោយនិយាយយោងទៅលើឯកសារមួយដែលខ្ញុំភ្លេចលើកមកបង្ហាញនៅព្រឹកនេះ។ ឯកសារនោះ E3/114។ គឺជាការបោះពុម្ពផ្សាយរបស់ខាងហ្វុង ដែលមានចំណងជើងជាភាសាបារាំងថា "នូវែល ឌុយ កាំបូដស៍" ហើយចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៤។ ភាសាអង់គ្លេសមានលេខ 00280550, ភាសាបារាំងមានលេខ 00000088, និងខ្មែរមានលេខ 00662247។ ឯកសារនេះមានចំណងជើងដូចតទៅនេះ៖ "ទង់កិត្យានុភាព សមត្ថភាព និងកិត្តិយសរបស់ជាតិ របស់ប្រជាជនកម្ពុជា របស់រណសិរ្ស

រួបរួមជាតិកម្ពុជា (រ.រ.ជ.ក) និងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា អណ្តែតខ្ពស់ត្រដែតលើឆាកអន្តរជាតិ”។

[១៣:៣៤:៣០]

បន្ទាប់មកគឺមានអត្ថបទដែលរៀបរាប់អំពីគណៈប្រតិភូដែលដឹកនាំដោយលោក ខៀវ សំផន និងលោក អៀង សារី ដែលធ្វើដំណើរទស្សនកិច្ចក្រៅផ្លូវការទៅកាន់ប្រទេសជាមិត្ត ជាបងប្អូនមួយចំនួនដូចជា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម សាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។ ហើយនៅទំព័របន្ទាប់ ភាសាអង់គ្លេសមានលេខ 00280551, ភាសាបារាំងមានលេខ 00000088 គឺនៅទំព័រដដែល ដូចនឹងការដកស្រង់លើកទី១ ហើយនិងទំព័រមួយទៀតគឺមានលេខ S00662248 ដែលមានការដកស្រង់ដូចតទៅនេះ៖

“ដំណើរទស្សនកិច្ចនេះបានទទួលនូវភាពគគ្រឹកគគ្រេងមហោឡារិក និងវិសាលភាពបែបនេះ។ ចំពោះមតិអន្តរជាតិ មតិមិត្ត ក៏ដូចជាពួកមិនមែនជាមិត្ត ពីព្រោះគណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលដឹកនាំដោយលោក ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី និងលោក អៀង សារី ទីប្រឹក្សាពិសេសនៃទីស្តីការគណៈរដ្ឋមន្ត្រីរងរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តំណាងឲ្យជាតិ ប្រជាជនកម្ពុជា និងចលនាតស៊ូប្រឆាំងនឹងពួកចក្រពត្តិអាមេរិក ដើម្បីរំដោះជាតិនៅលើសមរភូមិដ៏ក្តៅគគុកជាងគេបំផុតនៅលើពិភពលោកនាបច្ចុប្បន្នកាលនេះ ដែលជាចលនាតស៊ូឯករាជ្យ ម្ចាស់ការ សុទ្ធសាធ ដែលមិនពឹងផ្អែកទៅលើប្រទេសបរទេសណាមួយឡើយ និងកាន់ក្តាប់ជោគវាសនាប្រទេសរបស់ខ្លួន និងប្រជាជនរបស់ខ្លួន។ រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គឺជាតំណាងពិតប្រាកដនៃចលនាតស៊ូរំដោះប្រទេសតូចតាចរងគ្រោះនៃអំពើឈ្លានពានដ៏សាហាវព្រៃផ្សៃបំផុត និងដែលកំពុងតែឈ្នះពួកចក្រពត្តិឈ្លានពានអាមេរិក ដែលជាមេខ្លោងរបស់ពួកចក្រពត្តិអន្តរជាតិទាំងអស់”។

[១៣:៣៧:១០]

នៅក្នុងឯកសារដដែល ខ្ញុំសូមបន្តទៅ -- ភាសាអង់គ្លេសមានលេខ 00280556, ខ្មែរមានលេខ 00662258 និងភាសាបារាំងមានលេខ 00000093/94។ ការដកស្រង់ គឺមានចំណងជើងដូចតទៅនេះ៖

“ពួកក្បត់ភ្នំពេញត្រូវបានវាយរំលំ ហើយយើងបានគ្រប់គ្រងទៅលើទីតាំងរបស់ពួកវា ក្នុងពេល

ដែលកងទ័ពប្រជាជនរំដោះកម្ពុជាបានវាយប្រហារសាជាថ្មីទៀត” ហើយខាងក្រោមបន្តិច ចុះមកខាងក្រោមនេះ “ប៉ុន្តែនៅពេលដែលគេមកជួបជាមួយនឹងប្រជាជន-- ជាមួយទាហាននៅភ្នំពេញ គឺមានការវាយប្រហារនៅថ្ងៃទី១៤ ខែមីនា ប្រឆាំងទៅនឹងនៅលើកោះដាច់ និងកោះឧកញ៉ាតី លើទន្លេមេគង្គចម្ងាយប្រាំមួយគីឡូម៉ែត្រពីព្រះបរមរាជវាំងក្រុងភ្នំពេញ។ ក្នុងរយៈ១យប់១ថ្ងៃ កងទ័ពប្រជាជនរំដោះជាតិកម្ពុជា បានរំដោះកោះទាំងនេះ និងកម្ទេចកងវរសេនាតូចរបស់ខ្មាំងបានមួយចំនួន និងបានជួយនាំប្រជាជនចំនួន ៥០.០០០នាក់ ទៅតំបន់រំដោះ”។

[១៣:៣៩:០៤]

ហើយនៅខាងក្រោមនេះបន្តិច “មួយថ្ងៃបន្ទាប់មក គឺថ្ងៃទី១៥ ខែមីនា កងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានវាយប្រហារជាថ្មីម្តងទៀតយ៉ាងខ្លាំង និងដោយមិនឲ្យខ្មាំងដឹងជាមុននៅក្រុងឧដុង្គ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៤ កងទ័ពប្រជាជនរំដោះជាតិកម្ពុជា បានរំដោះឧដុង្គបានទាំងស្រុង។ កងពលខ្មាំងមួយត្រូវបានកម្ទេច ហើយប្រជាជនចំនួន ៣០.០០០នាក់ នៃក្រុងនេះ និងតំបន់នៅជុំវិញ បានទៅដល់តំបន់រំដោះដោយជោគជ័យ។ ទាល់តែកងទ័ពប្រជាជនរំដោះជាតិកម្ពុជាបានបំផ្លាញទាំងស្រុងនូវប្រព័ន្ធទីតាំងទ័ព អំណាចរដ្ឋបាល ជំរំឃុំឃាំង មជ្ឈមណ្ឌលសន្តិភាពនៅក្រុងឧដុង្គរួចហើយ ទើបពួកអាក្សត់ប្រញាប់ប្រញាល់បញ្ជូនកម្លាំងជំនួយ ដើម្បីដណ្តើមយកក្រុងឧដុង្គវិញ ប៉ុន្តែកម្លាំងជំនួយនេះត្រូវបានកម្ទេចយ៉ាងដំណំ និងសម្លាប់ជាច្រើននាក់”។

[១៣:៤០:៣១]

ជាបន្តទៅទៀតនេះ ខ្ញុំសូមលើកទៅលើឯកសារ E3/2728, អង់គ្លេសមានលេខ 00390921, ខ្មែរមានលេខ 00602506, និងភាសាបារាំងមានលេខ 00602498 គឺឯកសារនេះជាសុន្ទរកថារបស់ ប៉ុល ពត នៅទីក្រុងប៉េកាំងនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៧។ ហើយខ្ញុំសូមធ្វើការដកស្រង់ដូចតទៅនេះ គឺនៅក្រោមចំណងជើងដែលមានចំណងជើងថា “ប៉ុល ពត អំពីការជម្លៀសប្រជាជនចេញពីទីក្រុង”។ ប៉ុល ពត បានផ្តល់នូវសន្និសីទកាសែតនៅក្នុងទីក្រុងប៉េកាំងនៅថ្ងៃ០៣ តុលា ឆ្នាំ៧៧ ហើយរាយការណ៍ដោយសារព័ត៌មាន អ៊ិន.ស៊ី.អ៊ិន.អេ ដែលនិយាយអំពីប្រជាជនដែលស្ថិតក្រោមការដឹកនាំរបស់បក្ស។

ចំណុចសំខាន់មួយនៅក្នុងជោគជ័យរបស់បដិវត្តន៍នៅក្នុងប្រទេសកម្ពុជា “គឺគាត់បានលើកឡើងថា គឺការជម្លៀសប្រជាជនចេញពីទីក្រុងទៅទីជនបទ។ ការជម្លៀសនេះត្រូវបានសម្រេចនៅក្នុងខែកុម្ភៈ ឆ្នាំ៧៥ ដោយសារតែ យើងដឹងថាមុនពេលដែលយើងអាចកម្ទេចនូវគ្រប់ប្រភេទនៃពួកខ្មាំង និងពួកបង្កប់

កងកម្លាំងរបស់យើងគឺមិនទាន់ខ្លាំងគ្រប់គ្រាន់ដើម្បីការពាររបបបដិវត្តន៍បាននោះទេ។ ភ្នាក់ងារសម្ងាត់របស់ខ្មាំងគឺវាយបណ្ដាញក្នុងប្រទេសកម្ពុជា ហើយវាមានលក្ខណៈស្មុគស្មាញទៅទៀត។ នៅពេលដែលយើងកម្ទេចពួកគេគឺយើងពិបាកដើម្បីប្រយុទ្ធជាមួយពួកនេះ ហេតុដូច្នេះហើយគឺយើង ពួកយើងគឺត្រូវ -- យើងត្រូវបំបែកទៅតាមសហករណ៍នានា ដើម្បីឲ្យយើងអាចគ្រប់គ្រងបាន។ ដូច្នេះគឺយើងមាន -- យើងអាចក្ដាប់ខ្មាំងនៅក្នុងដៃបានដោយមិនឲ្យមានការជួយពីខាងក្រៅមកបាន"។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

[១៣:៤២:៥៧]

ឯកសារបន្ទាប់គឺជាសារព័ត៌មានហ្វីប៊ីសថ្ងៃទី១៥ ខែមីនា ភាសាអង់គ្លេសមានលេខ 00413180 ហើយមិនមានការបកប្រែជាភាសាខ្មែរ និងភាសាបារាំងនោះទេ ប៉ុន្តែយើងកំពុងស្នើសុំឲ្យមានការបកប្រែឯកសារទាំងអស់នេះ។ នេះគឺជាសារទូរលេខរបស់ក្រសួងការបរទេសអាមេរិកដែលបានដកស្រង់នៅថ្ងៃទី១៥ មីនា ឆ្នាំ៧៥ ហើយឯកសារនេះគឺជាឯកសារសារទូរលេខផ្ញើចេញពីស្ថានទូតអាមេរិកនៅរ៉ូមទៅទីក្រុងវ៉ាស៊ីនតោន។

អនុរដ្ឋមន្ត្រីបុរីវ៉ាទីកង់ឈ្មោះ ប៉ែន ណាលី បានស្នើសុំឲ្យមានការ -- បានបញ្ជូនព័ត៌មានទៅការិយាល័យរបស់គាត់នៅព្រឹកថ្ងៃទី១៣ ខែមីនា ដើម្បីជម្រាបគាត់ថា ប៉ុប ផូល គឺថាមានអារម្មណ៍រន្ធត់យ៉ាងខ្លាំងទាក់ទងទៅនឹងស្ថានភាពនៅក្នុងប្រទេសកម្ពុជា។ ប្រតិភូសាសនានៅក្នុងទីក្រុងសៃហ្គន គឺលោកអាចារ្យ ឡឺ ម៉ែត្រ បានបញ្ជូនរបាយការណ៍ទៅបុរីវ៉ាទីកង់ នៅក្នុងរយៈពេលពីរបីថ្ងៃចុងក្រោយនេះ ដែលរបាយការណ៍នេះបានបញ្ជាក់ថា ពួកខ្មែរក្រហមបានកាប់សម្លាប់យ៉ាងសាហាវយង់ឃ្នងទៅលើប្រជាជនស៊ីវិលស្លូតត្រង់នៅក្នុងតំបន់ដែលពួកគេបានគ្រប់គ្រង។ របាយការណ៍ទាំងអស់នេះ គឺរាយការណ៍ដោយលោកអាចារ្យ ឡឺ ម៉ែត្រ ដោយផ្អែកទៅលើព័ត៌មានដែលទទួលបានពីអាចារ្យសាសនាកាតូលិកនៅក្នុងតំបន់ដែលមានការវាយប្រយុទ្ធ ក៏ដូចជាទទួលបានពីប្រភពដទៃទៀតផងដែរ។

[១៣:៤៥:១០]

ហើយឯកសារបន្ទាប់គឺឯកសារ D366/7.1.366--

**ប្រធានអង្គជំនុំ៖**

កុំអាល់សិនលោកតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោកខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព។ ភាគីទាំងអស់ជាទីគោរព។ ខ្ញុំសូមឱ្យសហភាតារបស់ខ្ញុំអភ័យទោសឱ្យខ្ញុំផងដែលខ្ញុំបានកាត់ផ្តាច់គាត់ ក៏ប៉ុន្តែខ្ញុំមានបញ្ហាមួយទាក់ទងទៅនឹងបញ្ហាឯកសារដែលគាត់កំពុងបង្ហាញនេះគឺថាឯកសារនេះជាឯកសារគន្លឹះ ហើយឯកសារហ្នឹងពុំមាននៅក្នុងជើងទំព័រដីកាដំណោះស្រាយ ហើយក៏មិនមាននៅក្នុងបញ្ជីរបស់ភាគីដែល។ អ៊ីចឹងបើពុំមានសំណើណាមួយដែលស្នើថាជាឯកសារថ្មីនោះ ខ្ញុំគិតថាគេមិនអាចយកឯកសារនេះមកបង្ហាញបានទេក្នុងឋានៈជាឯកសារគន្លឹះនោះ។ អ៊ីចឹង ខ្ញុំសូមជំទាស់ក្នុងដំណាក់កាលនេះក្នុងការបង្ហាញឯកសារនេះថាជាឯកសារគន្លឹះ។ សូមអរគុណលោកប្រធាន។

[១៣:៤៦:៣៤]

**លោក ឃីត វេយ្យន័រ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីពន្យល់អំពីឯកសារមួយនេះ។

ជាដំបូងគឺឯកសារនេះមាននៅក្នុងជើងទំព័រដីកាដំណោះស្រាយ។ ទី២ ឯកសារនេះគឺជាឯកសាររបស់ ហ្វីប៊ីស ដែលមេធាវីការពារក្តី អៀង សារីបានលើកឡើងថាមិនការត្រូវពិភាក្សាដេញដោលមុនពេលមានការទទួលយកនោះឡើង។ ទី៣ ឯកសារនេះគឺស្ថិតនៅក្នុងបញ្ជីរបស់មេធាវី អៀង សារី ហើយវាជាឱកាសមួយដែលខាងព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះដាក់ចូលនូវឯកសារចំនួន២៤ ដែលមិនទាន់ត្រូវបានគេពិភាក្សា។ ឯកសារមួយនេះគឺថាមាននៅក្នុងបញ្ជីដែលបានបញ្ជូនទៅដល់គ្រប់ភាគីទាំងអស់នៅក្នុងសារអេឡិចត្រូនិក ហើយក៏មិនមានការជំទាស់ណាមួយដែលបានលើកឡើងទាក់ទងទៅនឹងឯកសារនេះឡើយ។ តាមដែលខ្ញុំដឹងឯកសារនេះ គឺស្ថិតនៅក្នុងដំណាក់កាលរង់ចាំការសម្រេចជាស្ថាពរពីអង្គជំនុំជាសម្រាលដំបូង។ ប៉ុន្តែខ្ញុំគិតថាឯកសារនេះវាមានភាពពាក់ព័ន្ធយ៉ាងសំខាន់នៅក្នុងផ្នែកនេះ។ ដូច្នេះប្រសិនខ្ញុំអានហើយ អង្គជំនុំជម្រះសម្រេចថាទទួលយក គឺឯកសារហ្នឹងនៅក្នុងសំណុំរឿង។ ប៉ុន្តែសម្រាប់ហេតុផលអ្វីក៏ដោយ ប្រសិនបើមិនមានការទទួលយកទេ គឺយើងមិនចាំបាច់ដាក់បញ្ចូលទៅក្នុងសំណុំរឿងដូច្នេះទេ។ ដូច្នេះខ្ញុំសូមស្នើថា ឯកសារនេះគឺជាឯកសារពាក់ព័ន្ធយ៉ាងខ្លាំង ហើយវាមានសារៈសំខាន់យ៉ាងខ្លាំង។ គឺឯកសារចុះថ្ងៃទី១៧ មីនា ៧៥ មុនពេលដែលមានការជម្លៀស១ខែ។ ហេតុដូច្នេះខ្ញុំសូមស្នើថា អង្គជំនុំជម្រះមេត្តាសម្រេចទៅលើឯកសារឱ្យទៅតាមការជាក់ស្តែង។

[១៣:៤៨:៤៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមចោទសំណួរទៅសហព្រះរាជអាជ្ញាមួយ ថាតើកំណត់ត្រាជើងទំព័រនៃដីកាដំណោះស្រាយមួយណា ខ្ញុំរកហើយមិនឃើញទេ ហើយយើងពិតជាឃើញថាឯកសារហ្នឹងពីមុនមកត្រូវបានក្រុម អៀង សារី ជំទាស់ ហើយក្រោយមកទៀតដោយភាន់ច្រឡំនោះគាត់បានប្រាប់ថាឯកសារហ្នឹងមាននៅក្នុងកថាខណ្ឌ -- ទំព័រ៣៧៧ ហើយយើងរកមិនឃើញទេ។ អ៊ីចឹងម្ដងទៀត ជាថ្មីម្ដងទៀតយើងខ្ញុំសូមបញ្ជាក់ថា កំណត់ត្រាជើងទំព័រ៣៧៧នេះពុំមានទេ។ អ៊ីចឹងប្រសិនបើសហព្រះរាជអាជ្ញាមានអំណះអំណាងអីសូមផ្ដល់បន្ថែមទៀតពីព្រោះថានៅក្នុងដីកាដំណោះស្រាយពុំមានទេ។ ហើយបើសិនជាក្រុម អៀង សារី ដែលថាគាត់បង្ហាញច្រឡំអីនោះ អានោះមិនមែនជាការពិតទេ។ ហើយសេចក្ដីសម្រេចរបស់តុលាការក៏មិនទាន់មានចេញដែរ។ អ៊ីចឹងបើមិនទាន់មានសេចក្ដីសម្រេចអីទេ អ៊ីចឹងខ្ញុំគិតថាមិនទាន់អាចចាត់ទុកថាឯកសារនេះជាឯកសារគន្លឹះបានដែរ។

[១៣:៤៩:៥៩]

**លោក ឃីត រេយ៉ន័រ៖**

លោកប្រធានជាការត្រឹមត្រូវដែលខាងមេធាវីការពារក្ដីស្នើសុំនូវជើងទំព័រ ហើយខ្ញុំនឹងស្នើសុំឲ្យមន្ត្រីខាង*ខេសមេប*ត្រូវពិនិត្យទៅលើបញ្ហានេះ។ ហើយខ្ញុំសូមបញ្ជាក់ថាព័ត៌មានដែលខ្ញុំជម្រាបទៅតុលាការដូចដែលខ្ញុំបានបញ្ជាក់ គឺវាមាននៅក្នុងជើងទំព័រដីកាដំណោះស្រាយ ហើយថាមេធាវីមួយជាអ្នកប្រាប់មកខ្ញុំ។ ដូច្នេះខ្ញុំសូមស្នើដូច្នេះលោកប្រធាន ថាអនុញ្ញាតឲ្យខ្ញុំបន្តទៅមុខទៅលើឯកសារដទៃទៀត ហើយក្នុងពេលជាមួយគ្នាហ្នឹង គឺថាសហការីរបស់ខ្ញុំគាត់ស្វែងរកលេខនៅក្នុងជើងទំព័រ ហើយបន្ទាប់មកនៅពេលដែលរកឃើញ គឺថាខ្ញុំ យើងនឹងត្រឡប់មកនិយាយទៅបញ្ហាឯកសារនេះឡើងវិញ។ សូមលោកប្រធានមេត្តាអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

[១៣:៥០:៤៤]

**លោក ឃីត រេយ៉ន័រ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តទៅលើឯកសារ E3/3295 គឺជារបាយការណ៍មួយដែលរៀបចំឡើងដោយអ្នកសារព័ត៌មានចិនបានមកទស្សនកិច្ចនៅប្រទេសកម្ពុជា។ ហើយសម្រង់ទី១ គឺមាន

លេខភាសាអង់គ្លេស 00419155, ភាសាខ្មែរមានលេខ 00751899 និងភាសាបារាំងមានលេខ 00756905 ដល់ 06។ នេះគឺជារបាយការណ៍របស់អ្នកសារព័ត៌មានចិន ហើយខ្ញុំសូមដកស្រង់នូវសម្រង់ទី១ដូចតទៅនេះ "មួយថ្ងៃមុនដាច់ខែមីនា គឺនៅក្នុងខែមីនា ឆ្នាំ៧៥ យើងបានធ្វើទស្សនកិច្ចទីស្នាក់ការកណ្តាលសមរភូមិភ្នំពេញ។ យើងត្រូវគេទទួលយ៉ាងកក់ក្តៅ ហើយភ្ញៀវនិងម្ចាស់កម្មវិធីបានជជែកគ្នាអំពីមិត្តភាព ព្រមទាំងពិភាក្សាពីស្ថានភាពជ័យជម្នះនៃការរំដោះដែលជិតកើតឡើងនៅទីក្រុងភ្នំពេញ។ ម្ចាស់កម្មវិធីបានអមដំណើរយើងធ្វើទស្សនកិច្ច ហើយមានការចូលរួមដោយលោក ខៀវ សំផន និងនៃដែលជានៃរាជរដ្ឋាភិបាលរំដោះជាតិកម្ពុជា ហើយនិងមេបញ្ជាការកងទ័ពរំដោះកម្ពុជាផងដែរ។ យើងទទួលបាននូវការស្វាគមន៍យ៉ាងកក់ក្តៅ និងស្និទ្ធស្នាលពីពួកគាត់។ លោក ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហករណ៍ និងកំណែទម្រង់ ហើយនិងលោក ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការក៏បានទទួលប្រតិភូផងដែរ។ ហើយបានចូលរួមនៅក្នុងពិធីពិសាភោជនីយអាហារនៅក្នុងទីស្តីការរបស់ខាងរដ្ឋាភិបាលរំដោះជាតិកម្ពុជាផងដែរ"។

[១៣:៥៣:១៣]

នៅក្នុងផ្នែកមួយទៀតនៅក្នុងទំព័រដដែលនេះ គឺខ្ញុំសូមធ្វើការដកស្រង់ "អ្នកសារព័ត៌មានចិនបានចាកចេញដោយស្នាក់ស្មើរពីប្រទេសកម្ពុជា និងទឹកដីដ៏ល្អផូរផង់នៃប្រទេសកម្ពុជា ហើយមានព័ត៌មានយ៉ាងច្រើនបានបញ្ជាក់ថាកងទ័ពបានរំដោះតំបន់អ្នកលឿងរួចទៅហើយ។ បន្ទាប់មកគឺបានគ្រប់គ្រងទៅលើព្រលានយន្តពោធិ៍ចិនតុង។ យើងគិតថាការរំដោះទីក្រុងភ្នំពេញ គឺនឹងកើតឡើងនៅក្នុងពេលឆាប់ៗខាងមុខនេះ។ ប៉ុន្តែដោយសារតែរដូវកាលមូសុងបានចូលមកដល់ គឺយើងគិតថាប្រហែលជាយើងចាំបាច់ត្រូវត្រឡប់ទៅប្រទេសយើងវិញហើយ។ នៅតាមផ្លូវយើងបានឮព័ត៌មានដ៏ល្អមួយ ដែលគេនិយាយថា ភ្នំពេញត្រូវបានរំដោះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ យើងសូមលើកដៃ យើងគំនាប់គោរពជ័យជោគជ័យ ដ៏មហិមារបស់ប្រជាជនកម្ពុជាជាមិត្តភក្តិបងប្អូនរបស់យើង"។

ឯកសារបន្ទាប់គឺ E3/27 គឺជាកំណត់ហេតុស្តាប់ចម្លើយលោក ខៀវ សំផន ជាមួយនឹងសហចៅក្រមស៊ើបអង្កេត។ សំណួរដែលលើកឡើងដោយលោកចៅក្រមស៊ើបអង្កេត លោក ម៉ាសែលឡឺម៉ុងដ៍ គឺនៅទំព័រមានលេខ 00156743, ខ្មែរមានលេខ 00156614 និងជាភាសាបារាំងមានលេខ 00156666។ ចៅក្រម ឡឺមុងដ៍ បានសួរដូចតទៅនេះ៖ "តើលោកមានពីទីកន្លែងណា និងតើពីមុនមកលោកនៅជាមួយអ្នកណាគេ? ឆ្លើយ៖ អស់រយៈពេលជាង១០ថ្ងៃ ខ្ញុំនៅទីបញ្ជាការរបស់ប៉ុល ពត នៅ

ខាងលិចឧដុង្គ។ ខ្ញុំបញ្ជាក់ថា ខ្ញុំមិនបានចូលរួមក្នុងការងារទេ។ ខ្ញុំគ្រាន់តែមានវត្តមានប៉ុណ្ណោះ។ ហើយខ្ញុំតាមដានព្រឹត្តិការណ៍ដែល ប៉ុល ពត បានសង្ខេបឲ្យខ្ញុំម្តងម្កាល។ សំណួរ៖ តើមានវត្តមានអ្នកដទៃទៀតដែរឬទេ? ឆ្លើយ៖ ដូចជាមានតែខ្ញុំពីរនាក់ទេ"។

[១៣:៥៦:២៣]

ឥឡូវនេះ លោកប្រធាន ខ្ញុំសូមបន្តទៅឯកសារមួយទៀតដែលខ្ញុំបានបង្ហាញពីខាងដើមរួចមកហើយគឺជាសេចក្តីថ្លែងការណ៍របស់លោក អៀង សារី ដែលនិយាយអំពីការជម្លៀសប្រជាជន។ ឯកសារបន្តគឺ E3/611 គឺជាអត្ថបទព័ត៌មាននៅក្នុងសារព័ត៌មាន "ឈីកាហ្គោ ទ្រីប្យូន" នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ គឺជាអត្ថបទរបស់លោក រ៉ូណាល់ យ៉េត។ លោក អៀង សារី បានទទួលស្គាល់ថាគ្មានការជម្លៀសប្រជាជន ហើយនិងប្រហែលជាពីរភាគបីនៃប្រជាជនត្រូវបានគេបង្ខំឲ្យចាកចេញទៅទីជនបទ ហើយនិងទៅកាន់តំបន់សេដ្ឋកិច្ចជាច្រើនផ្សេងៗទៀតនៅតាមសហករណ៍នានា។ លោកនិយាយថាយើងគ្មានហេតុផលណាមួយដែលយើងត្រូវកាប់សម្លាប់ប្រជាជនរបស់ខ្លួនឯងនោះទេ។ លោក អៀង សារី បាននិយាយដូច្នេះ។

[១៣:៥៧:៤៧]

ឯកសារបន្ទាប់គឺឯកសារដែលមាន E3/550។ នេះគឺជាអត្ថបទដែលបោះពុម្ពនៅក្នុងទស្សនាវដ្តី ញ៉ូវស្វីក នៅថ្ងៃទី០៨ ខែ៩ ឆ្នាំ៧៥ ហើយអ្នកសរសេរអត្ថបទនេះគឺមានឈ្មោះថា ព្រីងហ្គល។ នេះគឺជាសំណួររបស់លោក ព្រីង ហ្គល ដែលធ្វើការចោទសួរទៅលោក អៀង សារី៖

"សំណួរ៖ ហេតុអ្វីកងកម្លាំងរបស់អ្នកជម្លៀសប្រជាជនចេញពីភ្នំពេញក្រោយពីពួកគេបានកាន់កាប់ទីក្រុងភ្នំពេញថ្ងៃទី១៧ ខែមេសា? អៀង សារី បានឆ្លើយ៖ មានមូលហេតុពីរ។ មូលហេតុទី១ គឺកត្តាស្បៀង យើងបានគិតថាមានប្រជាជនចំនួន២លាននាក់នៅភ្នំពេញ ប៉ុន្តែពេលយើងបានចូលទៅដល់យើងបានដឹងថា មាន៣លាននាក់"។

ព្រីងហ្គល បានសួរតទៅទៀត៖ "ចុះហេតុផលទី២ មូលហេតុទី២ ជាអ្វី? លោក អៀង សារី បានឆ្លើយថា៖ យើងបានរកឃើញឯកសារមួយដែលនិយាយលម្អិតអំពីផែនការនយោបាយយោធាសម្ងាត់មួយរបស់ភ្នាក់ងារសម្ងាត់កណ្តាលសហរដ្ឋអាមេរិក និងរបប លន់ នល់ ដួលរលំក្នុងការធ្វើឲ្យមានការភ័ន្តច្រឡំបន្ទាប់ពីជ័យជម្នះរបស់យើង"។

[១៣:៥៩:២៤]

ឯកសារបន្ត គឺE169/4.1.1 គឺភាសាអង់គ្លេសមានលេខ 00815131, ភាសាបារាំងមានលេខ 00815912 និងភាសាខ្មែរមានលេខ 00809797។ នេះគឺជាសម្រង់មួយដែលដកចេញពីទស្សនាវដ្ដី “យុវជន យុវនារីបដិវត្តន៍” គឺលេខ៧ ខែកក្កដា ឆ្នាំ១៩៧៥។ ឥឡូវនេះ យើងបានមកដល់យុគសម័យថ្មី នៃបដិវត្តន៍ប្រជាធិបតេយ្យ។ យើងបានរំដោះប្រទេសទាំងស្រុង។ យើងបានគ្រប់គ្រងទៅលើប្រទេស រដ្ឋអំណាចទាំងអស់ទូទាំងប្រទេស។ សង្គមកម្ពុជាបានក្លាយទៅជាសង្គមកម្ពុជាថ្មី ដែលគ្មានមនុស្សជិះជាន់មនុស្ស គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់ និងគ្មានត្រូវគេជិះជាន់ទៀតឡើយ។ ប្រជាជនកម្ពុជាទាំងអស់រស់នៅស្មើភាពគ្នា ដោយធ្វើការងារពលកម្មបង្កបង្កើនផលទាំងអស់គ្នាដើម្បីទ្រទ្រង់ជីវិត និងការពារកសាងប្រទេសជាតិទាំងអស់គ្នា។ នេះគឺជាលក្ខណៈសង្គមកម្ពុជាថ្មី”។

នៅក្នុងឯកសារដដែលនេះ គឺថាមួយទំព័រនៅខាងក្រោម ភាសាអង់គ្លេសមានលេខ 00815133, ខ្មែរមានលេខ 00809799, ហើយបារាំងគឺមួយទំព័រខាងក្រោម។ ដូច្នេះគឺមានលេខ 00815913។ “ប្រសិនបើបក្សគ្មានវិធានការជម្លៀសឲ្យចេញអស់ពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទេនោះ ប្រហែលជាខ្មាំងនឹងវាយសង្គ្រប់យើងពីក្រោយទៅវិញ។ កម្មេចកម្លាំងបដិវត្តយើងខ្ទេចខ្ទីអស់ ឬយ៉ាងហោចណាស់ក៏ខ្មាំងស៊ីរូងខាងគោលជំហរបដិវត្តន៍យើង ធ្វើឲ្យផ្ទៃក្នុងជួរបក្សបដិវត្តន៍ច្របូកច្របល់ ឥតអង្គការវិន័យ បែកបាក់សាមគ្គី សាបរលាបខាងគោលជំហរបដិវត្តន៍។ ដូច្នេះ ខ្មាំងអាចវាយកម្ទេចយើងថ្ងៃណាមួយក៏បាន។ ដូច្នេះ មហាជ័យជម្នះជាប្រវត្តិសាស្ត្រថ្ងៃទី១៧ មេសា របស់យើងក៏ត្រូវរលាយខ្សុលទៅវិញពុំខានឡើយ”។

[១៤:០២:៤០]

ឯកសារបន្តគឺ E3/622។ ឯកសារនេះចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨ ឯកសារនេះបង្ហាញនូវការផ្សព្វផ្សាយមួយអំពីគណៈប្រតិភូកម្ពុជានៅប្រទេសជប៉ុន ចុះក្នុងកាសែត“ឡូសអេនជឺឡេសថាមស៍។

នៅក្នុងឯកសារបានដកស្រង់នូវអ្វីដែល អៀង សារី បានឆ្លើយប្រាប់អ្នកកាសែតដូចតទៅ ហើយក៏បង្ហាញរៀបរាប់ថា អ្នកកាសែតនោះបានរាយការណ៍អ្វីខ្លះនៅក្នុងនេះ។

ពួកជនភៀសខ្លួនដែលបានចូលមកដល់ក្នុងប្រទេសថៃបាននិយាយថា មានប្រជាជនរាប់ពាន់នាក់ក្នុងពេលដែលរបបកម្ពុជាបានបណ្ដេញប្រជាជនស្ទើរទាំងអស់ឲ្យចេញពីទីក្រុងភ្នំពេញ ឲ្យទៅកាន់ទីជនបទ។ ដោយសារប្រជាជនទាំងនោះពុំមានការហាត់រៀន និងឧបករណ៍គ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការបាន។ ពួកអ្នកសារព័ត៌មានយូហ្គោស្លាវី និងអ្នកការទូតរបស់ប្រទេសស៊ុយអែតបានធ្វើដំណើរក្នុងប្រទេស

កម្ពុជាកាលពីនិទាឃៈរដូវនេះបាននិយាយថា រដ្ឋធានីភ្នំពេញមើលទៅស្ទើរតែជាក្រុងទទេ ប៉ុន្តែ អៀង សារី បានបដិសេធបញ្ហានេះ ដោយបាននិយាយថា សូមដកស្រង់សម្តី៖ “មានមនុស្សប្រហែលជា ២០ម៉ឺននាក់រស់នៅក្នុងរដ្ឋធានី។ មែនហើយការជម្លៀសទីក្រុងភ្នំពេញដើម្បី -- ដើមឡើយគឺជាវិធានការបណ្តោះអាសន្នតែប៉ុណ្ណោះ។ យ៉ាងណាមិញប្រជាជននាពេលនេះ មានការពេញចិត្តជាមួយនឹងជីវិតនៅជនបទ ហើយពួកគេពុំចង់ត្រឡប់មកទីក្រុងវិញទេ”។ អៀង សារី បាននិយាយដូច្នេះ។ ឧបនាយករដ្ឋមន្ត្រីបាននិយាយថា គាត់មិនបានដឹងថាមានមនុស្សប៉ុន្មាននាក់ស្លាប់ក្នុងការជម្លៀសនោះទេ។ គាត់បាននិយាយថា រឿងរ៉ាវដែលថាមានប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់ ដកស្រង់សម្តី “ គឺជាការប្រឌិតក្នុងគោលបំណងបង្ខូចកេរ្តិ៍ឈ្មោះកម្ពុជាប្រជាធិតេយ្យ”។

ក្រោយពីសង្គ្រាមបានបញ្ចប់ គាត់បានលើកឡើង “៨០ភាគរយនៃប្រជាជនយើង មានជំងឺគ្រុនចាញ់ ហើយពុំអាចដើរបាន។ នេះគឺជាហេតុផលនៃការជម្លៀសទីក្រុងភ្នំពេញ វាគឺជាវិធានការចាំបាច់មួយ ដើម្បីការពារកុំឲ្យប្រជាជនស្លាប់”។ គាត់បាននិយាយថាករណីជំងឺគ្រុនចាញ់ស្ទើរតែទាំងអស់ត្រូវបានព្យាបាលដាច់។

[១៤:០៥:៤៣]

ឯកសារមួយទៀតបន្ទាប់ គឺឯកសារ E3/624 ឯកសារនេះចុះផ្សាយៗនៅក្នុងកាសែតញូវយ៉កថែមស៍ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារនេះមានចំណងជើងថា “បែលហ្គ្រេត យូហ្គោស្លាវី”។ ថ្ងៃទី២៨ ខែកក្កដា ចំណងជើងសរសេរថា “ប្រទេសកម្ពុជានិយាយការពារ ការបិទប្រទេសនៅក្នុងឆ្នាំ៧៥ ថាជាការបង្ការសង្គ្រាមស៊ីវិល”។ ខ្លឹមសារនៃអត្ថបទនេះសរសេរដូចតទៅ៖ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា គឺលោក អៀង សារី បាននិយាយនៅក្នុងថ្ងៃនេះថា ការបិទប្រទេស និងការជម្លៀសទីក្រុងភ្នំពេញ ក្រោយពេលជនកុម្មុយនីស្តចូលកាន់កាប់នៅក្នុងឆ្នាំ១៩៧៥ គឺជាការចាប់បាច់ “ដោយហេតុថា បើមិនធ្វើដូច្នោះទេយើងនឹងអាចមានសង្គ្រាមស៊ីវិល ភាពស្មុគស្មាញ និងភាពលំបាកលំបិនរបស់យើងនឹងកាន់តែរីកធំឡើង”។ គាត់បានមានប្រសាសន៍ដូច្នេះ ហើយប្រជាជននឹងបាត់បង់ជីវិតកាន់តែច្រើន វាអាចនឹងមានសង្គ្រាម ហើយវាបើកទ្វារឲ្យប្រទេសជិតខាងចូលធ្វើការជ្រៀតជ្រែក។

[១៤:០៧:១៥]

នៅក្នុងទំព័រដដែល គឺមានចំណុចដកស្រង់ដូចតទៅ៖ “ការលំបាកក្នុងការផ្គត់ផ្គង់ស្បៀងដល់ប្រជាជនភ្នំពេញ គឺជាហេតុផលដំបូងដែលលើកឡើងដើម្បីជម្លៀសទីក្រុង ហើយលោក អៀង សារី បាន

លើកចំណុចនេះដដែលៗ ប៉ុន្តែលោកបាននិយាយផងដែរថា ជនបដិវត្តន៍បានពិចារណាជាលើកទី១ថា ទីក្រុងពោរពេញដោយគិញ ការទម្លាក់គ្រាប់បែក និងការឃុបឃិតក្នុងការបំផ្លាញរបបថ្មីនេះ។ ហេតុដូច្នេះហើយ យល់ឃើញថាការជម្លៀសទាំងស្រុងជាការចាំបាច់ដើម្បីការពារប្រទេស”។

ខ្ញុំចូលទៅដល់សុន្ទរកថាផ្សេងទៀតរបស់លោក ខៀវ សំផន។ ឯកសារដំបូង គឺឯកសារ D366/7.1.14។ ឯកសារនេះ គឺជាការដកស្រង់ចេញមកពីឯកសារបោះពុម្ពផ្សាយដោយ ស្ទីវិន ហេដឌ័រ មានចំណងជើងថា “ប៉ុល ពត និង ខៀវ សំផន”។ លេខ ERN អង់គ្លេសដែលពាក់ព័ន្ធ គឺ 00087771 គ្មានឯកសារនេះជាភាសាខ្មែរ ឬបារាំងនោះឡើយ។ ខ្ញុំបានដាក់សំណើសុំការបកប្រែជាពីរភាសានោះរួចមកហើយ។

[១៤:០៨:៥៥]

ឯកសារនេះ គឺមានចំណងជើងដូចតទៅ “ខៀវ សំផន និងការរំដោះ”។ ស្ទីវ ហេដឌ័រ បានរៀបរាប់ -- សរសេររៀបរាប់ដូចតទៅ៖ អ្វីដែលបង្ហាញឱ្យយើងឃើញអំពីការបំពាន ការជឿជាក់ដែលគាត់មាន ខៀវ សំផន បានគិតយល់ឃើញថា នៅមុនពេលសង្គ្រាម គឺគាត់ត្រូវបង្កើតបុគ្គលិក មន្ត្រីរដ្ឋការ លន់ នល់ ដើម្បីងាយនឹងសម្លាប់ចោល។ អ្វីដែលគាត់គិតគូរ គឺបានន័យថា អនុញ្ញាតឱ្យពួកគេមួយចំនួនស្ថិតនៅក្នុងស្ថានភាពដែលអាចនឹងបាត់បង់ជីវិត។ ហេតុដូច្នេះបក្សកុម្មុយនីស្តកម្ពុជា បានបោះជំហានទៅមុខ ដើម្បីទទួលជ័យជម្នះផ្នែកយោធាក្នុងរយៈពេល៤ខែដំបូងក្នុងឆ្នាំ១៩៧៤។ លោក ខៀវ សំផន បានលើកផ្តល់ជាសញ្ញាពីរដងទៅដល់អ្នកដែលវាយប្រឆាំងនឹងខ្លួន ក៏ប៉ុន្តែមានមេដឹកនាំតែប្រាំពីររូបកំពូលតែប៉ុណ្ណោះដែលត្រូវតែសម្លាប់ចោល និងឱ្យលុតជង្គង់ដល់ដី។ នៅថ្ងៃទី២៤ លើ ២៥ និងថ្ងៃ ២៥ ខែកុម្ភៈ ខៀវ សំផន ធ្វើជាអធិបតីនៅក្នុងសមាជ ដែលជាកិច្ចប្រជុំរបស់សមាជិកហ្វ្រុងរស់នៅក្នុងប្រទេស ហើយមានតំណាង២៧៣នាក់ របស់ហ្វ្រុង និងកងទ័តក៏បានចូលរួម។ សមាជបានប្រកាសថាជនក្បត់ទាំងប្រាំពីរនាក់ត្រូវតែស្លាប់ ហើយអ្នកដែលនៅក្នុងរបបសាធារណរដ្ឋខ្មែរអាចចូលរួមជាមួយនឹងសម្តេចសីហនុបាន។

[១៤:១១:០៦]

យើងឃើញមានឯកសារចំណុចនេះដកស្រង់នៅក្នុងហ្វីប៊ីសផងដែលពាក់ព័ន្ធទៅនឹងការបញ្ជាឱ្យសម្លាប់ជនក្បត់ទាំងប្រាំពីរនាក់នោះ។ ឯកសារហ្វីប៊ីសនេះគឺមានលេខ E3/117 ចុះថ្ងៃ២៦ ខែកុម្ភៈ ឆ្នាំ ៧៥។ បន្ទាប់មកនៅថ្ងៃទី១ ខែមេសា ឆ្នាំ៧៥ ពីរសប្តាហ៍មុនពេលទីក្រុងភ្នំពេញត្រូវបានចាប់យក ខៀវ

សំផន បានថ្លែងនៅក្នុងការផ្សព្វផ្សាយវិទ្យុរបស់រណសិរ្សថា ដោយក្នុងនោះគាត់វាយប្រហារបុគ្គលទាំងប្រាំពីររូបនោះរួមទាំងអ្នកដែលនៅក្នុងរបបសាធារណរដ្ឋដាក់អាវុធចុះដើម្បីចូលរួមជាមួយនឹងខ្លួន។ គឺជាការចុះផ្សាយនៅថ្ងៃទី០១ ខែមេសា ឆ្នាំ៧៥ ឯកសារគឺឯកសារ E3/118។

ខ្ញុំនៅពេលនេះលើកឡើងអំពីឯកសារ E3/216 គឺឯកសារពាក់ព័ន្ធនឹងការជម្លៀសដំណាក់កាលទី១។ អង់គ្លេស ERN 00850974, ខ្មែរ 00008487, បារាំងមានលេខ 00343375 ជាចំណុចដកស្រង់ចេញមកពីកំណត់ហេតុនៃទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅតាមភូមិភាគនៅថ្ងៃទី២០ ដល់ថ្ងៃទី២៤ ខែសីហា ឆ្នាំ៧៥។ ចំណងជើងសរសេរថា សភាពការណ៍សេដ្ឋកិច្ចបង្កបង្កើនផល និងកសិកម្មដំណាំស្រូវ។ “បានជំរុញនៅគ្រប់កន្លែង ដីចាស់បានធ្វើទាំងអស់ កន្លែងខ្លះថែមដីទៀត។ កន្លែងភាគច្រើនធ្វើរួចហើយស្រែពង្រោះ ស្រូវសន្ទូង គឺធ្វើនៅបាត់ដំបង។ ស្រែជាច្រើនមានប្រឡាយ និងលើកភ្លឺជាកង់ៗបញ្ហាទឹកម្ចាស់ការបានមួយកម្រិត”។

[១៤:១៤:១៣]

ចំណុចដកស្រង់បន្ទាប់ គឺអង់គ្លេស 00850975, ខ្មែរ 00008488 ដល់ 89, បារាំងមានលេខ 00343376 ក្រោមចំណងជើងថា មតិណែនាំរបស់អង្គការ ការងារការពារប្រទេស។ “និយាយឲ្យជាក់លាក់ទៅ យើងត្រូវពង្រឹងនិងពង្រីកសហករណ៍ និងធ្វើការសាមគ្គីជាធ្លុងមួយជារដ្ឋអំណាចបដិវត្តន៍”។ ហើយនៅក្នុងទំព័រដដែល “មុខងារសហករណ៍តាំងពីរំដោះមក គឺដើម្បីប្រមូលប្រជាជនថ្មីមកពី តាមក្រុង និងខេត្តផ្សេងៗ។ ជាពិសេសប្រជាជនមកពីក្រុងភ្នំពេញហើយនិងនៅពាយ័ព្យគឺបាត់ដំបង។ ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបងមានសមាសភាពអាក្រក់គ្រប់យ៉ាង។ ក៏ប៉ុន្តែសហករណ៍ស្រូបអស់ផ្គត់ផ្គង់ស្បៀងព្រមទាំងចាត់ចែងកម្លាំងធ្វើការងារទៀត។ អានុភាពសហករណ៍ខ្លាំងក្លាណាស់។ ដូច្នេះត្រូវពង្រឹងពង្រីកសហករណ៍ថែមទៀត”។

យើងចូលទៅដល់អង់គ្លេស 00850976, ខ្មែរ 00008490, បារាំង 00343377 ដល់ 78 មានសំណួរចោទសួរថា “តើត្រូវដោះស្រាយយ៉ាងដូចម្ដេច? ប្រជាជនគេមានសង្ឃឹម។ នៅពាយ័ព្យលក្ខណៈភូមិសាស្ត្រអំណោយណាស់គេឃើញច្បាស់។ ប្រជាជនចាស់គេរីករាយណាស់ ឯប្រជាជនថ្មីក៏រីករាយ។ នៅពាយ័ព្យគេសង្ឃឹមច្រើន។ ១ឆ្នាំ ២ឆ្នាំទៅទៀត ជីវភាពនឹងឡើង សភាពការណ៍ប្លែកស្រែប្រែប្រួល ទឹកប្រែប្រួល ស្បៀងសំបូរសប្បាយ ហើយកាន់តែឡើងខ្ពស់ទៅទៀត”។

[១៤:១៧:០១]

ឯកសារដដែលខ្ញុំលើកឡើងត្រង់ទំព័រ 00850977, ខ្មែរ ERNគឺ 00008491 ដល់ 92, បារាំងមានលេខ 00343378 ដល់ 79 ក្រោមចំណងជើងថា “បញ្ហាសេដ្ឋកិច្ចបង្កបង្កើនផល”។

“ទិសរបស់បក្សគឺបង្កបង្កើនផល និងកសាងប្រទេស។ ត្រូវចែកកម្លាំងដែលមានដីទំនេរ ឱ្យបង្កបង្កើនផលផង ការពារប្រទេសផង។ ម្យ៉ាងទៀត ត្រូវប្រមូលកម្លាំងទៅកន្លែងណាដែលមានលទ្ធភាពជាងគេ គឺធ្វើបានតិចបាន ផលច្រើនដើម្បីវាយសម្រុករកទុនកសាងប្រទេសជាបន្តបន្ទាប់។ ដូច្នេះ ឧត្តរ និងពាយ័ព្យ ពិសេសគឺពាយ័ព្យដែលមានលក្ខណៈសម្បត្តិល្អច្រើនជាងគេខាងភូមិសាស្ត្រដីស្រែ ល្អហើយសល់ច្រើន ត្រូវទទួល ប្រជាជនថែមទៀត។ ទី២ មានទុនជាស្រូវអាចចិញ្ចឹមប្រជាជនថ្មី។ ទី៣ មានទុនជាឧបករណ៍ផ្សេងៗ។ យើងវាយសម្រុកបង្កបង្កើនផលនៅពាយ័ព្យដើម្បីដោះស្រាយជីវភាពប្រជាជនទូទាំងប្រទេស។ រកទុនថ្មី ទិញឧបករណ៍កសាងប្រទេស និងបង្កបង្កើនផលកសិកម្មនិងឧស្សាហកម្ម។ បើយកកម្លាំងទៅកន្លែង ផ្សេងដែលមានលទ្ធភាពតិចនោះយើងនឹងខាតទាំងប៊ី ទាំងស្គរ។ មាគ៌ាប្រយុទ្ធរបស់យើងមិនត្រូវ។ ដូច្នេះ ត្រូវប្រយុទ្ធត្រង់ណាដែលមានប្រសិទ្ធភាព ព្រោះយើងអនុវត្តនយោបាយខ្លួនឧបត្ថម្ភខ្លួន។ យើងត្រូវរកទុនដោយខ្លួនយើង”។

[១៤:១៩:៣៨]

ហើយក្រោមចំណងជើងតូចដាក់ថា “ការរៀបចំកម្លាំងមនុស្ស” បានសរសេរថា “ពាយ័ព្យមានស្ថានភាពល្អ និងមិនល្អដូចខាងក្រោម។ ស្ថានភាពល្អ លក្ខណៈសម្បត្តិងាយស្រួលគឺដីល្អ ជាទូទៅមិនបាច់ប្រើជីក៏ល្អ។ វាលរាបល្វឹងល្វើយ គ្មានភ្នំ ងាយស្រួលឱ្យយើងចាត់ចែងកម្លាំងភ្ជួររាស់ និងប្រើប្រាស់ទឹក។ មានកម្លាំងមនុស្សដែរ យើងបន្ថែមទៀតរឹតតែល្អ កម្លាំងនេះមានពិសោធន៍បង្កបង្កើនផល។ មានឧបករណ៍ម៉ាស៊ីនខ្លះ”។ នៅក្រោមចំណងជើងតូចដាក់ថា “ចំណុចខ្វះខាត ឬក៏ត្រូវចាប់អារម្មណ៍៖ ចំណុចទី១ សរសេរថា មិនទាន់ម្ចាស់ការលើទឹក។ ទី២ សរសេរថា កម្លាំងមនុស្សមិនគ្រប់ ត្រូវបន្ថែមកម្លាំងពលកម្ម ៣ ឬ៤សែនទៀតក៏មិនគ្រប់។ កម្លាំង១លាននាក់បច្ចុប្បន្នធ្វើមិនបាន៥០ភាគរយទេ ត្រូវថែម៤ ឬ៥សែនទៀត”។

[១៤:២១:០៣]

ឯកសារបន្ទាប់ គឺឯកសារ E3/781។ ឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា ចុះខែកញ្ញា ឆ្នាំ ១០៧៥ *(ស៊ីក)*។ ខ្មែរ 00072367, បារាំង 00543745, អង់គ្លេសមានលេខ 00523569។ ចំណងជើងឯកសារនេះសរសេរថា “ពិនិត្យ ការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំ

កសាងប្រទេសគ្រប់ផ្នែក”។ បន្ទាប់មកយើងមានចំណងជើងតូចដាក់សរសេរថា “ការក្តាប់ និងអនុវត្តមាគ៌ានយោបាយកសាងកសិកម្មរបស់បក្ស។ សំណូមពរ ពិនិត្យមើលការក្តាប់ ការជ្រួតជ្រាប និងការអនុវត្តនូវមាគ៌កសិកម្មរបស់បក្ស ដើម្បីជំរុញកសិកម្មនេះឲ្យបានចម្រើនលោតផ្លោះជាអតិបរិមាតាមទិសណែនាំរបស់បក្ស”។

ខាងក្រោមហ្នឹងបន្តិចត្រង់ទំព័រនេះដដែលសរសេរថា “យើងត្រូវត្រៀមខ្លួនឲ្យលឿនរួចជាស្រេចគឺកែប្រែពីកសិកម្មអន់ថយទៅកសិកម្មសម័យពី១០ទៅ១៥ឆ្នាំ នេះជាសំណូមពរ។ បើមើលពេលវេលានេះយើងឃើញរហ័សណាស់”។

ទំព័របន្ទាប់អង់គ្លេសមានលេខ 00523570, ខ្មែរមានលេខ 00072368, បារាំងមានលេខ 00543745។ “សំណូមពរលើកឡើងនេះមានកម្រិតធ្ងន់ណាស់ យើងត្រូវធ្វើប្រញាប់ប្រញាល់មែនទែនដើម្បីសម្រេចសំណូមពរនេះ។ បញ្ហានេះទាមទារការរៀបចំកម្លាំងគ្រប់ផ្នែកឲ្យដើរជាខ្សែចង្វាក់មែនទែន ម៉ាស៊ីន ជីរ ទឹក ។ល។ បន្ថែមពីនេះយើងមានសហករណ៍ដែលជាទ្រព្យសម្បត្តិរបស់យើង ងាយស្រួលសម្រាប់រៀបចំអ្វីទាំងអស់។ ថ្ងៃនេះយើងមានម្ចាស់ការលើសហករណ៍ ប្រជាជន និងសហករណ៍រដ្ឋ”។

[១៤:២៤:០៥]

ក្នុងឯកសារដដែល អង់គ្លេស ERN 00523574, ខ្មែរ ERN 00072373, បារាំង 00543749 ដល់ 50។ បានសរសេររៀបរាប់ថា “កន្លែងដែលយើង -- យើងធ្វើភ្លឺសម្រាប់អ្វី គឺមិនមែនតែសម្រាប់ទឹក ជីរ ប៉ុណ្ណោះទេ គឺសម្រាប់កន្លែងដែលមិនសូវទាន់មានទិន្នផល”។ ទំព័រខាងក្រោម “នៅបាត់ដំបងក្នុងឆ្នាំ៧៦ យើងត្រូវតែមានទឹកនៅតាមតំបន់វាលទំនាប ព្រោះនៅតាមតំបន់វាល់ទំនាបភាគច្រើនមានប្រភពទឹកជាប្រចាំ”។

ចូលទៅដល់អង់គ្លេស ERN មួយទៀត 00523576, ខ្មែរ 00072376, បារាំង 00543752។ “តាមការប៉ាន់ស្មានកម្លាំងពលកម្មសព្វថ្ងៃ៥លាននាក់។ កម្លាំងនេះដកយកទៅធ្វើការងារផ្សេងទៀតនៅសល់តែ ៤លាន ៧សែននាក់។ ក្នុងកម្លាំងនេះយកមួយចំនួនទៅខាងផលិតកៅស៊ូ ចម្ការអំពៅ នៅសល់តែ៤លាននាក់។ ត្រូវធ្វើដី៣លានហិកតា។ បើពង្រីកទៅទៀតឡើង៤លានហិកតា”។

អង់គ្លេស ERN នៅក្នុងឯកសារដដែលគឺ 00523580, ខ្មែរ 00072382, បារាំង 00543755 ដល់ 56។ “នៅតំបន់១៥ ត្រូវមានទិសយកកម្លាំងប្រជាជន៣ ឬ៤ម៉ឺនមកធ្វើនៅតាមផ្លូវលេខ៥។ កន្លែងនេះធ្វើបាន១ហិកតា ៤តោន។ នៅពាយ័ព្យអាចធ្វើបាន៣ ទៅ៤តោន”។

[១៤:២៧:១០]

នៅក្នុងឯកសារដដែល ERN ជាភាសាអង់គ្លេស 00523590, ខ្មែរ 00072397, បារាំង 005437 (សូមហៅ ERN ជាភាសាបារាំង ឡើងវិញ)គឺ 00543766។

"នៅពាយ័ព្យត្រូវការបន្ថែមកម្លាំង៥សែននាក់ទៀត។ ព្រះវិហារស្នើ៥ម៉ឺនចំពោះមុខសិន។ នៅព្រះវិហារមានលទ្ធភាពដោះស្រាយស្បៀងបាន ព្រះវិហារមានប្រជាជនចាស់៧ម៉ឺននាក់។ ដូច្នេះបណ្ដើរៗជូន២ម៉ឺនសិន"។

ទំព័រដដែល អង់គ្លេសមានលេខ 00523591 បានសរសេរទៀតថា "នៅឧត្តរគេត្រូវការមនុស្សឲ្យទៅខាងកំពង់ធំ ខាងបូព៌ាក៏ត្រូវការកម្លាំងផងដែរដែលត្រូវផ្ដល់ទៅឲ្យតំបន់ដែលខ្វះមនុស្ស។ ដូច្នេះភូមិភាគនីមួយៗត្រូវរៀបចំឲ្យសមស្រប កុំឲ្យឃ្លោងម្ខាងៗ។ លែសល់ប៉ុន្មានខាងលើនឹងឥតយកទៅចែកកន្លែងផ្សេងៗទៀត"។ ឯកសារបន្ទាប់គឺ E190.1.318 គឺជាអត្ថបទសរសេរដោយអ្នកសារព័ត៌-មានឈ្មោះ វីល្លៀម សក្រូស ចុះនៅក្នុងទស្សនាវដ្ដី ហ្វាអ៊ីស្ទើនរីវ្យូ ចុះឆ្នាំ១៩៧៦។ តំបន់គឺត្រង់ទំព័រ S00708573, បារាំង 00780515, អង់គ្លេសគឺ S00005151។

[១៤:២៩:៥៣]

"ចូរដាំ ដាំគ្រប់យ៉ាង ការចាប់អារម្មណ៍ជាពិសេសត្រូវផ្ដោតលើស្រូវតែប៉ុណ្ណោះ។ ស្រូវជាអ្វីៗគ្រប់យ៉ាងៗ។ ស្រូវមានន័យថា ជាដែក ជារោងចក្រ ជាថាមពល ជាប្រេងឥន្ធនៈ និងជាត្រាក់ទ័រ។ នៅតំបន់ខ្លះ ព្រះវិហារ ជាឧទាហរណ៍ស្ថានភាពអាក្រក់ណាស់។ ទោះបីជាបច្ចុប្បន្ននេះ ទិន្នផលស្រូវបច្ចុប្បន្នចាត់ទុកជាទិន្នផលដែលល្អបំផុតរកគ្មាន ទោះបីជាគេត្រូវដាំវានៅចុងដៃដោយកម្លាំងពលកម្មគ្មានជំនាញ និងគ្មានឆន្ទៈក៏ដោយ។ អៀង សារី បានប្រាប់រដ្ឋាភិបាលថៃថា កម្ពុជាបានប្ដេជ្ញានឹងក្លាយជាប្រទេសដែលមានស្រូវគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ត្រូវការខ្លួនឯង"។ ហើយការនេះជាមធ្យោបាយមួយដែលជាកត្តាទី២នាំដល់ការជម្លៀសប្រជាជន។

ជនភៀសខ្លួននិយាយថា "២ខែមុន ប្រជាជនប្រមាណ៣០០.០០០នាក់ដែលត្រូវបានជម្លៀសពីភ្នំពេញនោះ ត្រូវបានជម្លៀសសាជាថ្មី ដែលលើកនេះត្រូវគេជម្លៀសទៅខេត្តបាត់ដំបង។ ការធ្វើការដំណើរការត្រូវគេឃើញថា ធ្វើដោយផ្នែកៗ ខ្លះតាមទូក ខ្លះតាមរថភ្លើង។ មានប្រជាជនល្មមតែប៉ុណ្ណោះដែលត្រូវគេទុកឲ្យធ្វើការនៅក្នុងខេត្តភាគខាងត្បូង និងភាគខាងកើតទីក្រុងភ្នំពេញ ដើម្បីច្រូតស្រូវដែលបានដាំកាលពីដើមរដូវក្ដៅ។ ចំណែកអ្នកដែលនៅសល់ពីនោះ គឺគេត្រូវបញ្ជូនទៅតំបន់ដីដែលមាន

ជីវជាតិបំផុតក្នុងប្រទេសដើម្បីពង្រីកទិន្នផលស្រូវនារដូវប្រាំងឆ្នាំក្រោយ"។

[១៤:៣០:៣៩]

ឯកសារបន្ទាប់គឺឯកសារលេខ D199/26.2.184។ ខ្ញុំនៅសល់តែបីឯកសារទៀតទេ។ ឯកសារនេះ គឺឯកសារបោះពុម្ពផ្សាយចុះនៅក្នុងកាសែតភ្នាក់ងាររបស់បារាំង។ ឯកសារមានចំណងជើងថា "កម្ពុជា, របាយការណ៍របស់កាសែតញូវយ៉ក ស្តីអំពីការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត ដែលបង្កគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស"។ អង់គ្លេសគឺមានលេខ 00519810, ខ្មែរ 00548749, បារាំង 00389829។ នៅតាមព្រំដែនថៃឈ្មោះ អារញ្ញប្រថេត បានរាយការណ៍ថា "ប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានជម្លៀសដោយបង្ខំសាជាថ្មីពីទីកន្លែងមួយទៅកន្លែងថ្មីមួយទៀតក្នុងប្រទេស ហើយមានអ្នកជម្លៀសមួយចំនួនធំបានបាត់បង់ជីវិតក្នុងដំណើរជម្លៀសដ៏សែនលំបាកនោះ។ ប្រជាជនភាគច្រើនត្រូវបានគេបង្ខំផ្លោះទៅកាន់តំបន់ដែលពុំសូវមានប្រជាជន និងមានការវិវឌ្ឍតិចតួចនៅខេត្តបាត់បង។ យោងតាមអ្នកជម្លៀសមួយដែលបានលើកឡើងនៅក្នុងខែ ថ្ងៃទី០៦ ខែមករា បានឲ្យដឹងថា ប្រជាជនដែលត្រូវបានគេជម្លៀសនោះ ភាគច្រើន គឺជាកសិករ មានជំងឺសង្កាត់ ដូចជាគ្រុនចាញ់ គ្រុនពោះវៀន អាសន្នរោគ រាកមួលជាដើម"។

[១៤:៣៣:៤៥]

បើតាមសម្តីរបស់ជនភៀសខ្លួនម្នាក់ដែលជាគិលានុបដ្ឋាកអាយុ៣៣ឆ្នាំបានឲ្យដឹងថា "មានប្រជាជនភៀសខ្លួនចំនួន៦០០នាក់ បានសម្លាប់ក្នុងខែដែលពួកគេបានមកដល់តំបន់ភ្នំស្រុក ដែលគាត់ក៏ស្ថិតនៅទីនោះដែរ"។ ការជម្លៀសប្រជាជនដោយបង្ខំជាថ្មីម្តងទៀត បានធ្វើឡើងក្នុងទ្រង់ទ្រាយធំ ដូចការជម្លៀសប្រជាជននៅភ្នំពេញ កាលពីខែមេសាមុនដែរ នឹងត្រូវគេចាប់ផ្តើមអនុវត្តនាដំណាច់ខែតុលា ដើមវិច្ឆិកា។

យោងសក្ខីកម្មនានាដែលប្រមូលបានដោយកាសែតញូវយ៉កថាមស៍ "ជនដែលត្រូវគេជម្លៀសទទួលបានបាយបរិភោគតិចតួចប៉ុណ្ណោះ ហើយពួកគេស្ថិតនៅក្រោមការឃ្លាំមើលរបស់កងទ័ពប្រដាប់អាវុធ។ អ្នកធ្វើដំណើរដោយរថភ្លើងត្រូវបានគេញាត់ក្នុងទូរថភ្លើងដូចទំនិញណែនក្តន់ ហើយប្រៀបដូចជាត្រីខកំប៉ុង។ អ្នកជម្លៀសផ្សេងទៀតត្រូវបានគេជម្លៀសដោយថ្មើរជើង ដោយរទេះគោ ឬដោយរថយន្តកាំម៉ុង។ ក្នុងចំណោមអ្នកទាំងនោះ មួយភាគធំបានស្លាប់បាត់បង់ជីវិត ដោយសារជំងឺ ឬក៏ដោយសារភាពទ្រុឌទ្រោមក្នុងពេលធ្វើដំណើរជាច្រើនយប់ ច្រើនថ្ងៃនោះ"។

[១៤:៣៥:០៩]

ឯកសារមួយទៀត ឯកសារលេខ E3/1181។ ជាឯកសារបក្សកុម្មុយនីស្តកម្ពុជា មានចំណងជើងថា "ការយល់ឃើញជារួមលើតំបន់៥ ភូមិភាគពាយព្យ" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧។ អង់គ្លេស ERN 00223175, ខ្មែរ 00214486, បារាំង 00612289។ ខ្ញុំក៏គិតថា វាក៏ពាក់ព័ន្ធនឹងឯកសារទំព័រត្រង់មួយទំព័រផ្សេងទៀតផងដែរ។ "ទិដ្ឋភាពរួមនៅស្រុកនីមួយៗ ថ្មពួកប្រជាជនភាគច្រើននៅក្នុងស្រុកនេះទើបតែរំដោះក្នុងខែ១ -២-៧៥ ហើយនិងប្រជាជនក្រោយ១៧ ស្មើរតែ១០០ភាគរយ"។

ចំណុចទី២ ត្រង់អង់គ្លេស 00223176, ខ្មែរ 00214489, បារាំងមានលេខ 00612290។ "ស្រុកស៊ីសុផុន ប្រជាជនមានជាង៥០.០០០នាក់ ថ្មីស្មើរតែ១០០ភាគរយ"។ នៅខាងក្រោមនេះបន្តិចនៅភ្នំស្រុកមានប្រជាជនជាង៧០.០០០នាក់, ប្រជាជនចាស់មានប្រហែល៣០០គ្រួសារ, ទៅពីភ្នំពេញប្រហែល៥០.០០០ផ្លាយ, ប្រជាជនថ្មីក្នុងស្រុកមានជាង២០.០០០នាក់។ ចំណុចទី៤ ព្រះនេត្រព្រះប្រជាជនមុន ១៧មេសា មាន១៥០គ្រួសារ ចេញទៅពីភ្នំពេញជាង ៧០.០០០នាក់"។

អង់គ្លេស 00223177, ខ្មែរ 00214490 និងបារាំង 00612292។ គឺមានចំណុចដកស្រង់ដូចតទៅ "វាជាកន្លែងដែលអត់ឃ្លានខ្លាំងបំផុត ឆ្នាំទៅស្លាប់អស់ជាង ២០.០០០នាក់"។

[១៤:៣៨:០២]

ឯកសារចុងក្រោយនៅក្នុងការបង្ហាញរបស់យើងខ្ញុំ លើកលែងតែមានសេចក្តីសន្និដ្ឋានផ្សេងទៀតដែលនឹងធ្វើឡើងដោយសហសេវិករបស់ខ្ញុំ ដែលមេធាវីការពារក្តីគាត់នឹងអាចលើកឡើង គឺលោកស្រីហ្គីសសេ គឺឯកសារ D -- សូមអធ្យាស្រ័យ ខ្ញុំសូមរៀបរាប់ឡើងវិញ។ ឯកសារនេះ គឺឯកសារ E3/3316 គឺឯកសារផ្សព្វផ្សាយចេញពី អេមណាស់ស្ទី អ៊ិនធឺណាស់ស្យូណល គឺជាឯកសារថ្មីចុះនៅក្នុងទីក្រុងញូវយ៉កថ្ងៃទី២០ -- ថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៨។ ចំណុចដកស្រង់នោះ គឺមានសរសេរដូចតទៅ៖ "អ្នកសង្កេតការណ៍មួយចំនួនបានចង្អុលបង្ហាញថា វាអាចកើតឡើងថា ប្រជាជនជាច្រើនណាស់បានបាត់ខ្លួនផ្អែកតាមការជម្លៀសដោយបង្ខំឲ្យទៅធ្វើការនៅតំបន់ដាច់ស្រយាល។ រហូតមកដល់បច្ចុប្បន្ននេះមានរបាយការណ៍ស្តីពីទេសន្តប្រវេសន៍ ដោយបង្ខំឥតឈប់ឈរ។

លោកប្រធានជាទីគោរព ខ្ញុំសូមលើកឡើងឯកសារ មួយដែលយើងកំពុងតែពិនិត្យមើលអម្បាញ់មិញនេះ។ ខ្ញុំទទួលបានអ៊ីម៉ែលបញ្ជាក់ពីខាងសហសេវិករបស់ខ្ញុំពីការការិយាល័យរបស់ខ្ញុំ លើកលែង -- ទោះបីជាមានការលើកឡើងយោបល់របស់ខ្ញុំក៏ដោយ ឯកសារនេះមិនបានលើកឡើងនៅក្នុងសេចក្តីសន្និ-ដ្ឋានចុងក្រោយ និងដីកាដំណោះស្រាយនោះទេ ហើយវាក៏មិនមាននៅក្នុងបញ្ជីតាមវិធាន៨០របស់យើងខ្ញុំ

ផងដែរ ក៏ប៉ុន្តែដោយសារតែខ្លឹមសារនៃឯកសារនេះមិនទាន់សម្រេចដោយអង្គជំនុំជម្រះនៅឡើយនោះទេ ដូច្នេះខ្ញុំសូមស្នើសុំតំណាងឲ្យការិយាល័យសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងបញ្ញើតាមវិធាន៨០នេះគឺថា នឹងត្រូវគិតថា នឹងត្រូវបានបញ្ចូលនៅក្នុងសំណុំរឿង ហើយអង្គជំនុំជម្រះត្រូវពិចារណាសម្រេចទទួលយកបាន ឬក៏មិនទទួលយកបាន។ ហើយប្រសិនបើសម្រេចទទួលយកបាន សូមឲ្យអង្គជំនុំជម្រះពិចារ-ណាលើឯកសារមួយដែលខ្ញុំបានលើកឡើងខាងដើម។ នេះគឺដល់ពេលក្រុមយើងខ្ញុំបញ្ចប់ហើយ ក៏ប៉ុន្តែខ្ញុំសូមនិយាយជារួមមកថា ខ្ញុំមានបំណងផ្ញើជូនទៅដល់ភាគីនិងអង្គជំនុំជម្រះអំពីឧបសម្ព័ន្ធ និងចំណុចដែលខ្ញុំយោងទៅលើឯកសារអម្បាញ់មិញហ្នឹង ថាតើវាមានលេខ ERN អ្វីខ្លះ ហើយនិងមានលេខឯកសារនេះយ៉ាងម៉េចខ្លះ។ នេះជាសំណើរបស់ខ្ញុំថាយើងខ្ញុំមានបំណងចង់ផ្ញើឯកសារ ដែលខ្ញុំបង្ហាញនេះទៅដល់ភាគីនិងអង្គជំនុំជម្រះ លើកលែងតែខាងមេធាវីការពារក្តីជំទាស់មិនចង់បានឯកសារដែលខ្ញុំបង្ហាញនេះ ទើបខ្ញុំនឹងមិនផ្ញើជូន។ សូមអរគុណ។

[១៤:៤១:៣៤]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះចង់ឲ្យយើងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញដែលសុំដាក់ឯកសារថ្មីនេះដែរឬក៏អត់? ព្រោះថាឯកសារនេះយើងខ្ញុំសូមជំទាស់ ឬក៏អង្គជំនុំជម្រះចង់ឲ្យយើងឆ្លើយនៅពេលក្រោយ ឬក៏ឆ្លើយតាមឯកសារលាយលក្ខណ៍អក្សរ ព្រោះថាបើខ្ញុំយល់មិនច្រឡំទេនោះ គឺថាព្រះរាជអាជ្ញាបានទទួលស្គាល់ហើយថា ឯកសារនេះពុំធ្លាប់ដែលបានដាក់មកពីមុនទេ ពីសំណាក់ខាងការពារក៏ដោយ ពីសំណាក់ខាងព្រះរាជអាជ្ញាក៏ដោយ។ អ៊ីចឹងខ្ញុំសូមឲ្យអង្គជំនុំជម្រះជួយបំភ្លឺថាតើឲ្យខ្ញុំធ្វើសំណើធ្វើការជំទាស់ឥឡូវនេះ ឬក៏សំណើជាលាយលក្ខណ៍អក្សរនៅពេលក្រោយ? សូមអរគុណលោកប្រធាន។

[១៤:៤២:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៤:៣០]

**ប្រធានអង្គជំនុំ៖**

បាទ សូមជម្រាបជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន ថាចំពោះការឆ្លើយតបនេះសូមលោកស្រីមេធាវីប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះចែកឲ្យ។ ដល់វេនពេលវេលាសម្រាប់មេធាវី

ការពារក្តីលោក ខៀវ សំផន សម្រាប់ធ្វើការកត់សម្គាល់ ឬធ្វើអត្ថាធិប្បាយលើបណ្តាលឯកសារទាំងឡាយដែលភាគីសហព្រះរាជអាជ្ញា ឬក៏ភាគីដទៃទៀតដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយចំពោះពេលវេលាគឺអង្គជំនុំជម្រះនឹងពិនិត្យតាមស្ថានភាពនៃតម្រូវការជាក់ស្តែងនៃការងាររបស់ក្រុមការងាររបស់ក្រុមមេធាវីការពារក្តីរឿងក្តីរបស់លោក ខៀវ សំផន។

បាទ ឥឡូវនេះដល់ពេលសម្រាក អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកសិនចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៧ នាទី)*

[១៥:០៧:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអង្គជំនុំជម្រះសូមរំឭកជម្រាបជូនភាគីពាក់ព័ន្ធថា ក្នុងការបង្ហាញឯកសារពាក់ព័ន្ធជាមួយអង្គហេតុសហឧក្រិដ្ឋកម្មរួម ហើយនិងតួនាទីរបស់ជនជាប់ចោទ ភាគីខាងសហព្រះរាជអាជ្ញានិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺប្រើប្រាស់ពេលវេលារួមនៅក្នុងការបង្ហាញឯកសារតែម្តងដើម្បីអង្គជំនុំជម្រះទុកពេលវេលាសមស្របសម្រាប់ភាគីមេធាវីការពារក្តីពិនិត្យនឹងមានពេលវេលាសមស្របសម្រាប់ឆ្លើយតបទៅនឹង ឬក៏ធ្វើការកត់សម្គាល់ទៅលើបណ្តាឯកសារដែលដាក់បង្ហាញដោយសហព្រះរាជអាជ្ញានិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ បញ្ហាទីពីរ គឺអង្គជំនុំជម្រះសាជាថ្មីម្តងទៀត តែអម្បាញ់មិញនេះគឺមានបញ្ហាបន្តិចបន្តួច គឺអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើការបញ្ជាក់បន្ថែមអំពីសំអាងហេតុនៃសំណើសុំដាក់ឯកសារថ្មីតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ។

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។ ប្រវត្តិនៃឯកសារនេះគឺមានដូចតទៅនេះ គឺថាឯកសារនេះមិនមាននៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយ ហើយក៏មិនមាននៅក្នុងដីកាបញ្ជូនផងដែរ។ គឺមិនមាននៅក្នុង

ឯកសាររបស់សហព្រះរាជអាជ្ញានោះទេ។ ខ្ញុំគិតថាប្រហែលជាមានបញ្ហាជាមួយកាសរបស់លោកប្រធាន ដូច្នេះខ្ញុំសូមចាប់ផ្តើមតទៅទៀត គឺមិនមាននៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយនោះឡើយ ហើយក៏មិនមាននៅក្នុងសំណើរបស់ព្រះរាជអាជ្ញាតាមវិធាន៨០នោះដែរ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតដាក់ឯកសារនេះយោងទៅតាមវិធាន៨៧(៤) ដោយផ្អែកទៅលើមូលដ្ឋានដើម្បីផលប្រយោជន៍យុត្តិធម៌។ ហើយខ្ញុំក៏មិនដឹងថាហេតុអ្វីបានជាឯកសារនេះមិនត្រូវបានដាក់បញ្ចូលនៅពេលដំបូងនោះឡើយ។ ដូច្នេះជាដំបូងខ្ញុំសូមធ្វើការសង្ខេបទៅលើឯកសារនេះ ឯកសារនេះគឺបានលើកឧទាហរណ៍ចំនួន១៥ ដែលមានចំណងជើងថា “អំពើយង់ឃ្នងរបស់កម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា” ទាក់ទងទៅនឹងការជម្លៀស និងការសម្លាប់ប្រជាជន ហើយក៏មានការយោងទៅលើព័ត៌មានរបស់ជនភៀសខ្លួន ព្រមទាំងអត្ថបទសារព័ត៌មានដែលមាននៅក្នុងសារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ផងដែរ ក៏ដូចជាសារព័ត៌មាន ឈីកាហ្គោ ទ្រីប្យូន, គ្រីស្ទៀន សាយអិន ម៉ូនីទ័រ, ក៏ដូចជាសារព័ត៌មានវ៉ាស៊ីនតោនស្តាញូវ។ ក្រៅពីនេះក៏មានការដកស្រង់សារព័ត៌មានរបស់ខាងស្ថានទូតអាមេរិក ក៏ដូចជាសារព័ត៌មានរបស់ប្រទេសឡាវ។

ដូច្នេះ ខ្ញុំគិតថាឯកសារនេះគឺវាមានភាពពាក់ព័ន្ធយ៉ាងខ្លាំងចំពោះការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយខ្ញុំគិតថា វាអាចបង្កើតជាមូលដ្ឋានដើម្បីឲ្យព្រះរាជអាជ្ញាអាចស្នើសុំដាក់ឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១២:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខាងព្រះរាជអាជ្ញាគួរបញ្ជាក់ឲ្យបានច្បាស់បន្តិច តើលោកអាចបញ្ជាក់ឡើងវិញទេ ថាតើឯកសារដែលលោកនិយាយយោងហ្នឹង គឺឯកសារអ្វីខ្លះ?

**លោក ឃីត រេយ៍ន័រ៖**

ឯកសារដែលខ្ញុំចង់បញ្ជាក់ គឺមានលេខដូចតទៅ D366/7.1.366 ហើយនេះគឺជាអនុស្សរណៈរបស់ក្រុមប្រឹក្សាសន្តិសុខជាតិនៃសហរដ្ឋអាមេរិក គឺរបស់ ស្វេនក្រេម៉រ ដែលផ្ញើដោយ ក្រេមម៉រ ទៅប៊ីល ខេនឌល ដែលចុះថ្ងៃទី១៧ មីនា ឆ្នាំ១៩៧៥។

លោកស្រីចៅក្រម ខាតវ៉ាយថ៌ តើខ្ញុំបានឆ្លើយនូវសំណួររបស់លោកស្រីហើយឬនៅ?

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

ចាស អរគុណ គឺលោកបានឆ្លើយនូវសំណួររបស់ខ្ញុំហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៥:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះនឹងផ្តល់ឱកាសដល់ភាគីដទៃទៀតដើម្បីឆ្លើយតបទៅនឹងសំណើសុំផ្ទាល់មាត់នេះនៅពេលដែលភាគីដទៃទៀតមានឱកាសក្នុងការលើកបង្ហាញពីឯកសារដទៃទៀត។ ប៉ុន្តែខ្ញុំមានបញ្ហាមួយចុងក្រោយចំពោះលោកព្រះរាជអាជ្ញា។ ការបង្ហាញរបស់លោកទាក់ទងទៅនឹងឯកសារហ្នឹងត្រូវបានកាត់ផ្តាច់ដោយភាគីម្ខាង។ ដូច្នេះប្រសិនបើអង្គជំនុំជម្រះសម្រេចថាយល់ស្របដាក់ឯកសារហ្នឹងនៅចំពោះមុខអង្គជំនុំជម្រះ តើលោកចង់ទទួលបានឱកាសម្តងទៀតដើម្បីបង្ហាញ ក៏ដូចជាពិភាក្សាឯកសារហ្នឹង ឬមួយក៏លោកចង់ធ្វើជាសារណាជាលាយលក្ខណ៍អក្សរវិញ ដើម្បីឱ្យភាគីដទៃអាចឆ្លើយតបបាន។ ដូច្នេះតើលោកចង់បានជម្រើសមួយណា?

[១៥:១៦:៣០]

**លោក ឃីត រេយ៍ន័រ៖**

អរគុណលោកស្រី។ ខ្ញុំគិតថាប្រហែលជាខ្ញុំត្រូវតែពីរបីនាទី នៅពេលដែលចុងបញ្ចប់នៃការបង្ហាញដើម្បីឱ្យខ្ញុំអាននូវខ្លឹមសារនៃឯកសារនេះ។ ហើយបន្ទាប់មកទៀត គឺថាវានឹងបង្កើតជាផ្នែកនៃការបង្ហាញឯកសាររបស់ខាងព្រះរាជអាជ្ញា។ ដូច្នេះ ខ្ញុំគិតថាវាជាវិធីសាស្ត្រដ៏ត្រឹមត្រូវ ដ៏ងាយស្រួលក្នុងករណីដែលអង្គជំនុំជម្រះសម្រេចថា ឯកសារហ្នឹងគេអាចទទួលយកបាន ហើយមានភាពពាក់ព័ន្ធ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

លោកប្រធានបានយល់ស្របជាមួយខ្ញុំថា លោកអាចមានឱកាសបង្ហាញ ប៉ុន្តែមិនមែនមានន័យថាអង្គជំនុំជម្រះបានទទួលស្គាល់ថាឯកសារហ្នឹងត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ។ សូមអរគុណ។

**លោក ឃីត រេយ៉ន៍រ៖**

សូមអរគុណច្រើនលោកស្រីចៅក្រម។

[១៥:១៧:២៣]

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកលោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំសូមបន្តបង្ហាញឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញាពាក់ព័ន្ធទៅនឹងគោលនយោបាយស្តីពីសហករណ៍ និងជំរំការងារ។ ថ្ងៃនេះខ្ញុំប្រហែលជាមិនអាចចប់ទេ ខ្ញុំនឹងបន្តនៅព្រឹកស្អែកទៀត។ ដើម្បីបញ្ជាក់បញ្ហាឲ្យបានច្បាស់នោះ គឺថាយើងមានបំណងប្រើប្រាស់២ថ្ងៃដើម្បីបង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម។ ដូច្នេះ យើងប្រហែលជាអាចបញ្ចប់នៅស្អែកល្ងាចម៉ោង៤ពាក់ព័ន្ធទៅនឹងគោលនយោបាយនេះ។

[១៥:១៨:៣៦]

គោលនយោបាយពាក់ព័ន្ធទៅនឹងសហករណ៍ និងជំរំការងារហ្នឹង នឹងត្រូវពិភាក្សារួមគ្នា ដោយសារតែនៅក្នុងឯកសារជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា គឺថាមិនមានការបែងចែកគ្នាឲ្យដាច់ច្បាស់រវាងសញ្ញាណទាំងពីរហ្នឹងទេ គឺពាក្យសហករណ៍ហ្នឹងក្តោបរួមទាំងការដ្ឋាន ឬក៏ជំរុំការងារផងដែរ។ ក៏ប៉ុន្តែនៅពេលបញ្ចប់ការបង្ហាញឯកសារនោះ ខ្ញុំនឹងលើកឡើងអំពីឯកសារជាក់លាក់តែម្តងដែលពាក់ព័ន្ធទៅនឹងជំរំការងារ។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន។ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអភ័យទោសដែលខ្ញុំកាត់ផ្តាច់សហព្រះរាជអាជ្ញា។ ជាថ្មីម្តងទៀតនេះហើយ ខ្ញុំសូមការបំភ្លឺពីអង្គជំនុំជម្រះ។ យើងឃើញថានៅក្នុងឯកសារដែលសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីចង់បង្ហាញនោះ គឺមានឯកសារដែលពាក់ព័ន្ធទៅនឹងគោលនយោបាយទាំងប្រាំ

របស់កម្ពុជាប្រជាធិបតេយ្យ។ ពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវ។ ដូច្នេះខ្ញុំមិនអាចរង់ចាំបានទេ ខ្ញុំត្រូវតែសួរបញ្ជាក់ពីអង្គជំនុំជម្រះឲ្យបានច្បាស់អំពីពេលនេះ ពីព្រោះថានៅពេលនេះវាមានបញ្ហានៃដំណើរការសវនាការយើងហើយ។ ដូច្នេះខ្ញុំចង់ដឹងថាតើ យើងនៅតែស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១ ដដែល ឬក៏យ៉ាងណា? ពីព្រោះថាអង្គជំនុំជម្រះបានបញ្ជាក់ជាច្រើនលើកច្រើនដង ហើយក៏បញ្ជាក់ដោយសេចក្ដីសម្រេចនៃការបំបែកនីតិវិធី E284 ហើយ គឺចុះថ្ងៃទី២៦ ខែមេសា ២០១៣ គឺអង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ ហើយនិងក៏ដូចជានៅក្នុងឧបសម្ព័ន្ធ E124/7.3។ ត្រង់ចំណុចនេះខ្ញុំយោងទៅលើកថាខណ្ឌ៥ ដែលក្នុងនោះអង្គជំនុំជម្រះលើកឡើងអំពីទម្រង់នៃការទទួលខុសត្រូវ ដែលនឹងអាចពិភាក្សានៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១។ នៅក្នុងកថាខណ្ឌ៥ មានបញ្ជាក់អំពីទម្រង់នៃការទទួលខុសត្រូវ។ ក) ការទទួលខុសត្រូវដែលកើតចេញពីការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម។

[១៥:២១:២០]

កថាខណ្ឌ១៥/២២ ទៅដល់-- ២១ -- សូមទោស ១៥២១ ទៅដល់១៥២៥។ គឺថាលើកលែងតែការពាក់ព័ន្ធទៅនឹងការរំលោភធ្ងន់ធ្ងរទៅលើកិច្ចព្រមព្រៀងហ្សឺណែវ ហើយនិងការពាក់ព័ន្ធការបង្កើតសហករណ៍ និងជំរំការងារ ការអប់រំសមាសភាពមិនល្អ និងការកម្ទេចខ្មាំងទាំងក្នុង និងក្រៅជួរបក្ស និងការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍។ ខ្ញុំសូមបិទវង់ក្រចកត្រង់ចំណុចនេះ។ ហើយអនុស្សរណៈបានបន្តទៀតថា “ហើយយើងក៏ពិនិត្យពាក់ព័ន្ធទៅនឹងមន្ត្រី ហើយនិងទាហាន លន់ នល់។ ពាក់ព័ន្ធទៅនឹងចំណុចដែលថាចាប់វិធានការដាក់លាក់ពាក់ព័ន្ធទៅនឹងក្រុមជាក់លាក់មួយចំនួន ជាពិសេសជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន ហើយនិងអ្នកទទួលខុសត្រូវចាស់ៗ គឺមន្ត្រីរាជការ ទាហាន និងគ្រួសាររបស់សាធារណរដ្ឋខ្មែរ”។

[១៥:២២:៣១]

ដូច្នេះ នៅក្នុងដែលអង្គជំនុំជម្រះយោងនៅក្នុងសេចក្ដីសម្រេចស្ដីពីការបំបែកនីតិវិធីនោះ គឺបានបញ្ជាក់ថានៅក្នុងសវនាការនៃការពិនិត្យទៅលើទម្រង់នៃការទទួលខុសត្រូវនោះក៏ដោយ ក៏យើងនៅតែស្ថិតនៅក្នុងក្របខ័ណ្ឌសំណុំរឿង០០២/០១ ដដែល។ បញ្ជីដែលផ្ញើដោយការិយាល័យសហព្រះរាជអាជ្ញានោះខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បីពិនិត្យទៅលើបញ្ជីទាំងស្រុងដែលផ្ញើដោយដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ញើតាមអ៊ីម៉ែលអម្បាញ់មិញនេះទេ។ ក៏ប៉ុន្តែខ្ញុំពិនិត្យមើលថា ឥឡូវនេះយើងកំពុងតែងាកចេញអំពីសវនាការលើកឯកសារ គឺយើងងាកចេញពីក្របខ័ណ្ឌសវនាការ ០០២/០១។ ដូច្នេះហើយ

ដែលខ្ញុំត្រូវតែងើបឡើងដើម្បីធ្វើការកត់សម្គាល់បែបនេះ។

[១៥:២៣:២៣]

យើងអាចនិយាយបាននៅពេលបញ្ចប់សវនាការនេះក៏បាន ក៏ប៉ុន្តែ ខ្ញុំចង់បញ្ជាក់ឱ្យបានច្បាស់ ហើយសូមការបំភ្លឺពីអង្គជំនុំជម្រះ សូមមេត្តាផ្តល់នូវព័ត៌មានលម្អិតបន្ថែមអំពីរបៀបនៃដំណើរការសវ-នាការរបស់យើងនេះ។ ប្រសិនបើយើងពិនិត្យមើលព័ត៌មាននៅក្រៅអង្គហេតុ ក្រៅក្របខ័ណ្ឌនោះ យើងមានបញ្ហាពាក់ព័ន្ធនឹងសច្ចភាពផ្លូវច្បាប់ហើយ។ តើយើងនឹងពិនិត្យទៅលើឯកសារគន្លឹះយ៉ាងម៉េចកើតបើឯកសារទាំងអស់នោះវាចេញពីក្របខ័ណ្ឌសំណុំរឿង០០២/០១ ទៅហើយនោះ?

ដូច្នេះអង្គហេតុដែលពាក់ព័ន្ធនោះវាចេញក្រៅអំពីអង្គហេតុដែលយើងពិភាក្សាគ្នានៅក្នុងសវនាការ។ ដូច្នេះយើងមិនដឹងថាតើយើងធ្វើយ៉ាងម៉េចនោះទេ? ដូច្នេះខ្ញុំគិតថា មិនមែនជាបញ្ហាតូចតាចទេត្រង់ចំណុចនេះ។ ពីព្រោះថាយើងត្រូវតែដឹងថា តើយើងត្រូវពិភាក្សា យើងត្រូវដោះស្រាយជាមួយនឹងឯកសារទាំងអស់នេះយ៉ាងម៉េចដើម្បីយើងអាចសរសេរនូវសេចក្តីសន្និដ្ឋានស្ថាពរចុងក្រោយរបស់យើងបាន និងសារណាស្ថាពរ។ ដូច្នេះក្នុងដំណាក់កាលនេះ ខ្ញុំសូមឱ្យអង្គជំនុំជម្រះមេត្តាផ្តល់សេចក្តីចង្អុលបង្ហាញសេចក្តីបំភ្លឺឱ្យបានច្បាស់ ពីព្រោះថាឥឡូវនេះយើងកំពុងតែមានបញ្ហាគតិយុត្តហើយ ហើយក៏សូមបញ្ជាក់ឱ្យបានច្បាស់អំពីរបៀបនៃការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះយើងពិនិត្យមើលថា ឯកសាររបស់ពួកគាត់នេះ គឺអាចនឹងដកចេញអំពីក្របខ័ណ្ឌនៃសវនាការ ០០២/០១ របស់យើងហើយ។

[១៥:២៥:០២]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាខាង -- ចំពោះខាងការិយាល័យសហព្រះរាជអាជ្ញាគឺយល់ឃើញថាការបង្ហាញឯកសារទៅលើសហករណ៍ និងជំរំការងារហ្នឹង គឺថាវាប្រហែលជាអាចមើលទៅដូចវាមិនសូវល្អទេ ពីព្រោះថាវាអាចនឹង -- ដូចជាយើងបានវិភាគ យើងបានផ្លាស់ប្តូរអ៊ីម៉ែលគ្នាទៅវិញទៅមករួចមកហើយតាំងពីមុនមកនោះ។ ទោះបីជាមេធាវីការពារក្តី ខៀវ សំផន ស្នើសុំនូវការបំភ្លឺក៏ដោយ ខ្ញុំគិតថានៅក្នុងដីកាដំណោះស្រាយគឺកថាខណ្ឌ១៥៦ ទៅ១៥៩ គឺនិយាយអំពីគោលនយោបាយ

នៅក្នុងក្របខ័ណ្ឌនៃសហឧក្រិដ្ឋកម្មរួម។ ដូច្នេះវាស្ថិតនៅក្នុងកថាខណ្ឌដែលអង្គជំនុំជម្រះចាត់ទុកថាជាផ្នែកនៃសំណុំរឿង០០២/០១ហើយ។

ចំណុចទី២ គឺថាមានការស្តីបន្ទោសមកឲ្យយើងដែលថា បង្ហាញឯកសារនុំងមិនត្រូវ។ តាមពិតឯកសារទាំងអស់ហ្នឹងគឺជាឯកសារ E3 ហើយដែលទទួលយកដោយអង្គជំនុំជម្រះរួចមកហើយ។ ហើយប្រសិនបើយើងទទូចថានៅក្នុងសំណុំរឿង០០២/០១ នេះគឺថានិយាយតែអំពីការបង្កើត និងការតាក់តែងគោលនយោបាយដូចដែលមានបញ្ជាក់នៅក្នុងកថាខណ្ឌ១៥៦ និង១៥៩ នៃដីកាដំណោះស្រាយនោះ យើងខ្ញុំនឹងកម្រិតតែត្រឹមហ្នឹង ក៏ប៉ុន្តែមានករណីលើកលែងពីរ គឺថាយើងអាចបង្ហាញឯកសារដែលចេញមកពីមូលដ្ឋានដែលបង្ហាញថាការអនុវត្តគោលនយោបាយទាំងអស់នេះ គឺវាបញ្ជាក់អំពីការអនុវត្តនយោបាយទាំងអស់នេះហើយ។ ហើយយើងមើលទៅនៅក្នុងយុត្តិសាស្ត្រអន្តរជាតិនោះគឺថាបានបង្ហាញអំពីការបង្កើតគោលនយោបាយនៅមូលដ្ឋានជាលក្ខណៈទូទៅ ហើយវាអាចប្រើប្រាស់ជាភស្តុតាងដែលបញ្ជាក់អំពីអត្ថិភាពនៃគោលនយោបាយនេះផ្ទាល់តែម្តង។

[១៥:២៧:៣០]

ដូច្នេះ ខ្ញុំគិតថាមេធាវីការពារក្តីគួរតែទុកពេលឲ្យយើងខ្ញុំបង្ហាញឯកសារ។ ហើយប្រសិនបើមេធាវីការពារក្តីជំទាស់ទៅនឹងតម្លៃជាភស្តុតាងយ៉ាងណាឬក៏យ៉ាងណានោះ គឺគាត់អាចនឹងធ្វើបាននៅពេលដល់វេនរបស់ពួកគាត់។ ដូច្នេះ ខ្ញុំគិតថាមិនសមស្របនៅពេលដែលពួកគាត់លើកឡើងនូវចំណុចបែបនេះនៅក្នុងដំណាក់កាលនេះនោះ។ លើកលែងតែអង្គជំនុំជម្រះពិភាក្សាសម្រេចឲ្យបានច្បាស់ថាតើយើងខ្ញុំនឹងធ្វើយ៉ាងម៉េច។ បើថាមិនអាចធ្វើនៅពេលនេះបាន យើងអាចធ្វើនៅថ្ងៃស្អែកក៏បានតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:២៨:២០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បន្ថែមបន្តិចទៅលើអ្វីដែលបានលើកឡើងរបស់សហព្រះរាជអាជ្ញា។ ខ្ញុំគាំទ្រទៅលើប្រសាសន៍របស់សហព្រះរាជអាជ្ញា ហើយខ្ញុំភ្ញាក់ផ្អើលទៅនឹងអន្តរាគមន៍របស់មេធាវីការពារក្តី។ ព្រោះថាយើងដឹងច្បាស់ហើយនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនោះ យើងមាន

អនុស្សរណៈរបស់អង្គជំនុំជម្រះ ហើយយើងបញ្ជាក់ហើយថានៅក្នុងអនុស្សរណៈទាំងអស់នោះគឺថាយើងអាចលើកឡើងអំពីគោលនយោបាយទាំងប្រាំនៅក្នុងសវនាការ អំពីឯកសារដែលពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ដូច្នេះតាំងពីដំបូងមកយើងច្បាស់ហើយថាយើងនិយាយអំពីគោលនយោបាយទាំងប្រាំ។ ដូច្នេះយើងចង់ដឹងថាតើ -- គាត់ចង់ដឹងថាតើធ្វើរបៀបម៉េចនោះ ខ្ញុំគាំទ្រទៅលើសហព្រះរាជអាជ្ញា។ គឺថានៅពេលដែលយើងបង្កើតគោលនយោបាយនៅក្នុងទស្សនទានអ្វីនោះ គឺថាយើងមានកម្មវត្ថុច្បាស់លាស់ដែលកំណត់តាំងពីដំបូង តាំងពីពេលដែលបង្កើតមកម្ល៉េះ។ ដូច្នេះយើងក៏ត្រូវគិតទៅលើគោលការណ៍ជាមូលដ្ឋានផងដែរ។ ដូច្នេះតាមរយៈសក្ខីកម្មមួយនោះ យើងអាចបង្ហាញឃើញថា វាមានបែបនេះ ហើយយើងអាចនឹងបន្តទៅទៀត។ ដូច្នេះ ផ្តើមចេញពីសក្ខីកម្មហ្នឹងហើយយើងអាចបង្កើតអំពីមូលដ្ឋានជាក់លាក់នៃគោលនយោបាយទាំងអស់នេះដែលត្រូវបានបង្កើតតាំងពីដំបូង ហើយនិងមានការអនុវត្តជាបន្តៗមកទៀត។

[១៥:២៩:៤៧]

ដូច្នេះ ខ្ញុំសូមបន្ថែមទៅលើមតិរបស់សហព្រះរាជអាជ្ញាថា យើងអាចយោងទៅលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដែលបញ្ជាក់ថា-- ជួនកាលនៅពេលដែលយើងបង្ហាញអំពីគោលនយោបាយជាលក្ខណៈទ្រឹស្តីនោះយើងត្រូវតែឆ្លងកាត់តាមរយៈការអនុវត្តគោលនយោបាយទាំងអស់នោះ។ ហើយនៅពេលដែលយើងពិនិត្យទៅលើសក្ខីកម្មមួយចំនួននោះយើងអាចបង្កើតអំពីលក្ខណៈជាស៊ីសង្វាក់ ឬក៏ជាលក្ខណៈប្រព័ន្ធនៅទូទាំងប្រទេសតែម្តង។ ដូច្នេះនៅពេលដែលយើងមិនទាន់អាចបង្ហាញឯកសាររបស់ខ្ញុំនោះ គឺថាគាត់មិនអាចលើកឡើងបែបនេះនោះទេ។ ដូច្នេះច្បាស់ណាស់គឺថា អង្គជំនុំជម្រះបានស្នើឲ្យយើងទាំងអស់គ្នាបង្ហាញអំពីឯកសារដែលពាក់ព័ន្ធទៅនឹងគោលនយោបាយទាំងប្រាំ គឺមិនមែនតែនិយាយអំពីគោលនយោបាយនៃការជម្លៀសដោយបង្ខំនោះទេ។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយខ្លី។ យើងមិនបានឆ្លើយតបតាមអ៊ីម៉ែលទេនៅក្នុងសវនាការគឺថានៅពេលដែលយើងមានចំណុចសំខាន់ដែលយើងត្រូវលើក គឺត្រូវតែលើកនៅក្នុងសវនាការមិនចង់លើកនៅក្នុងអ៊ីម៉ែលនោះទេ។ ចំណុចទីពីរ ពាក់ព័ន្ធទៅនឹងប្រតិកម្មតបរបស់យើងនោះគឺថាយើងមានបញ្ជីឯកសារដែលភាគីផ្សេងៗចង់ដាក់បង្ហាញនៅចន្លោះម្សិលមិញ និងថ្ងៃនេះ។ ដូច្នេះវាបង្ហាញអំពីឱកាសដែលអាចឲ្យយើងឆ្លើយតបបាន។ ហើយពាក់ព័ន្ធទៅនឹងបញ្ហាសក្ខីកម្មដែលចង់បង្ហាញ

អំពីគោលនយោបាយនោះខ្ញុំអត់មានបញ្ហាទេចំពោះត្រង់ចំណុចនេះនោះ។ ដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាគាត់បង្ហាញទៅ បង្ហាញសក្ខីកម្ម ហើយនិងព័ត៌មានដែលពាក់ព័ន្ធទៅនឹងគោល-នយោបាយទាំងពីរដែលជាកម្មវត្ថុនៃសវនាការរបស់យើងនេះ។ អ៊ីចឹងអត់មានលើសពីហ្នឹងទេ។ ដូច្នេះខ្ញុំមិនមែនស្នើសុំដើម្បីរារាំងដល់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយនៃការជម្លៀសដោយបង្ខំ ឬគោលនយោបាយនៃការសម្លាប់ទាហានលន់នល់នោះទេ ព្រោះថាចំណុចទាំងអស់ហ្នឹងវាទាក់ទងទៅនឹងសវនាការរបស់យើង។ ក៏ប៉ុន្តែចំណុចផ្សេងទៀត គោលនយោបាយផ្សេងទៀត វាត្រូវធ្វើសវនាការផ្សេងទៀត។ ដូចដែលបញ្ជាក់ដោយសេចក្តីសម្រេចនៃការបំបែកកិច្ចដំណើរការនីតិវិធីនោះហើយ។ ដូច្នេះខ្ញុំគិតថា យើងនៅក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះនោះយើងមិនអាចលើកចំណុចទាំងអស់នោះចំណុចលើកឡើងអំពីទម្រង់នៃការទទួលខុសត្រូវហើយបន្ទាប់មកយើងយកមកពិនិត្យនៅក្នុងសំណុំរឿង០០២/០២ នោះទេ។ ដូច្នេះ ខ្ញុំគិតថាវាមានបញ្ហានីតិវិធី។ ហើយខ្ញុំត្រូវតែបញ្ជាក់ឲ្យបានច្បាស់ ពីព្រោះថាឥឡូវនេះយើងកំពុងស្ថិតនៅក្នុងសវនាការបង្ហាញឯកសារគន្លឹះ។ ខ្ញុំត្រូវតែបង្ហាញនូវការកត់សម្គាល់របស់ខ្ញុំ។ ចំពោះខ្ញុំអត់មានបញ្ហាអីទេ ចំពោះការជម្លៀសដោយបង្ខំហើយនិងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃពីព្រោះថាវាស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១ ក៏ប៉ុន្តែ ខ្ញុំសូមឲ្យភាគីអនុវត្តទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធី។ ហើយប្រសិនបើមានសេចក្តីសម្រេចថ្មីរបស់អង្គជំនុំជម្រះតុលាការកំពូលនោះយើងនឹងអនុវត្តទៅតាមនោះទៀត។

[១៥:៣៣:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៨:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ក្នុងការដាក់បង្ហាញឯកសារដោយក្រុមតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះសូមបញ្ជាក់សាជាថ្មីអំពីសេចក្ដីណែនាំដើមរបស់អង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងគោលនយោបាយទាំងប្រាំដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ។ អង្គជំនុំជម្រះជាដរាបបានបញ្ជាក់ថាភស្តុតាងដែលនាំទៅដល់ការបង្ហាញអត្ថិភាពគោលនយោបាយទាំងប្រាំ ក៏ប៉ុន្តែឯកសារពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយទាំងអស់នោះ គឺអាចអនុញ្ញាតទៅបានលើកលែងតែវាពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ។ ហេតុដូច្នេះហើយអង្គជំនុំជម្រះគួរតែកម្រិតការបង្ហាញឯកសាររបស់ខ្លួននៅក្នុងដែលកំណត់ដែលអង្គជំនុំជម្រះបានណែនាំ។ ខ្ញុំសង្ឃឹមថាអ្វីដែលយើងណែនាំនេះគឺគ្រប់គ្រាន់ឲ្យលោកយល់បានហើយ លោកសហព្រះរាជអាជ្ញា។ សូមអរគុណលោកច្រើន។

[១៥:៣៩:៥៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកស្រីចៅក្រម។ បើខ្ញុំមិនអាចបន្តទៅមុខទៀតជាច្រើនទេរសៀលនេះនោះអ៊ីចឹងព្រឹកស្អែកបានខ្ញុំនិយាយបានច្រើនជាងនេះ ដោយសារមានការកាត់ផ្តាច់ខ្ញុំថ្ងៃនេះ។ លោកស្រីចៅក្រម ខ្ញុំនឹងគោរពតាមការបង្គាប់បញ្ជារបស់លោកស្រីចៅក្រម។

បាទ ដើម្បីជាកិច្ចផ្ដើមសេក្ដីទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជា ទាក់ទងទៅនឹងសហករណ៍ដែលត្រូវបានបង្កើតឡើងនៅមុនឆ្នាំ៧១-៧២ ហើយគោលនយោបាយនេះត្រូវបានអនុវត្តទាំងស្រុង ហើយនិងជំរុញថែមទៀតក្រោយពីឆ្នាំ៧៥។ ដូចដែលយើងឃើញនៅក្នុងឯកសារមួយចំនួនហ្នឹង គឺថាមាននិរន្តរភាពនៃការអនុវត្តគោលនយោបាយនេះ។ អ៊ីចឹងខ្ញុំសូមយោងទៅតែឯកសារមុនឆ្នាំ១៩៧៥ទេ។

ផ្នែកទី១ នៃការធ្វើបទបង្ហាញរបស់ខ្ញុំនោះ លើកតែអំពីឯកសារទាក់ទងទៅនឹងសហករណ៍ក្នុងន័យទូលាយ។ ឯកសារដែលខ្ញុំចង់បង្ហាញគឺឯកសារ E3/18 គឺជាសៀវភៅរបស់លោក ខៀវ សំផន ដែលមានចំណងជើងថា “ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់”។

[១៥:៤១:២៥]

ខៀវ សំផន បាននិយាយអំពីការបង្កើតសហករណ៍នៅតាំងពីឆ្នាំ១៩៧១ និងដើម៧២ ហើយនិងគោលនយោបាយដែលពាក់ព័ន្ធទៅនឹងការធ្វើសមូហភាវកម្មនៃប្រទេសកម្ពុជា។ នៅក្នុង ជាភាសាខ្មែរគឺ ERN 00103870 រហូតទៅដល់លេខ 01 នៅចុងកន្ទុយ។ ជាភាសាបារាំងគឺ 00595482, ជាភាសាអង់គ្លេសគឺ 00103776 រហូតដល់ 77។ ខៀវ សំផន សរសេរដូចតទៅនេះ ខ្ញុំសូមដកស្រង់ “ចំណុច

មួយទៀតជាចំណុចពិសេសរបស់ចលនាខ្មែរក្រហម គឺការចាត់តាំងសហករណ៍ជាទូទៅនៅក្នុងតំបន់រំដោះតាំងពីចុងឆ្នាំ១៩៧១ ដើមឆ្នាំ១៩៧២ គឺមុនខ្មែរក្រហមទទួលបានជ័យជម្នះ"។ ហើយខាងក្រោមហ្នឹងបន្តិច គាត់និយាយដូចតទៅនេះ "សហករណ៍ទាំងនេះម្យ៉ាងជាមធ្យោបាយសម្រាប់ឲ្យខ្មែរក្រហមក្ដាប់សេដ្ឋកិច្ច ក្ដាប់ស្រូវ តែម្យ៉ាងទៀតជាឧបករណ៍រដ្ឋអំណាចមួយសំខាន់សម្រាប់គេប្រមូលកម្លាំងទប់ទល់នឹងសង្គ្រាមវៀតណាមដែលហៀរចូលក្នុងដីកម្ពុជា ហើយនិងរក្សាឯកសារភាពរបស់គេចំពោះមុខកុម្មុយនីស្តវៀតណាមផងដែរ។" បាទ សូមបញ្ចប់ការដកស្រង់។ បាទ ខ្ញុំសូមត្រឡប់មកនិយាយពីឯកសារនេះនៅពេលក្រោយ។

[១៥:៤៣:១៩]

ឥឡូវនេះខ្ញុំសូមអានសម្រង់មួយទៀតនៃឯកសារ E3/108។ ឯកសារនេះមានលេខសម្គាល់មួយទៀត គឺ E3/122។ គឺជាសម្រង់កិច្ចសម្ភាសន៍របស់លោក ខៀវ សំផន ដោយម៉េងទ្រី និង សុភ័ក្ត្រ ឿង នៅថ្ងៃទី០៩ ដល់ទី១១ មិថុនា ឆ្នាំ២០០៦។ នៅទំព័រជាភាសាខ្មែរ គឺ00347036, ជាភាសាបារាំង គឺ 00613203, ជាភាសាអង់គ្លេសគឺ00000928។ ខ្ញុំអានម្ដងទៀតគឺ 00000928។ លោកខៀវ សំផន លើកឡើងដូចតទៅនេះ "ដោយសារតែការទម្លាក់គ្រាប់បែកដែលមាននៅតាមជនបទដែលប្រជាជនបាននាំគ្នារត់មកទីក្រុងភ្នំពេញ។ ក្នុងពេលជាមួយនោះប្រជាជនបានមករស់នៅទីក្រុងភ្នំពេញក្នុងបំណងចៀសកុំឲ្យខ្មែរក្រហមបញ្ចូលគេទៅក្នុងសហករណ៍"។ ក្រោយមកបន្តិចទៀត "ប្រជាជនទាំងអស់នេះត្រូវបានភៀសសឹកដើម្បីចៀសវាងគ្រាប់បែកអាមេរិកាំង ហើយនិងដើម្បីរត់គេចពីសហករណ៍នៅក្នុងតំបន់ដែលគ្រប់គ្រងដោយខ្មែរក្រហម។ ទន្ទឹមហ្នឹងនោះ ហេតុអ្វីក៏សហករណ៍ទាំងអស់នោះត្រូវបានគេបង្កើតឡើង? បើតាមពិតទៅកាលសម័យនោះខ្មែរក្រហមខំព្យាយាមទិញស្រូវ ទៅរបប លន់ នល់ ហើយនិងមក -- ខ្មែរនៅពេលក្រោយ។ អ៊ីចឹងបង្កើតសហករណ៍ទាំងអស់នេះ ដើម្បីឲ្យប្រជាជនទាំងអស់មានស្រូវអង្ករបរិភោគគ្រប់គ្រាន់ ប៉ុន្តែបើគិតសព្វគ្រប់ទៅ ប៉ុល ពត ចង់ជួយប្រទេសកម្ពុជា ហើយនិងឲ្យកម្ពុជាទទួលបានឯករាជ្យភាព។ អ្នកដែលចង់កាត់ទោស ប៉ុល ពត នោះ មិនបានដឹងពីអ្វីដែលកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រកម្ពុជានោះទេ"។ បាទ ខ្ញុំសូមបញ្ចប់ការដកស្រង់ខ្ញុំកន្លែងនេះ ខ្ញុំសូមកែការបកប្រែជាភាសាអង់គ្លេស ព្រោះថាជាភាសាបារាំងនោះគេនិយាយថា "អ្នកដែលចង់បោះ -- ថាអ្នកដែលចង់កាត់ទោសខ្មែរក្រហមនោះ អ្នកដែលមិនដឹងរឿងអ្វីសព្វគ្រប់នៅក្នុងប្រទេសកម្ពុជា ហើយការនិយាយដូច្នេះមិនសមស្របទេ"។ អ៊ីចឹងមានបញ្ហាបកប្រែ។

[១៥:៤៦:១២]

សម្រង់មួយទៀតនៃកិច្ចសម្ភាសន៍នោះ មិនមានការបកប្រែជាភាសាបារាំងទេ គឺឯកសារ E -- 0034736 ជាអង់គ្លេសគឺ 00000928 ហើយខ្ញុំសូមអានជាភាសាអង់គ្លេស ដោយសារពុំមានការបកប្រែជាភាសាបារាំងទេ។ បាទ អ៊ីចឹងខ្ញុំសូមឲ្យអ្នកបកប្រែត្រៀមលក្ខណៈ។

សូមដកស្រង់ពី ម៉េងទ្រី "ហេតុអ្វីបានជាមានការជម្លៀសនៅក្នុងឆ្នាំ៧៥? ខៀវ សំផន បានឆ្លើយថា គេជម្លៀសប្រជាជនដើម្បីទៅរស់នៅក្នុងសហករណ៍។ នៅក្នុងសហករណ៍ប្រជាជនមិនមានសេរីភាពទេ តែពួកគេមានអាហារបរិភោគគ្រប់គ្រាន់។ ប្រជាជនក៏មានកម្លាំងគ្រប់គ្រាន់ដើម្បីប្រយុទ្ធនឹងសត្រូវរបស់យើង"។ សូមបញ្ចប់ការដកស្រង់។

បាទ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីឯកសារដំបូងដែលខ្ញុំបានបង្ហាញអម្បាញ់មិញ គឺឯកសារ E3/18 ជាសៀវភៅរបស់លោក ខៀវ សំផន ទាក់ទងទៅនឹង -- ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"។ ខ្ញុំសូមអានសម្រង់ចំនួនបី៖

គឺមានទំព័រជាភាសាខ្មែរ គឺ 00103873, ជាភាសាបារាំងទំព័រ១២៨ ERN គឺ 00395485, អង់គ្លេស គឺទំព័រ១១២ ERN 00103779។ ខៀវ សំផន និយាយដូចតទៅនេះ "ប៉ុល ពត មានជំនឿថា ជំរុញឲ្យកម្ពុជាទៅជាប្រទេសសង្គមនិយមឆាប់រហ័ស គឺឲ្យប្រទេសកម្ពុជាខ្លាំងអាចទប់ទល់នឹងគ្រោះអាសន្នមកពីសំណាក់វៀតណាម ការពិត ការប្រញាប់ប្រញាល់ជំរុញចលនាសមូហភាវូបនីយកម្មទូទាំងប្រទេសដោយរួមទាំងអំពើផ្តាច់ការនៃ -- ដែលជាប់ជាមួយគ្នានឹងការបង្ខំនេះ បែរធ្វើឲ្យប្រទេសកម្ពុជាខ្សោះឈាមទៅវិញ"។ សូមបញ្ចប់ការដកស្រង់។

សម្រង់មួយទៀត ERN ជាភាសាខ្មែរគឺ 00103842, ភាសាបារាំងទំព័រ៧៥ ERN 00395434, អង់គ្លេសគឺ 00103753។ ខៀវ សំផន លើកឡើងដូចតទៅនេះ "ចំពោះទ្រឹស្តីបដិវត្តន៍ដែលផ្សាយនៅក្នុងអំឡុងឆ្នាំ ដែលខ្ញុំរៀននៅប្រទេសបារាំង គេបែងចែកសហករណ៍ជាច្រើនកម្រិត។ សហករណ៍ដែលគេហៅថា កម្រិតខ្ពស់ គេឲ្យចែកភោគផលប្រចាំឆ្នាំទេ។ គេប្រមូលផលទាំងអស់ដាក់ក្នុងឃ្លាំងរួម ហើយសមាជិកសហករណ៍រស់នៅជាសហគមន៍។ គេបើកអង្ករកំប៉ុងឲ្យសមាជិកម្នាក់ៗស្មើគ្នាក្នុងមួយថ្ងៃៗ"។

[១៥:៤៩:៣៩]

ហើយនៅក្រោមហ្នឹងបន្តិចគាត់និយាយដូចតទៅនេះទៀត។ "ប៉ុន្តែអ្វីជាការភ្ញាក់ផ្អើលខ្លាំងខុសពី

ការស្មានរបស់ខ្ញុំ គឺថាពេលដែលជួបសន្ទនាជាមួយកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំ១៩៥៧ -- ៧៥ ស្រាប់តែគេប្រាប់ខ្ញុំថា មានការចាត់តាំងសហករណ៍កម្រិតខ្ពស់នៅក្នុងតំបន់រំដោះទូទាំង -- ទូទៅតាំងពីឆ្នាំ១៩៧៣ម្ល៉េះ"។ ហើយគាត់បន្តទៀត "ដូច្នេះ បើដូច្នេះការចាត់តាំងរបៀបនេះមានតែធ្វើឡើងដោយបង្ខំចិត្តពីព្រោះកសិករប្រទេសណាក៏មិនងាយសុខចិត្តប្រគល់អោគផលនៃការចិត្តខំប្រឹងប្រែងបែកញើសហូរឈាមរបស់ខ្លួនទៅឲ្យអង្គការណាមួយទេ លុះត្រាតែមានការពិសោធដោយផ្ទាល់ គេឃើញនឹងផ្ទាល់ភ្នែក ដោយគេឆ្លងកាត់ពីសហករណ៍កម្រិតទាបជាបណ្តើរៗ គេអាច ថាគេអាចទទួលផលចំណេញពីការចាត់តាំងសហករណ៍កម្រិតខ្ពស់បាន។

ទាក់ទងនឹងការបង្កើតសហករណ៍ជាន់ខ្ពស់ កម្រិតខ្ពស់ចាប់ពីឆ្នាំ១៩៧៣មកនោះ ខ្ញុំសូមដកស្រង់ឯកសារមួយដែលមានទំព័រជាភាសាខ្មែរគឺ 00103772 រហូតដល់ 73, ជាភាសាបារាំងទំព័រ១២៧ ERN គឺ 00395484, ជាភាសាអង់គ្លេសទំព័រ១១១, ERN 00103778។ ខៀវ សំផន លើកឡើងដូចតទៅនេះ "មូលដ្ឋាននៃចលនាបដិវត្តន៍ស្ថិតនៅក្នុងសមូហភាវូបនីយកម្ម កសិកម្មចាប់តាំងពីឆ្នាំ១៩៧១ និងដើមឆ្នាំ១៩៧២ ហើយវិធាននៃការកើនប្រមូលផ្តុំស្រូវនៅតាមសហករណ៍កម្រិតខ្ពស់នៅក្នុងតំបន់ដែលខ្មែរក្រហមកាន់កាប់" សូមបញ្ចប់ការដកស្រង់។

[១៥:៥១:៥៩]

បាទ ទាក់ទងទៅនឹងការភ្ញាក់ផ្អើលរបស់លោក ខៀវ សំផន ដដែលអំពីសហករណ៍កម្រិតខ្ពស់នោះគឺថាចាប់តាំងពីឆ្នាំ១៩៧៤ មានការនិយាយអំពីការបង្កើតសហករណ៍កម្រិតខ្ពស់នេះ ហើយឯកសារដែលខ្ញុំបង្ហាញនេះ បញ្ជាក់អំពីការបង្កើតសហករណ៍ទូទាំងនៅក្នុងតំបន់រំដោះទាំងស្រុងតែម្តង។ គឺឯកសារ E3/146 គឺជាទស្សនាវដ្តីយុវជន យុវនារីបដិវត្តចុះថ្ងៃទី -- ចុះខែកញ្ញា ឆ្នាំ១៩៧៥។ ខ្ញុំសូមអានសម្រង់ជាភាសាខ្មែរគឺ 00283389 -- 02 (សូមទោស)។ បាទសូមអានលេខ ERN ម្តងទៀតជាភាសាខ្មែរ គឺ 00283402, ជាភាសាបារាំងគឺ 00611805, អង់គ្លេស 00538741។ ចំណងជើងទី៣ គឺថា "មោទនភាពគ្នាំឆ្លងមួយចំនួន។ យើងកំពុងតែទទួលបានជោគជ័យដ៏មហស្ចារ្យនៅក្នុងតំបន់រំដោះយើងបានកម្ទេចវណ្ណៈជិះជាន់ ហើយនិងយើងបានកាត់ផ្តាច់របបផលិតកម្មជិះជាន់ ហើយជាមូលដ្ឋានអស់ហើយ ហើយយើងបានចាត់តាំងសហករណ៍ផលិតកម្មកម្រិតទាប កម្រិតខ្ពស់ជាទូទៅហើយ"។ បាទ សូមចប់ការសកស្រង់។

[១៥:៥៣:៤៧]

បាទ ផ្នែកផ្សេងទៀតគឺខ្មែរ 00283411, ជាភាសាបារាំងគឺ 00611812, ជាអង់គ្លេសគឺ 00538748។ បាទ ខ្ញុំសូមដកស្រង់៖ “នៅក្នុងតំបន់រំដោះប្រភេទទី១ គ្មាននាយទុនជាតិទេ វានៅមាននៅតំបន់រំដោះប្រភេទទី២ប៉ុណ្ណោះ។ ហើយសព្វថ្ងៃនេះទៀតសោត ពួកនេះក៏សឹងតែអស់លទ្ធភាពជិះជាន់ទៅហើយដោយរដ្ឋយើងកាន់ពាណិជ្ជកម្មផ្ដាច់មុខ ជាពិសេសគឺពាណិជ្ជកម្មលើទំនិញជាយុទ្ធសាស្ត្រសំខាន់ៗហើយនិងចាត់តាំងសហករណ៍ផលិតកម្មពាសពេញគ្រប់ទីកន្លែង”។ សូមបញ្ចប់ការដកស្រង់។

ឯកសារបន្តទៀតគឺឯកសារ E3/16 ជាសៀវភៅរបស់លោក ខៀវ សំផន ដដែលទាក់ទងនឹងប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ គឺប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ។

[១៥:៥៥:១១]

ឯកសារនេះវាមានលក្ខណៈពាក់ព័ន្ធព្រោះថាយើងឃើញថា ខៀវ សំផន បញ្ចេញមតិរបស់ខ្លួនទាក់ទងទៅនឹងការបង្កើតសហករណ៍កម្រិតខ្ពស់នៅឆ្នាំ១៩៧៨ ហើយគាត់ក៏បង្ហាញពី -- ធ្វើការយុត្តិកម្មពីអត្ថិភាពនិងដំណើរការនៃសហករណ៍ទាំងអស់នេះនៅក្នុងសម័យសង្គ្រាម ហើយក៏គាត់ទិតៀនរិះគន់ពីសហករណ៍ទាំងអស់នេះផងដែរបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។ សម្រង់ទី១ ជាភាសាខ្មែរគឺ ERN 00380461, ជាភាសាបារាំងគឺ 00643887, ជាភាសាអង់គ្លេសគឺ 00498281 មានចំណងជើងទី៧: ហេតុអ្វីក៏មានការចាប់ចងហើយនិងការសម្លាប់ច្រើនយ៉ាងនេះ? សូមដកស្រង់៖ “ជាការពិតណាស់ការជម្លៀសប្រជាជនចេញពីទីក្រុងហើយពង្រីកសហករណ៍កម្រិតខ្ពស់ ដោយប្រញាប់ប្រញាល់គ្មានពេលពិនិត្យពិច័យ គ្មានពេលជ្រើសរើសសម្រិតសម្រាំងអប់រំប្រធានសហករណ៍ ការមិនចាយលុយ ការបន្តគ្រប់គ្រងប្រទេស ដូចកាលពីក្នុងពេលសង្គ្រាមដោយមានការលាក់ការណ៍សម្ងាត់ មានរបាំងតឹងរ៉ឹងមិនឲ្យនិយាយអ្វីប្រាប់គ្នាទៅវិញទៅមក បានបន្តិចបន្តួចជាការផ្ដល់អំណាចធំសម្បើមណាស់ថែមទៀតទៅដល់ស្ដេចត្រាញ់ទាំងនោះ”។ សូមបញ្ចប់ការដកស្រង់។

[១៥:៥៧:០០]

ហើយក្រោមហ្នឹងបន្តិចជាភាសាខ្មែរគឺ 003804 -- បាទ សុំទោសជាភាសាបារាំងទេអម្បាញ់មិញ គឺថា00643890, ជាភាសាខ្មែរគឺ 03804666, ជាភាសាអង់គ្លេសគឺ 00498284។ បាទ ខ្ញុំសូមដកស្រង់៖ “សហករណ៍កម្រិតខ្ពស់ត្រូវបានចាត់តាំងឡើងក្នុងឆ្នាំ១៩៧៣ ដីត្រូវបានប្រកាសជាដីសហករណ៍ ផលប្រចាំឆ្នាំក៏ត្រូវប្រកាសជាកម្មសិទ្ធិរួមរបស់សហករណ៍។ នៅក្នុងសភាពដែលប្រទេស

យើងត្រូវបានខ្ទេចខ្ទីខ្លាំងដោយសង្គ្រាមហើយ ស្រែមួយផ្នែកធំត្រូវបោះបង់ចោល ធ្វើលែងបាន។ មានតែធ្វើដូច្នេះទេទើបអាចចែកគ្នារស់បាន។ ហើយនៅសល់ស្រូវមួយចំនួនតែប៉ុណ្ណោះដើម្បីផ្គត់ផ្គង់ដល់កងទ័ពដើម្បីឲ្យឈ្នះសង្គ្រាម។ ទោះជាយ៉ាងណាក្តីក៏គង់នៅមានចលនាប្រឆាំងដែរ"។

បាទ ខ្ញុំសូមបន្តទៅទៀតខាងក្រោមបន្តិច "ក៏ប៉ុន្តែដោយប្រៀបធៀបមហាជនជាទូទៅនៅស៊ូទ្រាំទទួលយកសហករណ៍កម្រិតខ្ពស់នេះ ធ្វើម៉េចឲ្យតែរំដោះប្រទេសបាន ហើយបានសន្តិភាពមកវិញ។ ប៉ុន្តែដល់ចប់សង្គ្រាមហើយប្រជាជនកម្ពុជាទូទៅមិនឃើញហេតុផលអ្វីដើម្បីរក្សាការចាត់តាំងដ៏តឹងរ៉ឹងនេះទៀតទេ ប្រសិនជាយើងត្រឡប់ទៅយករូបភាពសហករណ៍ដែលបានចាត់តាំងឆ្នាំ៧១, ៧២ ដោយមានការបែងចែកផលប្រចាំឆ្នាំដោយយោងទៅតាមទំហំដីរបស់ម្នាក់ៗនៅក្នុងសហករណ៍ ប្រហែលជាសមស្របទៅនឹងសំណូមពររបស់ប្រជាជនជាង"។ សូមបញ្ចប់ការដកស្រង់។

[១៥:៥៩:០៩]

លោកប្រធានខ្ញុំសូមបន្តរហូតដល់ពេលសម្រាក។ទាក់ទងទៅនឹងសារៈសំខាន់ខ្លាំងនៃសហករណ៍ហើយនិងលទ្ធភាពនៃការធ្វើការដ្ឋានដែលសហករណ៍ទាំងអស់នេះផ្តល់ជូន។ លោក ខៀវ សំផន សរសេរដូចតទៅនេះទំព័រជាភាសាខ្មែរគឺ 00380470 រហូតដល់ 71, ជាភាសាបារាំងគឺ 00643893, ជាភាសាអង់គ្លេស គឺ00498286។ បាទ ខ្ញុំសូមដកស្រង់៖ "ប៉ុលពត បានគិតថាការបង្កើតសហករណ៍នេះធ្វើឲ្យបដិវត្តន៍នោះទៅមុខលឿន សហករណ៍កម្រិតខ្ពស់នេះ ហើយឲ្យយើងដើរលឿនជាងបដិវត្តន៍ចិននោះជាង៣០ឆ្នាំ និងជាងបដិវត្តន៍នៅកូរ៉េ នៅវៀតណាម។ ពីព្រោះវាបើកលទ្ធភាពយ៉ាងទូលាយដើម្បីធ្វើទំនប់ ជីកប្រឡាយ ស្រោចស្រពជនបទទូទៅប្រទេស ហើយបើកទស្សនៈធំទូលាយដើម្បីកសិកម្មកម្ពុជាចេញរួចផុតពីកសិកម្មអន់ថយទៅជាកសិកម្មទំនើប"។ បាទ សូមបញ្ចប់ការដកស្រង់។

បាទ បន្តមកទៀតនៅទំព័រជាភាសាខ្មែរគឺ 00380499 ទៅដល់លេខ 500 នៅចុង, ភាសាបារាំងគឺ 00643910, ជាភាសាអង់គ្លេសគឺ 00498303។ បាទ ខ្ញុំសូមដកស្រង់៖ "ប៉ុន្តែដើម្បីទៅដល់ទិសដៅនោះ គឺថាគោលនៅកសិកម្មទំនើប ដោយប្រទេសចេញពីសង្គ្រាមហិនហោច មហាហិនហោចហើយកំពុងប្រឈមមុខនឹគ្រោះអាសន្នអត់បាយដាច់ពោះស្លាប់ ចាប់ផ្តើមដំបូងត្រូវជម្នះសភាពការណ៍ដ៏លំបាក ដ៏មហាលំបាក" នៅក្រោមនឹងបន្តិច "ដូច្នេះត្រូវមានការបង្ខំសិន គឺបង្ខំឲ្យធ្វើការនឿយហត់ក្នុងសភាពខ្វះសព្វខ្វះគ្រប់ ទាំងអ្នកធ្លាប់ ទាំងអ្នកមិនធ្លាប់"។ បាទ សូមបញ្ចប់ការដកស្រង់។

[១៦:០១:៥៥]

បាទ លោកប្រធានខ្ញុំនៅសល់សម្រង់មួយទៀតដែលត្រូវបង្ហាញ។ ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើប្រជាជនចាស់ និងប្រជាជនថ្មីនៅក្នុងតាមសហករណ៍។ ខៀវ សំផន លើកឡើងដូចតទៅនេះដោយផ្ដល់មូលហេតុ។ ទំព័រជាភាសាខ្មែរ 00380469 ទៅដល់ 70, ជាភាសាបារាំងគឺ 00643892, ជាភាសាអង់គ្លេសគឺ 00498285 ទៅដល់ 86។ ខ្ញុំសូមដកស្រង់៖ "តាំងពីដើមរៀងមកបក្ស កងទ័ព និងរដ្ឋអំណាចថ្នាក់ផ្សេងៗគឺឈរលើមូលដ្ឋានវណ្ណៈ ហើយត្រូវចេញមកពីចលនាមហាជន"។

បាទ ខ្ញុំសូមទៅមុខបន្តិចទៀត "ដោយប្រជាជនជម្លៀសមិនដែលធ្លាប់ស្គាល់បក្ស និងកងទ័ព និងរដ្ឋអំណាចបដិវត្តន៍ផងនោះ គេពុំអាចមានលទ្ធភាពចូលធ្វើការនៅក្នុងរដ្ឋអំណាច សូម្បីតែថ្នាក់ទាប ដូចជាថ្នាក់ភូមិ ឬសហករណ៍ជាដើម"។ បាទ សូមបញ្ចប់ការដកស្រង់។

[១៦:០៣:១៨]

ឥឡូវខ្ញុំចូលទៅសម្រង់មួយទៀត "នេះគឺជាគោលការណ៍ប្រុងប្រយ័ត្នកុំឲ្យភ្នាក់ងាររបស់ប្រទេសខ្លះចូលមកស៊ីរូងរដ្ឋអំណាចបដិវត្តន៍កម្ពុជាបាន។ ដូច្នេះត្រូវតែក្ដាប់ប្រវត្តិរូបរបស់ម្នាក់ៗ ហើយដើម្បីឲ្យកម្មាភិបាលកសិករងាយក្ដាប់ប្រវត្តិរូបម្នាក់ៗនោះ វិធីដែលងាយបំផុតគឺបែងចែកប្រជាជនចាស់ចេញពីប្រជាជនថ្មី។ ប៉ុន្តែ ប៉ុល ពត ខ្លួនឯងតែងតែក្រើនរំឭកកម្មាភិបាលទាំងអស់ឲ្យខិតខំចៀសវាងកុំចាត់ទុកប្រជាជនថ្មីទាំងអស់ជាសត្រូវ ឬក៏ជាឈ្លើយសឹក ដោយមិនគិតគូរដល់គោលជំហរ គោលការណ៍ និងទស្សនៈរបស់បក្ស។ ប៉ុន្តែក្នុងការជាក់ស្ដែងច្រើនកន្លែងប្រជាជនថ្មីនៅតែគេចាត់ទុកថាជាឈ្លើយសឹកដូចកាលពីគេត្រូវជម្លៀសកាលពីថ្ងៃដំបូងមកម្ល៉េះ"។ បាទ សូមបញ្ចប់ការដកស្រង់។

លោកប្រធាន បើសិនជាលោកប្រធានអនុញ្ញាតឲ្យ ខ្ញុំអាចបង្ហាញឯកសារទៀត តែបើសិនជាលោកប្រធានមិនអនុញ្ញាតទេ សូមបញ្ចប់ឥឡូវនេះ។ បន្តស្អែកទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញា។ សវនាការនៅថ្ងៃនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៥ ខែមិថុនា ឆ្នាំ២០១៣ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តការដាក់បង្ហាញឯកសារគន្លឹះរបស់ភាគីចំពោះមុខអង្គជំនុំជម្រះ។ សូមភាគីនៃសំណុំរឿងក្ដី បុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការ និងសាធារណជនជ្រាប។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោកនួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ

អ.វ.ត.ក វិញចុះ។ ហើយនិងបង្គាប់ឲ្យនាំខ្លួនចូលមក ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

ដោយឡែកលោក នួន ជា ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*